ដោយ អែម.ម៉ុង

# អាចារ្យយីមេតស្ងៈ

(រឿងពិតនៅជំនាន់កើតអសន្តិសុខក្នុងប្រទេស)



www.elibraryofcambodia.org

អំណោយពីលោក ឡៅ ឃុនតារ៉ា ដល់គណៈខ្មែរ
ដើម្បីទុកដាក់ក្នុង elibrary of Cambodia.
កក្កដា ២០15.

# អាចារ្យឃី មេតស្សរៈ

(រឿងពិតនៅជំនាន់កើតអសន្តិសុខក្នុងប្រទេស)


និពន្ធដោយ

អ៊ែម ម៉ុខ



អ្នកបោះពុម្ពផ្សាយដោយ

លី អ៊ិចហ្លួយ

បោះពុម្ពលើកទីមួយ

ព.ស. ២៥៤៧ គ.ស. ២០០៣



រក្សាសិទ្ធិ

www.elibraryofcambodia.org

# អារម្ភកថា

ខ្ញុំមានបំណងចង់ឲ្យមិត្តអ្នកអានបានយល់ច្បាស់អំពីរឿងពិត ដែលកើតមាននៅជំនាន់កើតតសង្គមសុខក្នុងប្រទេស ។ ម្យ៉ាងទៀតរឿងនេះកប់នៅក្នុងភាពកំបាំងមិនសូវមានគេដឹងថា អាចារ្យយ៉េមានមនោគមវិជ្ជាបែបណាទេ ។

ដូច្នេះហើយបានជាខ្ញុំខំសរសេរនិទានរឿងនេះយកមកផ្សាយ បោះពុម្ពផ្សាយដើម្បីបង្ហាញនូវការពិត កុំឲ្យមនុស្សគេតែនិយាយវង្វេងវង្វាន់តាមការស្មានតទៅទៀត ។

រឿងអាចារ្យយ៉េនេះ សរសេរចប់យូរណាស់មកហើយ តែហេតុអ្វីខ្ញុំស្ងួតពេកមិនអាចបោះពុម្ពផ្សាយកើតនោះហើយរឿងអាថ៌កំបាំងដែលត្រូវតែលាតត្រដាងនោះមិនបាននេះ ក៏ដេកស្ងប់នៅតែក្នុងឃ្លាំងហិបឯកសាររបស់ខ្ញុំយ៉ាងក្ដៅស្ពុះរហូតមកដល់សព្វថ្ងៃណេះ កណ្ដៀរ ព្រឡាត ហ៊ាននិយាយសុំទោសផុះ ដោយដាក់ប្រឡាក់ខ្លួនពាក្យបាត់

www.elibraryofcambodia.org

ឃ្លាប្រយោគខ្លះ ៗ វិសែតនិងអត្ថបទផ្សេងទៀតផង ៗ

លុះមកដល់ថ្ងៃទី ៤ ខែមីនា ១៩៦៥ នេះ មានមិត្ត របស់ខ្ញុំម្នាក់ឈ្មោះ លី-គុយហួយ ធ្វើការនៅក្រុមហ៊ុនអគ្គិសនីកម្ពុជា លោកជាអ្នកស្នេហាអក្សរសាស្ត្រជាតិ មិនតែប៉ុណ្ណោះ លោកមានការឈឺចាប់ក្តៅក្រហាយចិត្តយ៉ាងខ្លាំងចំពោះពួកអាក្បត់ជាតិ មានអាខ្មែរក្រហម-ខៀវនិងអាខ្មែរសេរីជាដើម ដែលវាមានខួរក្បាលវង្វេងជាតិទៅបំរើមនោគមវិជ្ជាបរទេស មកធ្វើបាបសង្កត់សង្កិនបំផ្លិចបំផ្លាញជាតិឯង ៗ ដើម្បីឲ្យបានធូរស្បើយនូវការតានតឹងក្នុងចិត្តខ្លះនោះ លោកបានពន្យល់ឲ្យខ្ញុំសរសេររឿងណាមួយដែលមានប្រយោជន៍ដល់ជាតិ និងមានចំណងហែកកេរ្តិ៍ក្រុមអាក្បត់ជាតិមួយក្តាប់តូច ដែលមានសព្វថ្ងៃនេះឲ្យកូនស្គាល់ កុំឲ្យវាភ្ញាក់ កុំឲ្យវាធ្វើវង្វេងខួរក្បាលក្មេងជាតិ សាសនា ព្រះរាជបល្ល័ង្កទៅទៀត ជាពិសេសលោកចង់បំភ្លឺពលរដ្ឋខ្មែរ

www.elibraryofcambodia.org

ដាប់និពន្ធរួមឈាម ឲ្យបានយល់ ច្បាស់អំពីឫសកែវ និង
គោលបំណងរបស់អាត្យន្តជាតិទាំងនោះទៀតផង ។

លោក ល័ គុយហ្វួយ ពឹងឲ្យខ្ញុំធ្វើជូនបេះ ខ្ញុំសប្បាយ
ចិត្តណាស់ហាក់ដូចជាចាក់អារ៉ាង ( ពេលចូលឆ្នាំខ្មែរ )
ត្រូវបំលើកៅផ្ទៃតែម្តង ព្រោះខ្ញុំមានរឿងនេះស្រាប់ ហើយ
ខ្ញុំយល់ថា រឿងនេះអាចជាកញ្ចក់មួយយ៉ាងល្អសម្រាប់ឲ្យ
មិត្តអ្នកអានឆ្លុះពិចារណា ដោយសតម្ភាពគោលបំណង
មនោគមវិជ្ជារបស់ពួកអាខ្មែរក្បត់ជាតិ មួយក្តាប់តូចសព្វថ្ងៃ
នេះ ក៏ដូចជា សតម្ភាព គោលបំណងមនោគមវិជ្ជា
របស់អាចារ្យយ៉េមកស្ស្រះដែរ ក៏មិនចង់ឲ្យខ្មែរបានសុខទេ
ខ្ញុំក៏ជូនទៅលោកបោះពុម្ពផ្សាយនេះឡើង ។

កុសលផលបុណ្យដែលកើតពីសៀវភៅនេះសូមលើក
ថ្វាយចំពោះ :

- សម្តេចព្រះមាតាជាតិ

– សម្ដេចព្រះបិតាឯករាជជាតិ ព្រះនរោត្តម មហាវីរបណ្ឌិតយ៉ាងចំណាន ហ្មត់ចត់ព្យាបាលប្រទេសកម្ពុជាឲ្យបានជាសះស្បើយដោយឥតកំណាប់ ឲ្យបានសុខសម្បូណ៌សប្បាយរុងរឿង ។

– សូមជូនកុសលបំពោះវិញ្ញាណក្ខន្ធបងប្អូនរួមឈាមខ្មែរទាំងអស់ ដែលស្លាប់ដោយការទទួលទារុណកម្មពីពួកបក្សពួកអាណាចក្រ ប៉ុលពត - អៀងសារី - ខៀវសំផន ធ្វើបាបកាប់សម្លាប់យ៉ាងឃោរឃៅព្រៃផ្សៃ ។

– ខ្ញុំសូមជូនកុសលបំពោះបងប្អូនរួមជាតិដែលមានគំនិតការពារ ជាតិ សាសនា ព្រះរាជបល្ល័ង្កខ្មែរនៅក្រោមព្រះបារមីសម្ដេចឪខ្មែរមិនព្រមលក់ខ្លួនធ្វើជាខ្ញុំបរទេស ។

វ៉ែម ម៉ុង

# ១

## រាត្រីញាប់ញ័រ

រាត្រីមួយប្រមាណជាម៉ោង ១០ យប់ អ្នកស្រុកនៅក្នុងភូមិមេសប្រចណ្ឌតាំងពីល្ងាច ចូលនិទ្រាលង់លក់ស្ងាត់ជ្រាប ។

រាត្រីនោះពពកខ្មៅដាសងងឹតពាសពេញផ្ទៃមេឃបាំងទាំងព្រះច័ន្ទនិងពន្លឺផ្កាយបាត់សូន្យអស់ ។ រីឯវាយោក៏ស្ងប់ឈឹង ស្លឹកឈើទាំងឡាយស្ងៀមតែបន្តិចក៏គ្មានកំរើកសោះ ប្លែកខុសអស់រាត្រីមុនៗ ។

នៅចុងភូមិនេះមានផ្ទះទៀមមួយខ្នង សង់ឃ្លាតពីគេបន្តិច ផ្ទះនោះចាស់ទ្រុឌទ្រោមណាស់ទៅហើយ ដំបូលប្រកស្លឹក ជញ្ជាំងក្តាស់ផ្ទិតដោយជំរៀកឬស្សី ។ ទ័ល្មាមុខផ្ទះមានគ្រែកញ្ចាស់មួយតាំងនៅក្រោមដើមដូងមួយដើម ដែលមានកំពស់ទាបល្មមណាតមែកសាខា ។

ពូជន៍ជាម្ចាស់ផ្ទះនោះ ដោយស្ទះស្លាប់ពេកដេកមិនលក់ចក់មិនល្ហើយ ក៏បើកទ្វារចេញមកសំកន្តលំហែកាយលើគ្រែខាងក្រៅ គាត់ដេកសន្ធឹងសន្ធៃ ដៃម្ខាងគងថ្ងាស ដៃម្ខាងទៀតកាន់ក្រមាបក់បោក គ្រវែងគ្រវាត់ឲ្យមានខ្យល់លំ ហើយគ្រាណ ៗ ភ្នែកគាត់ចាំងឆ្ងូសំឡឹងយាំងមុតមើលទៅលើមេឃ យូរ ៗ ឮសូរផ្គរផ្ហើមធំម្តង ៗ ហាក់ដូចជាគាត់កំពង់គិតខ្វល់ខ្វាយ ឬក៏កំពង់ព្រួយលំបាកចិត្តពីរឿងអ្វីមួយ ៗ បន្តិចក្រោយមកស្រាប់តែឮ សម្រែកក្មេងស្រីម្នាក់ស្រែកនៅក្នុងផ្ទះនោះថា ៖

– ម៉ែ . . . ម៉ែ . . . ម៉ែអើយ ៗ ម៉ែ . . .

ម៉ែ . , . បន្ទាប់មកទៀតស្រែកខ្លាំងឡើងៗ ហើយយំ

កំសួញខ្សួរខ្សៀគណោបគង្ហ :

– ម៉ែ . . . អើយ . . . យកកូនទៅផង . .

យកកូនទៅផង . . . ម៉ែ . . . ម៉ែ . . . ម៉ែ . . .

ម៉ែ . . . ។

ពូផង់ឮកូនស្រែកដូច្នោះ គាត់ស្ទុះក្រោកឡើងពីគ្រែគេចូល ទៅក្នុងផ្ទះយ៉ាងលឿន ៗ លុះទៅដល់ឃើញកូនកំពង់អង្គុយ ប្រឹង ៗ យំញ័រមាត់ញ័របបូរ ទឹកភ្នែកហូរហាម ៗ គាត់សួរថា :

- ប៉ុប្ញា ! ហ៎យ៉ាងម៉េចហ្នឹងកូនស្រីៗ ពូផងសួរបណ្តើរ ជូតទឹកភ្នែកឲ្យកូនបណ្តើរ ហើយផ្តល់ឲ្យផងទៅវិញ ព្រម ទាំងលួងលោមសួរផងទៀត :

– ប៉ុប្ញា ! កូនស្រែកហៅម្តាយធ្វើអ្វី ? ម្តាយកូនឯង ក៏ . . . គេនាំទៅកូនស្រី គេនាំទៅ . . . ។

ទោះបីពូផង់ខំលួងលោមយ៉ាងណា ក៏នាងបុប្ផាមិនព្រមដេកដែរ ។ នាងនៅតែស្រែកហៅម្ដាយខ្សឹកៗ ធ្វើមាត់ម្រួច ។ រើបរះខ្លួនប្រេងប្រងាងតើតតើង ដៃក្ដាប់ជាប់ ភ្នែកសំឡឹងភ្លែតមើលទៅដំបូលផ្ទះ ផ្លូនមើលទៅសសរទ្រូង ផ្លូនមើលទៅបំណាងផ្ទះមិនព្រមពព្រិច ម្ដងសើចម្ដងយំ ៗ ឃើញកូនមានហេតុចំឡែកបែបនោះ ពូផង់ភ័យញ័ររំភែង កង្វល់គណនិតកូនខ្លោចចិត្តគ្មានអ្វីប្រៀប ។ ទឹកភ្នែកគាត់ហូរចេញមកព្រោក ។ ដែលធ្លាក់ស្រក់តក់ៗ ពូក៏សត់ដើរទៅយកអង្ករបានមួយក្ដាប់ រួចយកមកដាក់សម្រួចក្បែណលើខ្លួននាងបុប្ផាបីដងនិយាយទាំងកាត់សួលថា ៖

— ខ្មោចមែ៉ហើយ ! បើខ្មោចមែ៉ឯងចែកឋានទៅហើយ កុំមកធ្វើបាបកូនអញ្ជឹង ថ្ងៃក្រោយកុំមកធ្វើបាបកូនអញ្ជឹងទៀតណា៎ បើខ្មោចមែ៉ឯងឃ្លានចំណីអាហារ អញសែនឱ្យស៊ី មួយ . . . ពីរ . . . បី . . . បេរទៅ ៗ

និយាយរួចគាត់ប្រាប់អ្នករហាលទៅខាងក្រៅផ្ទះ ។ ពេលនោះនាងបុប្ផាអនចាប់ស្រែក ។ បន្តិចក្រោយមកគាត់ដេកលក់ទៅវិញ ។

ឃើញកូនដេកលក់ ពូផង់ក៏ចេញមកលំហែកាយលើគ្រែកញ្ចាស់ខាងក្រៅម្ដងទៀត ។ គាត់ទើបនឹងប្រុសខ្លួនដល់ទៀបស្រាប់តែឮសូរជ្រុកផ្អើល សូរក្ដពេសស្រុហ៊ឹងអឹកង ។ ពូពោះម៉ាយសង្ស័យពេក គាត់ពិនិត្យមើលទៅឃើញមានស្រមោលមនុស្សមួយហូតទៅស្នង ១ កំពុងភាយគាត់ខ្ទុំផ្ទះ ។ ពូផង់ស្លុតស្មារតីកកលគិតអ្វីមិនលេច ព្រោះយល់ជាក់ជាប្រាកដជាក្រុមចោរព្រៃ ដែលជាក្រុមយ៉ាងសាហាវ ។ គាត់ធ្វើក្បាលនឹងដើ ១ លោះលើគ្រែ ។ ដោយភ័យពេកក៏ស្ទុះចូលទៅពួននៅក្រោមគ្រែពោរពើតយ៉ាង ១ ខ្លួនប្រាណញ័រដូចកូនសត្វ ចង់រត់បន្តិច ចង់ក្រោកបន្តិច ចង់ក្រាបបន្តិច ព្រាសព្រាលដូចមាន់រកពងៗ

ស្រមោលមនុស្សកាន់តែខិតចូលមកជិតបន្តិចម្តង ៗ ពូផង់ភ័យកាន់តែខ្លាំងឡើង ៗ ព្រលឹងទើរហុងសក់ គាត់គិតក្នុងចិត្តថា "ដល់តែអញស្លាប់ក្នុងពេលនេះហើយតើ ឱ ! លោកឪពុកអ្នកម្តាយដ៏មានគុណអើយ សូមជួយកូនផង កូនស្លាប់ក្នុងពេលនេះហើយ" ។ គិតចប់ពូផង់រត់ចេញពីក្រោមគ្រែឈើ រួចរត់យ៉ាងលឿនហោលសំដៅចុះទឹកទន្លេ ប្រញាប់ហែលឆ្លងទៅត្រើយនាយ ។

ពួកចោរឃើញមនុស្សរត់ដូច្នោះ ក៏បាញ់កាំភ្លើងបីបួនគ្រាប់ផ្តក់សម្រង់ទៅ តែក៏មិននឹកស្មានថាពូផង់ជាអ្នករត់ទេ ក៏នឹកស្មានថាអ្នកដទៃរត់ទៅវិញ ។ ពេលនោះបើប្រសិនជាពួកចោរដឹងថាពូផង់វិញ មិនដឹងជាតាមទៅធ្វើបាបយ៉ាងណាទេ ។

គួរអនិច្ចាណាស់ គ្រាន់តែសូរកាំភ្លើងលាន់ផ្ទួង ៗ ភ្លាម ពូផង់ស្រែកគួរឲ្យខ្លោចផ្សា

— ស្អុយ ! ស្អុយ ៖ ... ! ៗ គាត់ស្រែកបាន តែប៉ុណ្ណោះ មាត់ក៏ស្ងាត់ឈឹង ៗ

ពួកចោរកំណាច ក៏នាំគ្នាសើចក្អាកក្អាយដោយនឹក ស្មានថាគេស្លាប់នឹងគ្រាប់កាំភ្លើងរបស់ខ្លួន ៗ បន្ទាប់មក ក៏នាំគ្នាចូលសំរុកទៅក្នុងផ្ទះភ្លាម ៗ លុះរកតួអង្គមិន ឃើញក៏នាំគ្នាចោមរោមនាងបុប្ផា ដែលកំពុងដេកពាំងកន្ទប ខ្ទប់ដៃញ័ររន្ធត់ដូចកូនសត្វ ៗ

ក្នុងចំណោមពួកចោរហោរហាខ្មៅទាំងប៉ុន្មាន មានម្នាក់ សម្បុរសណ្ដែកបាយ មាឌតូចល្អិតទេ តែកាចសាហាវ ជាងគេ ៗ សំដីក៏និយាយទៅរកចោរទាំងអស់សុទ្ធតែជា ពាក្យគា ... មីង ៗ ក៏សួរនាងបុប្ផាថា ៖

— នែ ... មីនេះ គាត់ទៅណាហើយ ?

បុប្ផាព្រឺរោមស្ទើរតែភ័យខ្លាំងឡើង ៗ គ្មានពាក្យ អ្វីឆ្លើយតបទេ ព្រាបផាន់ផាប់ ៗ ក៏សួរម្ដងទៀត ៖

- សាផង់នៅណាហើយ ? ហាងឯងកូនសាផង់ឬ?

សំនួរលើកទីពីរនេះ បុប្ផាក្រោកឡើងអង្គុយ មុខឈ្ងោកជ្រប់មិនហ៊ានមើលទេ ធ្វើក្បាលងើងើ ៗ បបេមាត់ឡើងស្វាំង ដៃគេះក្រចក ជួនគេះក្បាល ហើយស្រែកយំហោផ្ទុក ៗ

សាមោហាឃើញដូច្នោះ យល់ចិត្តក្មេងជាក់ក៏យំហើយបានជាមិនឆ្លើយ ទើបកែប្រែពាក្យសំដីលួងលោមវិញ

- នាង ! ប្រាប់ពូមកមើល សាផង់នៅណាហើយ ? ប្រាប់ពូមក ពូឲ្យនំញាំ ហើយពូឲ្យលុយចាយទៀតផង...

ដោយហេតុតែនាងនៅក្មេងល្ងង់ ការលួងពាក្យល្អលោមផ្អែមល្ហែមហើយឮថាគេឲ្យនំស៊ី ឲ្យលុយចាយ នាងក៏ផ្អាកយំ ហ៊ានលបមើលមុខគេម្ដង ១ ផង រួចងាប់ចង្គិចដោយប្រាប់ទៅគេវិញ

www.elibraryofcambodia.org

- ខ្ញុំ . . អត . . , ដឹង . . . ទេ . . . ពូ...
ខ្ញុំដេកលក់ដែរ ខ្ញុំប្រហែលជាគាត់ទៅលេងផ្ទះអ៊ុំខ្ញុំក៏មិនដឹង ព្រោះគាត់ឧស្សាហ៍ទៅលេងផ្ទះអ៊ុំខ្ញុំណាស់ ឥឡូវពូចាំខ្ញុំមួយភ្លែត ខ្ញុំទៅហៅគាត់ឲ្យ . . ។

- អេ . . . ទៅហៅឲ្យលឿនឡើង ហើយប្រញាប់ត្រឡប់មកវិញណា៎ ពូឲ្យនំញ៉ាំក្លាម . . .

ឆានបុប្ផារត់ចេញពីផ្ទះទាំងងងឹតតើមសំដៅទៅផ្ទះម្ដាយធំបំណង់ទៅរកហៅឪពុក ។ គ្រាន់តែបុប្ផាចេញផុតភ្លាម អាមេហោរដាក់កំហិតដល់កូនហោរទាំងអស់គ្នាថា ៖

- នែរ៉ឺ . . . ពួកអាឯងចាប់អាផន់ឲ្យបាន តែកាលណាវារត់រួច អាឯងទាំងអស់គ្នាត្រូវមានទោសដល់ជីវិត ឮទេ ?

- ប្របាទ ..ពានព្រោស (កូនហោរឆ្លើយព្រមគ្នា)។

www.elibraryofcambodia.org

កូនក្រីនោះ ទោះបីយប់ជ្រៅណាស់ទៅហើយក៏ដោយ មនុស្សនៅក្នុងភូមិមេសប្រច័ណ្ឌទាំងប៉ុន្មាន សូម្បីតែកូនក្មេងក៏ភ្ញាក់រឭកគ្រប់ ៗ គ្នាដែរ ព្រោះឮសូរសន្ទឹកកាំភ្លើងដែលពួកគាហោរបាញ់ ៗ ជនជាម្ចាស់ផ្ទះនិមួយ ៗ ខំរៀបចំខ្ចប់ ខំប្រមូលហិប ប្រមូលទ្រព្យសម្បត្តិល្អ ៗ កាន់ជាប់នឹងខ្លួនប្រុងប្រៀបគេចចេញពីផ្ទះទៅពួនដោយស្ងួតព្រៃជិតខាង ៗ

នាងបុប្ផាទៅដល់ផ្ទះម្តាយធំភ្លាម ទាំងអស់គ្នាក្នុងផ្ទះគេភ្ញាក់ខ្លួនព្រើត ហើយនិយាយទាំងភិតភ័យថា :

– យីព្រះអើយ ! មេចក៏ហ៊ានដើរមកអញ្ចឹង មិនខ្លាចកាំភ្លើងទេបុប្ផា ?

កុំតែជាម្តាយធំស្រែក ហើយស្ទុះមកចាប់ដៃទាញទៅឲ្យពួនជាមួយនឹងគាត់ ៗ តែនាងបុប្ផាមិនព្រមទៅពួនតាមទេ នាងធ្វើព្រងើយគ្មានខ្លាចអ្វីសោះ ៗ កុំ

www.elibraryofcambodia.org

ផែក៏គិតរកឲ្យឃ្លងទៀត ៖

— ម៉េចមិនព្រមទៅតួនបុណ្យ មិនខ្លាចស្លាប់ទេឬ ?

— ទេ ( តាងបុណ្យគប ) ខ្ញុំមកហៅឪ គេប្រើឲ្យមក ហៅឪខ្ញុំណាក៏ស៊ុ . . .

— អាណាឲ្យហៅ ?

— បាស់ . . . ខ្ញុំមិនស្គាល់ផង ណោះតួស៊ីគេខ្ញុំ ស្លៀកពាក់ខ្មៅ ៗ កាន់កាំភ្លើង មានតួខ្លះទៀតកាន់កាំបិតផង . . .

— អ៊ូ . . . ស្លៀកពាក់ខ្មៅ មានកាំភ្លើង មានកាំបិតផង យ៉ើ . . . មិនស្រួលទេកូយ រត់ទៅពួនភ្លាមទៀង ពិតជាចោរព្រៃហើយ ពួកនោះសុទ្ធមនុស្សចាំងរស់ កាប់សម្លាប់គ្មានស្គាល់ប្រគូនកូនចៅអ្នកណាទេ រាប៊ូល មករែតបាប់មនុស្ស បង្ខំយកល្បុយតាក់ទៀតហើយកូយ រាប្រើឲ្យមកហៅឪពុកកូយឯង ដើម្បីយកទៅសម្លាប់ចោល ណាំ !

គុំផែនិយាយរួចដឹកដៃបុប្ផារត់ទៅពួនកូនជង្រុកស្រូវ ភ្លាម ៗ នាងបុប្ផាដោយព្រួយណាយផងនិយាយថាពួកនោះស៊ី មនុស្សទាំងរស់ ហើយនិយាយដោយសំឡេងញ័ររាទៀត នឹកក៏ភ័យ តាមក្មួចមុខការដែលហោរប្រើអស់ ហើយរត់ទៅ ពួនក្រោមស្រឡាបកូនជង្រុកស្រូវ ៗ

បណ្ដាអ្នកពួនទាំងប៉ុន្មាន នាងវណ្ណាជាកូនស្រីរបស់ គុំផែក៏ភ័យណាស់ដែរ ៗ កាលឃើញបុប្ផាចូលទៅ ដល់ក៏ស្ទុះមកឱបនាងជាប់ ព្រោះក្មេងទាំងពីរនាក់នេះ ស្រឡាញ់គ្នាណាស់ ៗ

ចំណែកពួកចោរដែលពួនចាំចាប់ពួកផងនោះ រាំចាំ យូរ ៗ ទៅ មិនឃើញពួកផងមកសោះ ហើយបាត់ទាំង អស់ឲ្យទៅតាមហៅទៀតផង រកឃើញឈរក្មេងផ្លូងទាំង ១ ម្ដងទៀត ព្រមទាំងនាំគ្នាដុតផ្ទះពួកផងចោលឥតត្រាប្រណី ៗ ភ្លើងក៏ឆេះសន្ធោសន្ធៅក្រពេញទាំងភូមិ ផ្ទះក្មេងប៉ោះប៉ោរ

គ្រាន់ព្រោះតែលើវេហាស៍ ។

ផ្ទះដែលសង់ដោយស្លឹកខឹងដំបៀកឬស្សីជងឯណា នឹងព្រះអគ្គី ? នេះតែមួយស្របក់ប៉ុណ្ណោះ ក៏ស្ទុះឆេះអស់រលីងទៅ ។ ពេលនោះគេឮតែសូរមាត់ពួកចោរស្រែកជេរតួផង់ថា:

– អាផង់ អាក្បត់ជាតិ អាឯងហ៊ានឲ្យបាយពួកឃាក់ផង់ស៊ី អាផង់អាក្បត់ជាតិ ។ មានអាខ្លះទៀតស្រែកប្រកាសប្រាប់អ្នកស្រុកថា:

– សូមអ្នកកាល់គ្នា កុំយកគម្រាប់តាមអាផង់ឲ្យសោះ អាផង់ក់ខួរក្បាលឃាក់ផង់ យើងស្អប់ណាស់អាណាខួរក្បាលឃាក់ផង់ អកណាក៏ដោយតែកាលណាយើងជួប យើងសម្លាប់ចោលឲ្យអស់មួយពូជ យើងជាក្រុមឥស្សរៈ អាចារ្យយ៉េអ្នកស្នេហាជាតិ ។

ពួកអាចារ្យយ៉េទាំងនោះ ស្រែកឃោសនាប្រាប់

www.elibraryofcambodia.org

អ្នកស្រុករួចក៏បាញ់កាំភ្លើងបីបួនគ្រាប់ឡើងទៅលើ ហើយនាំគ្នាស្រែកហ៊ោយកជ័យជំនះ ទើបនាំគ្នាចូលទៅក្នុងព្រៃវិញបាត់អស់ទៅ ។

អ្នកស្រុកដឹងថា ពួកឃាតកររួចចូលព្រៃបាត់អស់ហើយនោះ ក៏នាំគ្នាទៅមើលផ្ទះដែលឆេះយ៉ាងកកកុញ ។ ទាំងអស់គ្នាគាំងគិតតូចចិត្តណាស់ ទឹកជាប្រពន្ធទើបនឹងស្លាប់ថ្មីៗ ឥឡូវផ្ទះសម្បែងទ្រព្យសម្បត្តិភ្លើងឆេះអស់ទៅទៀត ។ ខណៈនោះអ៊ុំផែងឈ្មោះខ្ទួនជាប្តី បាននាំនាងបុប្ផាឧងនាងវណ្ណាទៅមើលទីនេះដែរ ។ គ្រាន់តែឃើញផ្ទះក្លាយទៅជាផេះភ្លាមនោះ បុប្ផាធ្លាក់ថ្លើមក្តុកស្រែកហៅគេផុតតក់ក្តៅ ហើយយំសោកឡោកខ្ទួនជួយឆក ។

អ៊ុំផែងពិបាកចិត្តខ្លាំងណាស់ បាត់តូចធំជាខ្ទួនម៉េចដឹងជាទៅណា ? ផ្ទះសម្បែងទ្រព្យសម្បត្តិកភ្លើងឆេះ

អស់ ឃើញតែនាងបុប្ផាជាតិយយំសោកទោកព្រោណ
កណ្ដោចកណ្ដិនតែម្នាក់ឯង ។ ទឹកភ្នែកគាត់ហូរជ្រោក
ជ្រាល់ ស្រែកយំខ្សួញថាម៉ែចម៉ឹនកើត ដោយគាត់ស្មូលដើម
ទ្រូងតេកណាស់ ។

ចំណែកខ្លួនជាប្ដីអ៊ីវិញ ពិតមែនតែដឹងយល់ការនោះ
តែនិយាយមិនកើត ព្រោះគាត់គហើយថ្លង់ទៀតផង ។
គាត់ឈរមើលគេធ្វើភ្នែកក្នុះ ៗ យូរ ៗ គាត់ធ្វើជើងធ្វើដៃ
ជាសញ្ញាសួរគេឯងព្រមទាំងស្រែកព្រអឺអូ ៗ ៗ តែគ្មាន
នរណាចេះភាសាគាត់ឡើយ ។

អ្នកស្រុកអ្នកភូមិញាតិមិត្រជិតខាងនាំគ្នាជំនុំកព្វផង ។
អ្នកខ្លះថាគាបារ្សយចាប់យកទៅព្រៃ ហិតយកព្រាក
ទៅលួស ។ ខ្លះទៀតថាពួផងគៀសខ្លួនបាត់ទៅហើយ
គង់តែមកវិញជាពុំខាន ។ ការជជែកគ្នានោះមិនជាប់
ស្រេចសោះ ព្រោះទាំងអស់គ្នា គ្មាននរណាម្នាក់ដឹងការ

ពិតសោះ ជាដែកគ្នាតាមតែយោរស្មានរៀង ៗ ខ្លួន ។

គាសូរនាងបុប្ផាណាស់ ម្តាយទើបនឹងស្លាប់ទៅថ្មី ៗ ឪពុកក៏ព្រាត់បាត់ទៅទៀត ផ្ទះក៏ឆេះអស់រលីង ។ នាងយំសោកឥតស្រាកស្រាន្តឡើយ ។ ទោះមាមីងជិតខាងលួងលោមយ៉ាងណាក៏នៅតែយំស្រែករហៅរកឪពុកក្តុង ៗ ។ គុំផាកាលដឹងថាបុប្ផាមិនព្រមបាត់យំ មិនព្រមទៅដេកតាមគាត់នោះ គាត់ក៏កុហកថា:

— បុប្ផាក្មួយ ! ទៅគេងផ្ទះពុំសិនទៅ បន្តិចទៀតឪក្មួយឯងវាមកវិញហើយ ផលវាមកវាចូលផ្ទះពុំមុន តាផង វាមិនទៅណាចោលក្មួយឯងទេ យ៉ាងយូរណាស់ព្រឹកឡើងវាមកវិញហើយ ។

ឮម្តាយធំនិយាយដូច្នោះ បុប្ផាក៏សុខចិត្តទៅតាម ។ លុះទៅដល់ផ្ទះដោយមានអស់កម្លាំងពេក ហើយងុយដេកផងនោះ ក៏ដេកលង់លក់ក្នុងទ្រូងជាមួយនាងណាទៅ ។

# ៣

## ការស្វែងរកពូជផង

ព្រឹកឡើងភ្លឺស្រាង ៗ ប៉ុណ្ណោះ ភ្ញាក់ពីដំណេកមុនគេ ៗ ឆាន់ក្រោកឡើងភ្លាម មិនរវល់លុបមុខលាងមាត់ទេ គិតតែពីរយកគន់កេផុត ៗ ល្មុះគេមិនឃើញ ឆាន់ចុះពីលើផ្ទះម្តាយធំ ត្រឡប់ទៅតន្ទ្វីផ្ទះនេះវិញ ៗ ឆាន់អង្គុយសំកុចសំកាំងលើគំនរផេះយ៉ាងសោកស្តាយទ្រព្យសម្បត្តិដែលឆេះអស់នោះ ហើយអណ្តឺតអណ្តកតបកបថា :

ឱ ! អើយ ! ទៅណាហើយ ម៉ែបមិនយកខ្ញុំទៅផង ឬមួយឪស្អប់ខ្ញុំ ? កាលដើមឡើយ កូនបានម៉ែបានឪជាបង្គោល ម៉ែស្លាប់ទៅឪទៅណាបាត់ទៀតតើ

ឲ្យកូនទៅពឹងលើនរណា ? ឲ្យកូនសង្ឃឹមលើអ្វី ? បើ ទ្រព្យសម្បត្តិ ផ្ទះសម្បែងរបស់យើងក៏ឆេះអស់រលីង យ៉ាងនេះ ? ។

នាងយំរៀបរាប់បណ្ដើរ ដើររកកាយផេះបណ្ដើរ ប្រាថ្នា ក្រែងមានសល់របស់អ្វី និងរើសយកទុកធ្វើជាកេរ្តិ៍តទៅ ទៀត តែគ្មានអ្វីឲ្យនាងរើសយកទុកសោះ មានតែកំទេច ធ្យូង អំបែងដបអំបែងចានតែប៉ុណ្ណោះឯង ម្ល៉ោះហើយ បុប្ផាអង្គុយសំកុកតែឯងក្នុងស្រងេះស្រងោចបំផុតក្នុងចិត្ត ។

ចំណែកគុំផៃវិញ ក្រោកពីសម្រាន្តភ្លាម គាត់ខឹង ស្មានថានាងបុប្ផាកំពុងដេកនៅឡើយទេ ។ ហើយដោយ ភ្ញាក់ឡើងឃើញថ្ងៃខ្ពស់ពេក គាត់មិនបានជាពិនិត្យមើលគន់ ឲ្យសព្វគ្រប់ ប្រញាប់ចាប់ក្អមទឹកមកកណ្ដៀក ចុះទៅទន្លេ ព្រោះថាដងទឹកយកមកដាំបាយ ។ លុះទៅដល់មាត់ច្រាំង ស្រាប់តែឃើញឈាមក្រហមឆ្អៅស្រក់ជិតជាប់នឹងដី គាត់ទ

www.elibraryofcambodia.org

ដើរតាមពិនិត្យមកតាំងពីមាត់ព្រាំងរហូតដល់មាត់ទឹក ឃើញក្រមាកញ្ចាស់មួយប្រឡាក់ឈាមស្រមក ៗ គាត់សង្ស័យពេកក៏លើកក្រមានោះពិនិត្យមើល ស្គាល់ជាក់ថាក្រមានោះជាក្រមារបស់ពូផនប្អូនរបស់គាត់ ៗ ពេលនោះអ៊ុំផៃស្ទុតស្មារតីធ្លាក់ក្រមាពីដៃ ដោយមានគំនិតយល់ថាក្រុមអាចារ្យយើ សម្លាប់ពូផនយកមកបោះចោលក្នុងទឹកទន្លេនោះ ៗ កាលដឹងខ្លួនឡើងវិញ អ៊ុំផៃស្រែកទ្រហោរយំយ៉ាងខ្លាំង បណ្តាលឲ្យអ្នកស្រុកភូមិ ផ្អើលតោឡោរត់ប្រសាចទៅមើល ៗ គាត់យំរៀបរាប់ប្រាប់គេថា :

- បងប្អូនទាំងអស់គ្នាជួយខ្ញុំផង តាផនស្លាប់ទៅហើយ យប់មិញពួកអាចារ្យយើសម្លាប់យកមកបោះចោលក្នុងទន្លេនេះ មើលចុះនេះក្រមារបស់វាសុទ្ធតែឈាមជួយខ្ញុំផង ជួយរកខ្មោចវាយកមកធ្វើបុណ្យ ៖ - ·

អ្នកស្រុកឃើញដូច្នោះក៏ជឿតាមយល់ថាពូផនស្លាប់

www.elibraryofcambodia.org

ផែន ទើបនាំគ្នាចុះទៅមុជកករែកខ្លោចបពួជទឹកកកពុញពេញខ្លួន ។

អ៊ុំផែតតែពីកំពង់ចិតទៅផ្ទះវិញបំណងប្រាប់នាងបុប្ផាឲ្យបានដឹង ។ ទៅដល់ផ្ទះបើកមុងឡើងរកបុប្ផាមិនឃើញ គាត់ក៏ភ័យមួយជាន់ថែមទៀត ។ សួរប្ដីសួរនាងវណ្ណក៏គ្មាននរណាដឹងថានាងបុប្ផាទៅណាឡើយ ។ គាត់ស្ទុះស្ទៅស្រែកហៅរកបុប្ផាហើយតែទៅរកមើលឯកំពង់ចិតវិញ ក៏មិនឃើញ ។ លុះតែឡើងទៅមើលឯជង្រុកផ្ទះនេះទើបឃើញនាងបុប្ផាកំពុងយំសោកអន្ទងអន្ទោចនោះ អ៊ុំផែតសួរគាត់ស្ទើរតែនិយាយមិនចេញ ។ មួយស្ទុះក្រោយមក ទើបគាត់និយាយរួច ៖

— បុប្ផាកូនអើយ ! មកអង្គុយជិតអ៊ុំណេះវិញ ចុះកូនឯង . . . ស្លាប់ . . . បាត់ . . . ទៅហើយ ពួកអស្សុរៈគាចាបអើសម្លាប់យកទៅបោះចោល

ក្នុងទឹកទន្លេយប់មិញនេះ ។

គ្រាន់តែឮថាឪពុកស្លាប់ភ្លាម សាន់បុប្ផាស្រែកទ្រហោយំខ្លាំងឡើង ៗ ។ ស៊ីផៃក៏ដឹកដៃដើរទៅត្រើយនៅមាត់ប្រាំងមើលគេមុជរកខ្មោចទឹកទាំងយប់មកឆ្លុះបុណ្យ ៗ ទាំងពីរនាក់ម្ដាយជាំទឹកភ្នែកស្ដាយបង្ហូរទឹកភ្នែកហាមមើលទៅគួរឲ្យអាណោចខ្លោចចិត្ត ។

ពួកទាហានជូនមែន តែគាត់យល់ករុណាស់ ស្ងួរទេ ៗ ៗ តាមការសារបស់គាត់រួចក៏លោតបុះទៅក្នុងទឹក ជួយមុជរកខ្មោចពួកសំពាំងនោះដែរ ។ គេនាំគ្នារកតាំងពីព្រឹករហូតដល់ថ្ងៃត្រង់ជ្រេរនៅតែរកមិនឃើញទៀត ។ ដោយអស់សង្ឃឹមនឹងរកទៅទៀតនោះ បន្ទាប់មកគេក៏នាំគ្នាឈប់រក ។ ស៊ីផៃទន់ជើងទន់ដៃ នាំបុប្ផាឡើងមកផ្ទះវិញទាំងទុក្ខក្រៀមក្រំ ។

ល្ងាចនោះ នៅមុខផ្ទះស៊ីផៃមានដោតទង់ស (ទង់

ព្រលឹង) ហើយភ្លេងពិណពាទ្យបន្លឺបទយ៉ាងស្រងេះស្រងោច ជូនដំណើរខ្មោចពួកផង ៗ ពួកស្រីអ្នកភូមិនាំគ្នាទៅចូលបុណ្យ ខ្លះចូលជាអង្ករ លុយកាក់ ត្រីសាច់ ចានម្ហូប ម្លូស្លាបារីជាហូរហែរ ៗ សុំតែបានធ្វើបុណ្យបញ្ជូនកុសលឲ្យខ្មោចពួកផងតាមគន្លងប្រពៃណីព្រះពុទ្ធសាសនា . . . ។

ឯបុប្ផាក្មេងកំព្រាវិញ តែម្នាក់ណា ក៏ឃើញនាងយំសោកខឹងស្រែកហៅរកឪពុកដែរ រៀលតែពេលនាងដេកលក់ ៗ លុះភ្ញាក់ពីដំណេកឡើងយំរកឪពុកទៀត យំគ្មានឈប់ឈរ ៗ រំលងមកច្រើនថ្ងៃហើយក៏នៅតែនឹករលឹកជួនស្រម័យឃើញឪពុកនាងនៅធ្វើកែកជាខ្ទិច ជួនដេកយល់សប្ដិឃើញពាំងកណ្ដាលអធ្រាត្រកំស័ងមានដែរ ៗ

គួរស្ដាយណាស់ ! មានពេលព្រឹកមួយនោះ នាងក៏ពន់ចូលភូមិទឹកជញ្ជូនដាក់ពាង ស្រាប់តែក្រឡេកទៅឃើញបុរសម្នាក់កំពុងដើរតាមផ្លូវថ្នល់ បុប្ផាស្មានថាបុរស

www.elibraryofcambodia.org

នោះជាឧពុក ក៏ចាំស្រែកហៅ ៗ បុរសនោះឯងដោយ គាត់មិនបានដោយចាប់អារម្មណ៍ថាមាននរណាហៅខ្លួន ក៏បោះតែដើរទៅមុខ ៗ នាងបុប្ផាចាំស្រែកហៅ ហើយចាំប្រឹងតែទៅតាម ជ្រះក្លួមទឹកធ្លាក់តក់លើក្បាលពោះខ្លាយ ៗ លុះតាមទាន់ ស្រវាឱបបុរសនោះពីក្រោយជាប់រួចខ្សឹបថា :

– ឧ ! ឧទៅណាបាត់ពេលខ្ញុំ ឧអើយផ្ទះរបស់យើងភ្លើងឆេះអស់រលីងទៅហើយ សព្វថ្ងៃខ្ញុំទៅនៅជាមួយគុំផែងណេះទេ

បុរសអ្នកដំណើរនោះ កាលនាងបុប្ផាឱបពីក្រោយជាប់យ៉ាងរៀបរាប់ហៅគាត់ថាឧ ៗ នោះ គាត់ភ្ញាក់ខ្លួនព្រើតហើយឈរទ្រឹងអស់សំណើច រួចនិយាយទៅរកនាងថា :

– នាង ! . . . នាងច្រឡំហើយ ពូមិនមែនជាឧពុកនាងទេ ពូជាអ្នកដំណើរទេតើ ស្រុកពូនៅឆ្ងាយ

ណាស់ណាស់ . , . ៗ

ឮដំណើរនិយាយចប់គាត់ក៏ដើរចេញទៅ ៗ

នាងបុប្ផា កាលដឹងថាបុរសនោះមិនមែនជាឪពុក នាងអៀនខ្មាស់ជាអនេកទម្លាក់ខ្លួនចុះដល់ដីយំផ្កាប់ខ្លួន ព្រោណ ស្រណោះអាណិតជីវិតខ្លួនកាន់តែខ្លាំងឡើង ៗ លុះត្រាតែគុំផែនឹងនាងវណ្ណាយោហៅឡើងលើផ្ទះ ៗ

ដល់លើផ្ទះនាងនៅតួនយំសោកសំរក់ទឹកភ្នែកអន្ទងអន្លោចផែម្នាក់ឯងរៀងរៀងឥតញ៉ាំក្ដីបន្តិចទៀត ៗ

# ៣

## កំណិតអាចារ្យយី

ពីរោគពិក្សក្រោយមក ក្រុមអាចារ្យយីបានទៅនៅភាគស្រាកធ្វើបាបចាប់សម្លាប់ជាតិខ្មែរគ្នាឯង នៅម្តុំស្រុកត្បូងឃ្មុំ ដូច ស្នួល ស្រួលចំនួនពីរបីខែ ៗ បន្ទាប់មកទៀតក្រុមឥស្សាហារនេះបានលើកទ័ព ទៅសំចតនៅម្តុំខេត្តបិន ជីហែរ ព្រៃចបក្រោន ព្រៃកសណ្តែក ជួនកាលទៅដល់បុសខ្នុរ ស្ពឺ ស្ទឹងត្រង់ទៀតផង ៗ នៅទីសំចតនេះក្រុមអាចារ្យយីបានចាប់សម្លាប់មនុស្សរាប់មិនអស់ ដូចជាតខ្មែរដែលគាត់បានទៅសំចតមុន ១ ដែរ ហើយបាន

បំផ្លាញទ្រព្យសម្បត្តិផ្ទះសម្បែង នៅគ្រប់ ជ្រុង មាន ៣ របស់អ្នកស្រុកស្ទើរតែអស់ទាំងសល់ ។ ក្រៅពីនេះ អាចារ្យយើ ធ្វើបាបព្រះសង្ឃផុតវត្តអារាម ផុតគម្ពីរជាព្រះពុទ្ធសាសនា ដែលបោះពុម្ពជាសៀវភៅនោះចោលអស់ទៀត ។ ចំណែក ស្រីក្រមុំ ១ វិញក៏ត្រូវពួកចោរកំណាចនេះបំផ្លាញព្រហ្មចារីយ៍ទីងទីសម្លាប់ចោលអស់ច្រើននាក់ដែរ ។

ប្រមាណជា ១ ខែក្រោយមក អ្នកស្រុកតំបន់ ពារាំងភ្ញាក់ពីដេកព្រឹកទៀង ស្រាប់តែឃើញមានប្រកាស ធំ ១ បិទនៅតាមដើមឈើនិងតាមបង្គោលផ្ទះអ្នកស្រុក ដែលគេលួចលបបិទពីយប់មកនោះ ឃើញមានស៊ុំញ៉ែបោះ ត្រាបុិនមាត់បានគោមហើយមានសេចក្ដីប្រាប់ថា ៖

ធីជាតិការនៅព្រៃធំត្នុំផ្ទូជី

ប្រាប់មកអ្នកស្រុកកល់គ្នាឲ្យបានដឹង ។

យើងប្រធានអាចារ្យយ៉ើម៉េសស្សរះ កាប់មិនមុតផុត មិនឆេះបាញ់មិនចេញ មិនបាក់ ចេះបែងកាយ ជា

ទៅឆ្ងាយពីរបស់អ្នកកល់ន្លា សូមអ្នកកល់គានៅភូមិនេះ សង់កេងសំណាក់ពិសេសឲ្យយើងបានមួយ នៅខាងក្រៅភូមិនេះឲ្យជំនួលាយ កុំមានឲ្យសោះកន្ទុះវេលាថ្ងៃនេះដាក់ហិត ហើយត្រូវមានបាយទឹក ម្ហូបចំណីគ្រប់មុខនឹងស្រា សម្រាប់ឲ្យក្រុមយើងកុំឲ្យខ្វះខាត ។ ហើយសូមកុំភ្លេចប្រមូលប្រាក់ឲ្យបានចំនួនប៉ុន្មានរៀលឲ្យយើងផង ។ ពេលល្ងាចថ្ងៃនេះយើងទៅដល់សូមឲ្យហើយស្រេច កុំឲ្យខ្វះអីឲ្យសោះ ។ ម្យ៉ាងទៀតពេលយើងទៅដល់ ត្រូវអ្នកកល់ន្លាទាំងក្មេងចាស់ប្រុសស្រីទៅចាំស្តាប់យើង ធ្វើសេចក្តីថ្លែងការណ៍ . . . ។

បើអ្នកណាមួយមិនព្រមស្តាប់តាមបញ្ជារបស់យើងនេះទេ ឬមួយក៏គេចខ្លួន នោះយើងនឹងសម្លាប់ចោលមួយពូជ

ហត្ថលេខា

យើងប្រនាមតារ្យយ៍

www.elibraryofcambodia.org

អ្នកស្រុកឃើញសេចក្ដីប្រកាសនោះភ្លាម គ្មានអ្នកណាមួយហ៊ានគេចខ្លួនទេ គិតតែភិតភ័យឥតឧបមា នាំគ្នាទៅសង់រោងនៅខាងក្រៅភូមិតាមសេចក្ដីប្រកាសនោះ អ្នកខ្លះចេញស្លឹក អ្នកខ្លះចេញឫស្សី ឯខ្លះទៀតចេញឈើ នាំគ្នាធ្វើតែមួយព្រឹកប៉ុណ្ណោះ ក៏ហើយស្អាតសមរម្យឥតមានទាស់ ។ កាលធ្វើរោងរួចអ្នកខ្លះកាប់គោ ក្របី មាន់ ទា ជ្រូក ធ្វើម្ហូបយ៉ាងប្រណីត មាននំចំណីមានស្រា ទុកសម្រាំងសម្រាប់ជូនក្រុមអាចារ្យ ។

លុះដល់ពេលល្ងាចដូចបានកំណត់ ក្រុមអាចារ្យបានលើកគ្នាទៅដល់មែន ។ ហើយគេបានហៅហោមអាចារ្យដូចជាគេហៅអ្នកតាបំនៃរ ។ ទៅជិតដល់រោងសេនាជំនិតអាចារ្យម្នាក់ ភ្លឹកក៏ក្អើងដាក់អ្នកស្រុក ហើយស្រែកឡើងខ្លាំង ១ ថា :

– លោកធំអញ្ជើញមកដល់ហើយ អ្នកទាំងអស់គ្នា

ថ្វាយបង្គំ ក្រាប..,. ក្រាប សំពះ ... សំពះ តោះតែ កុំងើប អ្នកណាងើបខ្ញុំបាញ់បែកសន្ធុះក្បាល ...

អ្នកស្រុកទាំងអស់គ្នាធ្វើតាមគ្នានេះណាមួយហ៊ាន ជំទាស់ឡើយ ។ រំពេចនោះគេបារ្យយ៍ចូលទៅក្នុងភេទ ហើយឡើងអង្គុយតែងកែងលើគ្រែធម្មាសនៈ ដែលជាគ្រែ សម្រាប់ព្រះសង្ឃគង់ទេសនា នោះយ៉ាងថែនថេង ដោយ មានក្មេងស្រីក្រមុំរូបស្អាត ១៦ នាក់ អង្គុយអមម្ខាង ៣ នាក់ ចាំបក់ផ្លិតឲ្យគាត់ផង ។ បន្ទាប់មកអ្នកស្រុកលោកក្រោក បីម៉ឺនរៀលទៅជូនលោកធំ រួចលើកបាយសម្លនំចំណី ស្រាទៅជូនក្រុមនេះស៊ី ។ ដោយក្រុមនេះមានគ្នាច្រើន គេក ស៊ីងតែអ្នកស្រុកកំប៉ុងមិនចង់រួច ។ មួយៗទៀតក៏ស៊ីគាក្រក់ គេក ម្ហូបណាមិនសូវឆ្ងាញ់ក៏ចាក់ចានក៏យឆ្នាំងពេល តាមតែចិត្តកខិកឃើញ ។ គាខ្ទះស៊ី គាខ្ទះឈរយោម យួរ ។ ក៏ផ្ដាំសំអុតស៊ីឲ្យទៅយាម ឯអ្នកយាមឱ្យមតស៊ី

វិញម្ដង ។ ស៊ីផ្អែតមានកម្លាំងអាចារ្យយើបំពេញខ្លួន ប្រកាសថា:

- អ្នកកល់គ្នាស្គាល់ខ្ញុំទេ ? ខ្ញុំហ្នឹងហើយប្រធាន អាចារ្យយើមេធស្សរៈជាអ្នកធំខ្លាំងពូកែ ខ្ញុំមកនេះមាន បំណងចង់ដឹងអំពីវត្តអារាមក្នុងភូមិនេះ តើវត្តណាខ្លះដែល រៀនធម៌ប្រែ រៀនធម៌តាមសៀវភៅ សូមប្រាប់ខ្ញុំកុំលាក់?

ពេលនោះមានលោកតាមួយបំណាស់ជាងគេលើកដៃ ឡើងសំពះ រួចផ្ដើមប្រាប់អាចារ្យយើថា:

- បាទព្រះករុណាព្រះតេជគុណម្ចាស់ ភូមិនេះវត្តមាន ច្រើន តែវត្តដែលរៀនសូត្រធម៌ប្រែធម៌ថ្មី រៀនតាមសៀវ ភៅនោះមានតែវត្តមួយទេ គឺវត្តមេសប្របុណ្ណ ក្រៅពីវត្តនេះ គេនៅរៀនធម៌ចាស់មើលសាស្ត្រាបៃបបូរាណដដែល...

- ហាស . . . ហាស . . ហាស . . (អាចារ្យយើ សើចខ្លាំងស្រែកហ៊ោរួចលោតគាត់ហើយបញ្ឈូកក្បាល ) នែ . .

អាយក្ស ប្អូនឯងនាំគ្នា ១០ នាក់ទៅដុតសៀវភៅក្បួនច្បាប់គម្ពីរដីកា ដែលបោះពុម្ពជាសៀវភៅនៅវត្តនោះចោលឲ្យអស់ បើមានសាលារៀនត្រូវដុតសាលានោះចោលទៀតឬទេ ?

- ប្របាទម្ចាស់ ... ។

នាយយក្សទទួលបញ្ជារួចនាំគ្នា ១០ នាក់ ដើរតម្រង់ទៅកាន់វត្តមេសប្រច័ណ្ឌ ហើយឡើងទៅលើកុដិលោកគ្រូចៅអធិការ និងលោកគ្រូសូត្រ រើយកសៀវភៅ និងគម្ពីរព្រះពុទ្ធសាសនា ដែលបោះពុម្ពជាសៀវភៅនោះយកទៅដុតចោលអស់ ... ។

ចំណែកកាពារ្យយី នៅតែចាំខឹងក្នុងពេងលើគ្រែធម្មាសនៈនោះ ហើយសួរដេញដោលក្នុងស្រុកទៅទៀតៈ

អ្នកទាំងអស់គ្នាកុំលាក់ បើខ្ញុំសួរត្រូវតែប្រាប់ខ្ញុំ

www.elibraryofcambodia.org

ឲ្យគ្រន់ កូនកុហកខ្ញុំមិនបានទេ ប្រយ័ត្នខ្ញុំសម្លាប់ចោល ហើយអ្នកកល់គ្នានៅក្នុងភូមិនេះ មានដឹងថាអ្នកណា ជាបក្សពួកត្រូវជើងខឹងប៉ាក់ងដែរឬទេ ?

លោកតាម្នាក់នៅចំមុខអាចារ្យយ័នោះ ក៏ឆ្លើយឡើងភ្លាមថា:

- បាទប្រោស ! នៅភូមិនេះគ្មានអ្នកណាជាបក្សពួកឬត្រូវជើងខឹងប៉ាក់ងទេបាទ . . .

- ប្រាកដជាគ្មានមែនឬ ? ( អាចារ្យយ័សំឡក្សរូបហ្មត់ចេញមក ដែលមានឈាមមនុស្សប្រឡាក់ក្រហមឆ្អៅនោះ បង្អុលមុខអ្នកស្រុករូបស្គមស្គាំងកម្ពុជទៀត ) ប្រាកដជាគ្មានមែន ! កុំលាក់, អញដឹងអស់ហើយ ប្រយ័ត្នអញសម្លាប់ចោល . . , ត្រូវប្រាប់ឲ្យគ្រន់ .

អាចារ្យយ័ស្ទុះតែហក់ៗ ហើយបញ្ចេញជាមេក្មេះគ្មានអ្នកណាមួយឆ្លើយរួចសោះ គិតតែភិតភ័យ ៗ ដោយ

www.elibraryofcambodia.org

ត្រូវឆ្លើយតេក ព្រោះតែអាចារ្យយីធំប្រឡោតតួនឡើង ពេលផាវនោះវិលទៅត្រូវពោះកេណ្ឌាក់ មុតធ្លាយពីម្ខាងទៅម្ខាង រូបគាត់លើកបាទដាយបានសម្ដែរពេលវិលទៅត្រូវឆាក់យាយតាសម្លាក់ ដែលកំពុងអង្គុយសំពះញ៉ែទទេរ ផ្សែរនោះបាក់ធ្មេញបែកបបេមាត់ចេញឈាមហោម បានមួយទៀតពេលវិលទៅ ត្រូវចំក្បាលលោកតាអាចារ្យម្នាក់ ដោយក្បាលលោកតានោះទំពែកផង មើលទៅឃើញស្នាមមុតប្រហែលបន្ទុលដៃ ឈាមហូរសស្រាក់ ហើយអាចារ្យយីសំទុតឡើងតឆ្លើយតទៅទៀត :

— អញសួរត្រូវអ្នកកល់ឆ្នាំប្រាប់អញភ្លាម បើអ្នកកល់ឆ្នាំមិនប្រាប់ទេ មានតែអ្នកកល់ឆ្នាំជាបត្រូតព្រាកង ដូចេះអញនឹងសម្លាប់ពេលឡើអស់ . . .

អកស្រែកកាលអាចារ្យយីសំទុតតែតែក័យនិយាយលែងចេញ ។ ទទួលពេលនោះបន្ទាយានឡាយជុក

www.elibraryofcambodia.org

គម្ពីរដីកា ព្រះពុទ្ធសាសនា ឯវត្តមេ-សប្រចំណុះរូប ក៏ត្រឡប់មកផលវិញដែរ តាបារ្យយ៍ដាំពៅហ្វាយក៏ព្រើតស្មោះទៀត :

បន្ទុយានឡាយ(យក្ស)ត្រូវឯងចាប់ខ្លួនអ្នកស្រុកទាំងអស់គ្នានេះ តាមដែលឯងចូលចិត្តយកទៅសំឡេះចោល ហើយវះពោះយកថ្លើមវមកស្ងោស៊ីបញ្ចុះទេ ?

ពៅហ្វាយនិយាយចប់ បន្ទុយានឡាយចុះនោរោតរួបស្ទុះរឹងទៅចាប់គូសអ្នកស្រុក ដែលកំពុងអង្គុយសំរាកខ្លួនប្រាណញ៉ាំទទ្រើនរនោះឥតញយកទៅ ៗ នៅពេលកាសន្ធនោះ គ្មានអ្នកណាឆ្លើយប្រាប់តាបារ្យយ៍កើតទេ ម្នាក់ ៗ គិតតែភ័យខ្សើងស្វាំងមុខ ៗ ឯអ្នកដែលត្រូវគេចាប់យកទៅសម្លាប់នោះយំខ្លួញរអ៊ាំងទ្រហ៊ឹងអង្ករអន្ទ្រគេថា :

– លោកអើយ មេត្តាកុំសម្លាប់ខ្ញុំ ខ្ញុំមិនមែនបក្សពួក

បាក់ង៉ទេ កុំសម្លាប់ខ្ញុំ ខ្ញុំមានកូនច្រើននាក់ណាស់គ្នានៅតូចៗផង .. អាណិតមេត្តាកុំសម្លាប់ ឲ្យខ្ញុំធ្វើស៊ីកំភ្លើដែរ ..

— កុំស្តាប់វា (អាចារ្យយ៉ើស្រែកគំហកឡើង) យកវាទៅសំអេះទៅ យើងជាក្រុមអ្នកការពារមិនត្រូវអាណិតអ្នកណា មិនត្រូវខ្លាចអ្នកណាទេ ទើសមុខទើសមាត់ត្រូវតែសម្លាប់ចោលកុំត្រាប្រណី ,

បន្ទាយទាន់ឡាយ(យាក្ស)ក៏ទាញដៃមនុស្សស្លូតត្រង់ប៉ុន្មាននាក់នោះចូលទៅក្នុងព្រៃបាត់អស់ទៅ ។ ឯអ្នកដែលនៅសល់ប៉ុន្មាននាក់ក៏កើតកក់ភ័យមហិមាស្ទើរតែផុតដង្ហើម ខ្វះភ័យរហូតដល់លេបនោមលេបអាចម៍ទាំងមិនដឹងខ្លួនផង ។ ជាបន្ទាប់មកអាចារ្យយ៉ើសួរម្តងទៀត ។

— អាណាខ្លះជាបក្សពួកបាក់ង៉ អ្នករាល់គ្នាបើមិនប្រាប់យើងទេ ត្រូវតែស្លាប់ បើបងរស់ត្រូវតែប្រាប់ភ្លាម ..

លោកអាចារ្យម្នាក់ត្រូវគ្រាលខឹងតានសម្តី អាលក

www.elibraryofcambodia.org

តាឡូយើពេលនោះ ចាស់ក្រោកឡើងទាំងញើរញ័រសំពះ និយាយទាំងភិតភ័យថា :

— សូមលោកមេត្តាប្រោស អ្នកស្រុកនេះគ្មាននរណាជាបក្សពួក ៗ បាក់ឌីទេ ទាំងអស់គ្នាសុទ្ធតែជាតិខ្មែរស្លូតបាត បាក់ឌីដូចព្រះតេជគុណម្ចាស់ដែរ ក៏ប៉ុន្តែព្រះតេជគុណអើយ ! ធ្វើម្តេចបើបាក់ឌីវាចេះតែចូលមក បង្ខំបញ្ជា យើងមិនធ្វើតាមគេបាញ់សម្លាប់ចោល ហ៊ឺ . . ពិបាកណាស់

គតាឡូយើញលោកតារូបនេះ មានប្រសាសន៍ប្រាប់ផ្ទះ ធ្វើបែបព្រងើយហាក់ដូចជាមិនឮ ហើយសំឡក់ក្រញ៉ីសំឡឹងរំពៃមើលទៅអ្នកស្រុកគ្រប់ ៗ គ្នា ៗ យូរបន្តិចមក ស្រាប់តែបង្គាប់ទៅសេនាគាត់ថា :

— នែ! . . . ពួកសេនា ឯងយកពួកគប្រែតដែលយើងចាប់យកពីស្រុកខាងនោះមកនេះ យកទៅ

កាន់តែកាន់ជិតឈានឡើងញញើមញើម យើងខ្ញុំលទុភនាំពុក ដឹកនាំយកទៅទៀតទេ . . . .

អាសូរផុតទាំងនោះណាស់ ! ដឹងជាក្រុមអាហារយើងបាច់យកពីស្រុកណាមកទេ ម្នាក់ៗឃើញស្នាមជាំពេញទាំងខ្លួនប្រាណ ដៃត្រូវគេចងស្លាបសេក ពេលគេសុំបាយត្រូវគេបង្អត់ នាអង្គុយយំសោកភ័យ ខ្លះក៏ស្លាប់ៗ អាហារយើប្រាប់ប្អូនពួកសេនានោះទាញដៃ ពួកអ្នកអស់ទាំងប៉ុន្មាននាក់នោះចេញទៅ ទោះគ្នាក្រញាំស្រែកយំអង្វរលន់តួយ៉ាងណាក៏ដោយ មេក្បាលអាហារយើមិនព្រមអើពើ និងស្ដាប់ដែរ គិតតែដាក់ទាត់គ្នាថែមទៀតៗ លុះអ្នកទាំងទៅដល់ខាងក្រៅរោង ដេញឲ្យអ្នកស្លូតត្រង់ទាំងប៉ុន្មាននាក់នោះឈរតំរបគ្នា ហើយស្រែកបង្គាប់ថា :

– ការនាធម៌ទៅ . . . អាឯងត្រូវទៅនៅឋានប្រេតមួន . . .

និយាយចប់សេនាតាចារ្យយ៍ លើកកាំបិតកកុកតាតិច អ្នកស្លូតត្រង់ហ៊ាក់ . . . ហ៊ាក់ . . ដាច់កស់ក្បាល តាខ្វះ ឃើញក្បាលគ្នាធ្លាក់ដល់ដីក៏យកជើងទាត់លេង ដូចជាគេទាត់បាល់ តាខ្វះទៀតស្ទុះទៅហូតឈាមមែនទែន ៗ តាចារ្យយ៍ឃើញដូច្នោះសើចក្អាកក្អាយ សប្បាយចិត្តណាស់ ហើយនិយាយថា :

– ល្អ . . . ល្អ . . . ល្អណាកូន . . . ធ្វើអញ្ចឹងបានហៅថាកូនចៅរបស់អញ... (សរសើរកូនចៅគាត់រួចក៏ស្រែកប្រាប់គេទៅទៀត) ហៅគ្នាយើងមកឲ្យជួបជុំគ្នា រៀបចំដំណើរហើយ ពួកយើងទៅមុខទៀត ចំណែងពួកអ្នកស្រុកនេះ យើងត្រូវចាប់យកខ្វះមកទឹមរទេះធ្វើជាគោឲ្យអញជិះ ៗ

តាចារ្យយ៍និយាយចប់ពួកសេនាទាំងអស់គ្នានោះមកជួបជុំគ្នា ហើយស្រែកហ៊ោគ្រាវ ៗ ឡើងបំផ្លិចពួកនរគង

ក៏លែងស្រែ ។ រួចចាប់អ្នកស្រុក ១០ នាក់ យកទៅទឹម

នេះធ្វើជាគោ ដោយដាក់ម្នាក់២នាក់ឲ្យអាចារ្យយើជិះ ។ ពេល

នោះមើលទៅគួរឲ្យវេទនាណាស់ មនុស្សស្រែនោះយកគ្នា

ទៅទឹមធ្វើជាគោ ហើយបើជិះតែអាចារ្យយើម្នាក់ឯងនោះក៏មិន

សូវជាអួតប៉ុន្មានទេ ពួកសេនាធ្វើស្នាំទឹកក្រមប្រើក្បា

ដំឆត ១ របស់អាចារ្យយើនោះឡើងជិះដែរ ហើយក៏យកបាំ

ហោលឡើងហុយជ័ព្រលោម ។

អាចារ្យយើបេញផុតបន្តិច ស្រាប់តែពួកទាហានបុក-

ក៏នូលទៅដល់ទៀត ក៏ចាប់ធ្វើបាបអ្នកស្រុកនេះបៀបតែ

ក្រុមអាចារ្យយើដែរ ពួកអាចារ្យទាំងពីរក្រុមនេះស៊ូទតែអាបណា

ហាវផ្ចុបគ្នា ។ ក៏ចោទប្រកាន់អ្នកស្រុកថា អ្នកស្រុក

ទាំងនេះជាបក្សពួកអាយើងសុទ្ធៗ ក៏ធ្វើបាបអ្នកស្រុកឥតត្រា

ប្រណី ។ ពីរបីថ្ងៃក្រោយមកទើបក៏ផុតទុក្ខភ័យ ។

www.elibraryofcambodia.org

# ៤

## អុំដៃរីកាមុខប៉ុនចង្អេរ

ទំពាបាក់នឹងចេញទៅទំនេរវិញ ៗ ក្រុមអាចារ្យយើបាន ទៅដល់ភ្លើសកម្មភាពព្រៃផ្សៃនៅស្រុកស្រីសន្ធរ (ព្រែក-ពោធិ) ស្រុកខ្សាច់កណ្តាល រួចធ្ងន់នៅមុខកំពូល (រកាគោង) ស្រុកខុត្តរ ធន់ប្រកល្អកឯទៀតនោះ អ្នកស្រុកម្ពុំមេសប្រចណ្ឌបានសេចក្តីសុខសប្បាយមួយគ្រាដែរ តែនៅតែងមានការព្រួយបារម្ភខ្លាចក្រែងវាត្រឡប់មកវិញ ៗ

ធាងមុម្ភដែលបានមកសែនៅ ជ្រកគោនក្រោមដំបូលផ្ទះអ៊ែនោះ ពោះម្អកស្រុកគ្រប់គ្នាបានសេចក្តីសុខសប្បាយខ្លះ ៗ យ៉ាងណា កនាងនៅតែងទុក្ខព្រួយបន្ត

ជាទិច្ចព្រោះតែកំព្រាគ្មានឪពុកម្ដាយ ។ កាលពេលនាងមានមុខក្រៀមក្រំក្ដួចចិត្តចំពោះអនាគតរបស់ខ្លួន ជាពន់ពេក តែនាងជាក្មេងមានមារយាទល្អ ទោះនាងមានទុក្ខកង្វល់យ៉ាងនេះក៏ដោយ នាងមិនដែលភ្លេចខ្លួនមកសោ ដោយសារនេះទេ ។ នាងជួយធ្វើការជំនួសដៃម្ដាយធំគ្រប់សព្វឥតខ្ជិលច្រអូសម្ដងណាឡើយ ។

ចំណែកនាងវណ្ណាកូនគុំផែវិញ នាងដឹងខុសត្រូវណាស់ដែរ ពេលណាឃើញបុប្ផាកើតទុក្ខខ្លាំង នាងតែងជួយបន្ធូរបន្ថយ ធ្វើការអ្វីនាងធ្វើតាំងពីរនាក់ ទៅណាទៅតាំងពីរនាក់ ។ នាងស្រឡាញ់គ្នាណាស់ ដោយនាងតាំងពីរមានអាយុស្រករគ្នានោះ ធ្វើឲ្យគេនឹកស្មានថាជាកូនភ្លោះ កំពស់ក៏ប្រហែលគ្នា មុខមាត់សឹងដូចគ្នាបេះបិទ ខុសបន្តិចត្រង់នាងបុប្ផាមានរៀងល្អ ទឹកសាច់ជ្រះជាងវណ្ណាប៉ុណ្ណោះ ។

ឆលផុតម្តាយទើបនឹងស្លាប់ទៅ នាងបុប្ផាទើបតែអាយុ១៣ឆ្នាំទេ ឥឡូវនេះនាងមានអាយុ១៩ឆ្នាំហើយ បើទោះកំទោះបន្តិចបន្តួចប៉ុណ្ណោះ ។ ឯនាងវណ្ណាវិញក៏ពេញក្រមុំដូចនាងបុប្ផាដែរ ។

តាំងពីក្មេងស្រីទាំងពីរពេញរូបពេញរាងមក អ៊ុំផៃតែងមានគេព្រួយបារម្ភកើតទុក្ខជានិច្ច ខ្លាចក្រែងក្រុមការពារ្យយ៉ីជីង ឬក្រុមបារាំងដឹងរឿងមកចាប់យកធ្វើជាប្រពន្ធ ព្រោះពួកអាចង្រៃទាំងនោះ វាតែងដើរចាប់ស្រីក្រមុំស្អាតៗ យកទៅធ្វើជាប្រពន្ធតែបួនដប់ថ្ងៃបំផ្លាញកិត្តិយសស្រី រួចទើបវាលែងមកវិញដែលជាការធម្មតារបស់វានោះ ។

នៅភូមិមេសប្រចណ្ឌនេះ មានដឿម្នាក់ឈ្មោះម៉ាំង ជាអ្នកមានទ្រព្យសម្បត្តិយ៉ាំងស្តុកស្តម្ភ មានមនុស្សរាប់អាននឹងកោតញញើតគាត់ជាច្រើន ព្រោះគាត់មានប្រាក់ឲ្យគេជំពាក់បំណុលស្ទើរគ្រប់ ១ គ្នា ។ គាត់ជា

អ្នករកស៊ីជំនួញស្រូវ, ពោត, សណ្ដែក, ល្ហុង ដឹកនាំចុះឡើងមកលក់នៅភ្នំពេញញឹកញាប់ ។ ជំនាន់នោះទោះស្រុកកើតអសន្តិសុខយ៉ាងណាក៏ដោយ ក៏ដំណើររបរនេះមិនដែលមានគ្រោះថ្នាក់ឧបសគ្គអ្វីដែរ ព្រោះគាត់ចេះស៊ីអ្នកវាយឆែប ស៊ីរះតាំងសងខាង បារាំងក៏ត្រូវ ចោរក៏ត្រូវ ឥស្សរៈក៏ត្រូវ ។ ពេលមកភ្នំពេញម្ដង ៗ គាត់ច្រើនទៅសំណាក់នៅផ្ទះអ្នកម្នាក់នៅផ្សារកាប់គោ ។ ពេលមានរឿងជាមួយនាយកប៉ូលីស ឬក៏ជាមួយអ្នកលក់អ្នកទិញម្ដង ៗ ដង្ហើរម៉ាងមានអ្នកធំនោះឯងជាទីពឹង ។ អ្នកធំនេះដង្ហើរម៉ាងហៅតែព្រះតេជគុណ ១ ។ ព្រះតេជគុណនេះបារាំងបានតែងតាំងឲ្យគាត់ធ្វើជាចៅកាប់ មុខដំណែងយ៉ាងធំគួរសមដែរ ។ គាត់មានអាយុជាង ៦០ ឆ្នាំទៅហើយ ហើយគាត់មានប្រពន្ធពីរបីសុទ្ធតែក្មេងៗខ្ចីដែលមានអាយុស្មើនឹងចៅក្រមុំគាត់ដែរនោះ ។ សូម្បីប្រពន្ធពីរបីយ៉ាង

នេះក៏ដោយ ក៏ព្រះតេជគុណនៅតែមិនទាន់ស្កប់ស្កល់ចិត្ត និងតែចង់បានប្រពន្ធពីរបីថែមទៀត ។

ថ្ងៃមួយជន្លើមាំងនាំពានមកកំពេញ លុះលក់ឲ្យចិន-យួនរួច គាត់ក៏ឈៀងចូលទៅលេងផ្ទះព្រះតេជគុណនោះ ហើយបាននិយាយគ្នាលេងយ៉ាងយូរ ។ តែមិនហ៊ាននិយាយឲ្យត្រូវខ្លាំងទេ គេនិយាយទៀប ១ យូរ ១ ត្រូវសួរសើចខ្លាំងម្តង ១ ៗ នៅទីបញ្ចប់ស្រាប់តែព្រះតេជគុណគញ្ចាស់នោះនិយាយឲ្យជន្លើមាំងជួយរកប្រពន្ធដែលមានអាយុ ១៥ ឆ្នាំឲ្យគាត់បានមួយទៀត ។ គាត់និយាយបណ្តើរហុចប្រាក់មួយពាន់ប្រាំរយរៀល (១៥០០) ទៅឲ្យជន្លើមាំងបណ្តើរ ។ ជន្លើមាំងទទួលប្រាក់មក ហើយក៏អះអាងធានារកប្រពន្ធឲ្យឥតប្រហែល ។ ដាក់ប្រាក់ក្នុងតាបរួច ជន្លើមាំងសំពះលាព្រះតេជគុណគញ្ចាស់នោះត្រឡប់ទៅផ្ទះវិញ ។

លុះទៅដល់ផ្ទះជន្ទើម៉ាំងដេកសន្ធឹងសន្ធៃរិះគិតគេប្រពន្ធទៀតណាស់ ។ គិតយូរបន្តិចទៅក៏និយាយខ្សឹបខ្សៀវប្រាប់ប្រពន្ធគាត់តាមដំណើររឿង ។ ស្រាប់តែនៅពេលល្ងាចនោះចាំងតែរងាក់ប្ដីប្រពន្ធនាំគ្នាទៅផ្ទះគុំផៃតែម្ដងៗ គុំផៃបានទទួលកក់ទាក់ហើយសួរទៅកាន់ភ្ញៀវថា :

— ប៉ៅកែមកមានការអីដែរ បានជាអញ្ជើញមកផ្ទះខ្ញុំទាំងប្ដីប្រពន្ធយ៉ាំងនេះ ?

— អើ . . ល្ងាចនេះខ្ញុំមានការចង់និយាយជាមួយផៃឯងនឹងបន្តិចបានទេ ? (ជន្ទើម៉ាំងសួរ) ។

— ចាស . . . ចង់មានប្រសាសន៍យ៉ាំងម៉េចសូមប៉ៅកែមានប្រសាសន៍ទៅចុះ

— អើ . . . គ្មាននិយាយអីក្រៅពីមកស្នើដណ្ដឹងកូនផៃឯងទេ អើ . . . ដូចផៃឯងដឹងស្រាប់ហើយ ខ្ញុំឡើងចុះក្នុងពេញរកស៊ីលំថ្ងៃនេះ ពួកអ្នកមាន

ទ្រព្យសម្បត្តិទីនឹងរបស់លោកធំ ៗ គេស្គាល់ខ្ញុំច្រើនណាស់ ហើយមានលោកមួយនោះ គេធ្វើការជំណាស់លោកចង់បានប្រពន្ធនៅស្រុកយើង លោកបានពឹងខ្ញុំឲ្យជួយរកដណ្ដឹងកូនគេក្នុងស្រុកយើងនេះឲ្យគាត់ ខ្ញុំសំឡឹងមើលទៅគ្មានឃើញកូនចៅអ្នកណាត្រូវចិត្តសោះ វាមិនសមនៅផ្ទះឬ មិនសមជិះឡាន មិនសមធ្វើជាលោកស្រី តែ . . . ខ្ញុំគណិតនៃឯងពេក ឃើញនៃឯងគ្រប់ខជា ខ្ញុំមកស្នើកូនចៅនៃឯងហ្នឹង . បំណាច់ចង់ជួយលើកតំកើងនៃឯង តើនៃឯងគិតយ៉ាងណា ?

កុំនៃមិនទាន់ទាំងឆ្លើយផង ប្រពន្ធជស្នើហ៊ាននិយាយបន្ថែម :

- នៃឯង មានសំណាងណាស់ ប៉ុនជាបានទ្រព្យសម្បត្តិមហាចក្រហើយ ពេលនេះនៃឯងលែងក្រហើយ បានកូនប្រសារធ្វើលោកធំ . . .

ស៊ុំផៃគ្រាន់តែជឿស្តៅចាំងប្តីប្រពន្ធនិយាយថា ខាងប្រុសគេធ្វើធំនោះគាត់សប្បាយចិត្តណាស់ពុំប្រៀប ហើយគួបតែទៀតទឹកក្តីចិត្តថាគាត់បានជាប់សាច់ជាប់ឈាមនឹងអ្នកមានទ្រព្យនឹងអ្នកធំហើយពេលនេះ ក៏ធ្វើមេប្រាប់ទៅថៅកែម៉ាងភ្លាមវិញថា :

— មិនជាការទាស់អ្វីទេលោកថៅកែ វណ្ណាកូនខ្ញុំ ខ្ញុំគិតថាឲ្យវាមានប្តីសិនឆ្នាំនេះដែរណា ... ទុកយូរទៅក្រែងក់ផ្ទះឆ្ងាយព្រោះស្រុកទេសយើងមិនស្ងប់ស្រួល ...។

ថៅកែម៉ាងឮស៊ុំផៃនិយាយពីនាងវណ្ណា គាត់មានប្រសាសន៍កាត់យ៉ាងប្រញាប់តបទៅវិញ :

— ទេ ... ទេ ... អត់ទោសផៃ ខ្ញុំមិនមែនដណ្ដឹងនាងវណ្ណាទេ ខ្ញុំសុំដណ្ដឹងនាងបុប្ផាទេតើ ព្រោះខាងប្រុសគេបានផ្ដាំថាប្រពន្ធរបស់គេ ទាល់តែមានរូបរៀងដូចបុប្ផាទើបគេព្រមយក ម្យ៉ាងទៀតខ្ញុំគិតឃើញថាបុប្ផា

កំព្រាគ្មានឪពុកម្តាយគួរឲ្យវាមានប្តីមុនទៅចុះ . . .

អ៊ុំផេញឮចៅតែម៉ាន់និយាយមិនត្រូវការវណ្ណាកូនរបស់គាត់នោះ ហាក់ស្ទើរធ្លាក់ថ្លើមក្តុក ហើយនិយាយបែបររើររ៉ាយថា :

– យី ! ផណ្តឹងម៉ីបុប្ផា ! ម៉ីបុប្ផាខ្ញុំមិនទាន់ចង់ឲ្យវាមានប្តីទេ វានៅក្មេងណាស់ រាល់ថ្ងៃវាគ្មានដឹងខុសត្រូវអីសោះ ឡេះឡោះ ៗ ដូចកូនក្មេង សូម្បីតែបាយដាំមិនទាន់បានស៊ីផង ខ្ញុំមិនដែលឲ្យវាធ្វើការអី ១ ទេ ប្រើឲ្យតែវាទៅចាំតោចាំក្រប៉ប៉ុណ្ណោះឯង បើវណ្ណាកូនខ្ញុំវិញវាដឹងខុសត្រូវណាស់ ប្រើបានដូចចិត្ត . . . មិនល្ងង់ដូចម៉ីបុប្ផាទេ . . .

និយាយគ្នាមកដល់ត្រឹមនេះ ជន្ទៅម៉ាន់ឈប់និយាយចុះចុកសឲ្យប្រពន្ធគាត់ជួយនិយាយម្តង :

– ហ្ហឺយ . . . ផែអើយ បុប្ផាល្មមឲ្យមានប្តី

ហើយ ទុកកាលធ្វើតែទៀតក្មេងអាយុ ១៥-១៦ ឆ្នាំទៅហើយ នោះ ក្មេងណាក៏ដូចជាក្មេងណាដែរ នៅក្រមុំតែងតែ ល្ងង់ឥតដឹង ដល់កាលមានប្តីទៅ ទើបបានដឹងខុសត្រូវ មួយទៀតខ្ញុំយល់ទៅក្រោមការប្រយ័ត្នដឹង ប្អូនត្រូវតាមបានកាន់ ដឹងនាំតែខាត... គេ ដូចដែលដឹងស្រាប់ហើយតើ..., ។

ប្រពន្ធនិយាយចប់ ដង្ហើមរាំងផ្ទុះបៀតកុំតែននៅ ទៀត ហើយដកប្រាក់ចេញពីហោប៉ៅមួយពាន់រៀល (១០០០៛) គាត់លាក់ទុកប្រាំរយ (៥០០៛) យកមក បង្ហាញប្តីនិយាយថា:

– ថៃឯងកុំគិតវែងពេក មើលណេះប្រាក់មួយពាន់ រៀល បើថៃឯងព្រមឲ្យបុប្ផាទៅនេ យកប្រាក់ហ្នឹង ទៅស៊ីបាយលេងមុនសិនទៅ ដល់ពេលការល្អយកតាក់ពី ស្រេចតែខាងប្រុសទាំងអស់ ហើយគេជូនមាស គេជ្រើ នឹងប្រាក់ខ្លះថែមទៀត ការរួចមានឡានជិះ មានផ្ទះថ្មនៅ

មានឈ្មោលប្រុសស្រីប្រើតាមចិត្ត ម៉េចត្រូវប្ដីមិនព្រម ?

ពុំផ្ញើថាឡាន ផុះថ្មី នឹងឃើញប្រាក់ ១០០០៛ ( មួយពាន់រៀល ) នោះ គាត់មួលពោះទាំងណាស់ បើសិនជាគេត្រូវការនាងវណ្ណកូនបង្កើតរបស់គាត់វិញ មិនដឹងជាគាត់សប្បាយចិត្តដល់កម្រិតណាទេ តែគេបែរជាទៅត្រូវការបុប្ផាឯណោះវិញ ម្ល៉ោះហើយគាត់អង្គុយសំកុកច្រើនភ្ញើមុខស្ងូរ មួយសន្ទុះក្រោយមកទើបគាត់ឆ្លើយទៅរកផល្លាម៉ានវិញ :

- មិនកើតទេចៅតែ ខ្ញុំមិនបានឲ្យក្លាយ ១ ទេ ចាំខ្ញុំសួរក់មើលសិន បើវណ្ណកូនរបស់ខ្ញុំវិញ ខ្ញុំហ៊ានសម្រេចជូនភ្លាមតែម្ដងហ្នឹង បើអញ្ចឹងចាំថ្ងៃស្អែកសិនទៅ សុំខ្ញុំជូនដំណឹង ។

- អើ . . . ស្អែកក៏បានដែរ រឿងនេះបើស្រេចបាច់ហើយត្រូវរៀបការក្នុងពេលឆាប់ ១ នេះ ខាងប្រុស

គេមិនទុកយូរទេ  គឺយើងទៅក៏យកពី  លុយកាក់ប្រាក់កាស់ខាងប្រុសគេបញ្ចេញទៅតើ  យើងគ្មានខាតអីមួយសេនទេ  សំពត់ខោអាវក៏គេកាត់ឲ្យដែរ ។

និយាយចប់ហើយតាមាន់និងប្រពន្ធ  លាម្ចាស់ផ្ទះត្រឡប់ទៅផ្ទះគាត់វិញទុកឲ្យកាសខ្សែអុំដៃគិតគូរពិចារណា ... ។

ថ្ងៃនោះអុំដៃក្ដៅក្រហាយចិត្តណាស់  បំណាំមកដល់មាត់ហើយមិនបានស៊ីទៀត  ម្ល៉ោះហើយអង្គុយក៏មិនសុខបក់មិនល្ហើយ  ព្រោះតែគេមិនត្រូវការកូនគាត់  ចិត្តអន្ទះអន្ទែងយ៉ាងខ្លាំង ។

លុះដល់ពេលល្ងាចនាងបុប្ផាមកពីឃ្វាលគោវិញនាងដឹកគោបញ្ចូលក្រោលព្រមទាំងផ្លុកកររួច  អុំដៃហៅមកនិយាយប្រាប់ថា ៖

— បុប្ផា !  អញចង់ឲ្យឯងទៅលេងស្រុកឆ្ងាយពេលបួនដប់ថ្ងៃ  ត្បិតអ្នកសម្បត្តិជាគូព្រេងរបស់ឯង  គេចង់ឃើញឯង  ឯងមិនដែលទៅលេងសោះ  អញ្ចឹងស្អែកនេះ

www.elibraryofcambodia.org

ទៅលេងចុះ សឹមអញឲ្យកុំខ្លួនជូនឯងទៅឬទេ ?

នាងបុប្ផាមិនដឹងកលល្បិចពុំដែរទេ នាងសប្បាយចិត្តណាស់គិតថាម្តាយធំមានចិត្តល្អអនុញ្ញាតឲ្យ នាងដើរលេងហើយឲ្យទៅស្គាល់ស្រុកស្វាយតល ដែលនាងមិនធ្លាប់បានទៅលេងសោះនោះ ។ កន្លងយប់នោះនាងហាក់ដូចជាផ្កាបាយគិតតែអររើករាយចង់ឲ្យឆាប់ភ្លឺ ទើបបានទៅលេងស្រុកឪពុកមាតែប៉ុណ្ណោះ ។

ព្រឹកឡើងក៏ស្រាង ១ កុំដៃធ្មៀដៃធ្មេដើរបួញមុខបួញមាត់ ប្រើកុំខ្លួនបំពាក់ឲ្យជូននាងបុប្ផាទៅលេងស្រុកស្វាយតល ។ កុំខ្លួនស្តាប់បាន ក៏លុបមុខលាងមាត់រួចចុះទៅទាញរទេះទឹមគោបរជូននាងបុប្ផា ទៅភ្លាមឥតមានបង្អង់ ។

កាលនាងបុប្ផាចេញទៅភ្លាម កុំផែសប្បាយចិត្តតាំងសៀកពាក់យ៉ាងស្អាតបាត ហើយទាញក្រមាមកបង់ចុះ

www.elibraryofcambodia.org

ដើរយ៉ាងលឿនតម្រង់ទៅផ្ទះជនឆ្នោះម៉ោង ៗ គ្រាន់តែឡើងទៅដល់លើផ្ទះគេភ្លាម គាត់និយាយទៅកាន់ម្ចាស់ផ្ទះភ្លាមថា ៖

— មិនកើតទេចៅកែ ចៅកែជួយគិតមើលចុះពីល្ងាចមិញនេះ ខ្ញុំគ្រាន់តែប្រាប់ថាមានគេចូលមកស្តីដណ្តឹងតែប៉ុណ្ណោះមាត់គោះ ស្រាប់តែវាទទ្រាំដើរតួនតាំងសឹងបាក់ផ្ទះស្រែកដំណាលឡូឡាវិញ ថាវាមិនយកប្តីទេ ហើយស្រាប់តែនៅពេលយប់មិញនេះ វាគេចបាត់ពីផ្ទះមិនដឹងជាទៅណា ? សំពត់អាវក៏វាយកទៅអស់គ្មានសល់អ្វីបន្តិចទេ មីបុប្ផានេះវាអាក្រក់ណាស់ដូចជាខ្ញុំបានជំរាបចៅកែពីម្សិលមិញអញ្ចឹង មានតែវណ្ណាកូនខ្ញុំទេនិយាយអីទៅស្តាប់គ្នាបាន វាដឹងខុសត្រូវ ស្គាល់ចាស់ស្គាល់ទុំ បើលោកចៅកែព្រមដណ្តឹងវាខ្ញុំលើកជូនភ្លាម ឥតប្រកែកទេ ។

ចៅតែមាន់ទិនករយាណាលសុំតែប្រាប់ថាបុប្ផារត់បាត់ នោះ   គាត់ស្រងាកចិត្តយ៉ាងខ្លាំងជឿតាមសំដីសុំតែពាន់ស្រេង   សំគាល់ថានាងបុប្ផាជាក្មេងស្រីវិលខូចមែន   រួចគាត់មានប្រសាសន៍ថា :

– អើ . . . បើមីបុប្ផាតែបាត់ទៅហើយ   ខ្ញុំក៏មិនត្រូវការនឹងវាដែរ   យកវាមកធ្វើអីនាំតែខូចកិត្តិយសខ្ញុំ   បើអញ្ចឹងខ្ញុំសុំស្នើដណ្តឹងនាងវណ្ណាវិញចុះហើយប្រាក់ ១០០រ (មួយពាន់រៀល)   នេះតែឯងយកទៅសិតាយទិញសំពត់អាវឲ្យកូនស្លៀកពាក់ទៅណា . . .

ត្រាន់តែគេត្រូវការកូនគាត់ភ្លាម   សុំតែសប្បាយចិត្តណាស់ការរំពឹងទុកបានទួលប្រាក់ពីដៃចៅខាំង   មកដាក់ក្នុងហោប៉ៅគាត់ឥតគៀងខ្លួនសុំបន្តិចឡើយ   ហើយឆ្លើយប្រាប់ទៅគេវិញភ្លាម :

– បាន . . . បាន . . . មិនអីទេចៅតែ

វណ្ណកូនខ្ញុំប្រពៅបានបទណាស់ ចាំឲ្យទៅឆ្វេងមុខជាឆ្វេង ចាំឲ្យទៅស្ដាំមុខជាស្ដាំហើយ មិនរបេះរំពេះរំពើយដូចម៉ែបុប្ផាទេ . . .

— តែ . . . បើគ្នីងយើងរៀបការកូនពេលឆាប់ៗនេះខាងប្រុសគេចង់រៀបការឲ្យហើស មិនចូលចិត្តទុកយូរទេ ដល់ការរួចគេយកឡានមកដាក់យកទៅភ្នំពេញ ហើយគេមិនទុកប្រពន្ធគេនៅឲ្យស៊ីអំបិលប្រហុកស្រុកស្រែចំការទេ . . . (ចៅតែមាន់និយាយ) ។

— យើ . . . ចង់ការថ្ងៃណាក៏បានដែរ ស្អែកក៏បាន ខានស្អែកក៏បាន ស្រេចតែលោកចៅតែប៉ុះ ការរួចហើយចង់យកទៅណាក៏បានដែរខ្ញុំប្រគល់ជូនហើយតើ.

ប្រពន្ធដស្ដើមាន់ដឹងថាគុំផៃចូលសិងគាត់ហើយ ក៏គាត់សៅតែលាក់គាថក៏បានមិនឲ្យគុំផៃដឹងថា ខាងប្រុសជាបុរសចាស់ដែរ គាត់គិតថាចាំដល់រៀបការសម្រេចៗដោយ

គាត់ចង់ឲ្យគុំផែសប្បាយក្នុងចិត្តនោះ គាត់បន្ថែមពាក្យមួយម្ដងទៀតថា :

— ផែអើយ . . . ដល់រៀបការកូនរួចហើយ ត្រូវតែឯងគិតណាត់ប្រាប់វណ្ណផង បើបានទៀតឯហ្នឹងតើ ជាលោកស្រីផងទៅកុំភ្លេចខ្ញុំណា៎ . គិតបានឡាន ជិះបើកបុកខ្ញុំចុះ . . .

គុំផែឮថាវណ្ណការរួចបានទៀតជាលោកស្រី មានឡានជិះ គាត់គ្មានពាក្យឆ្លើយតបអ្វីនិយាយទៅកេប្រពន្ធ ហៅតែមកវិញទេ គិតតែញញឹមខ្ចប់មិនឈប់ឈរមុខរីក សើចមិនបង្អើរ ហើយលាហៅកែកទាំងប្តីប្រពន្ធចុះត្រឡប់ទៅផ្ទះគាត់វិញ ៗ ដោយសប្បាយចិត្តពេក គុំផែមិនពានចូលទៅផ្ទះគាត់ភ្លាមទេ គាត់ដើរឆ្នូតគាន់ប្រាប់ញាតិមិត្រជិតខាងសិនថាវណ្ណកូនគាត់បានប្តីជាអ្នកធំធ្វើការនៅទីក្រុងភ្នំពេញ មានឡាន មានផ្ទះថ្ម មានឈើលប្រសើរ..ៗ

www.elibraryofcambodia.org

លុះទៅដល់ផ្ទះគាត់នាំនាងវណ្ណាដើរស៊ីបាយ គាត់សំពត់អាវល្អ ៗ រៀបចំផ្ទះសម្បែងយ៉ាងហឹកហាក់ហ៊ឺហា ។

ពីពេលនោះមកវណ្ណា លែងស្លៀកពាក់ខោះពោលអស់សំពត់អាវចាស់ ៗ នាងបញ្ចេញសុទ្ធតែថ្មី ៗ មុខប្រឡាក់ម្សៅកល់ថ្ងៃប្រៀបបាននឹងតួឯកល្ខោនបាសាក់ដែរ ។

ចំណែកអ៊ុំខ្ទួនជូននាងបុប្ផាទៅដល់ស្រុកឆ្ងាយពេលគាត់ឡើងទៅលើផ្ទះអ្នកសម្បត្តិបានមួយសន្ទុះក៏បររទេះត្រឡប់មកតេម-សប្រចណ្ឌវិញភ្លាម ៗ ឯនាងបុប្ផានៅលើផ្ទះអ្នកសម្បត្តិជាទុក្ខពុតមា នាងគិតតែសប្បាយដោយឃើញស្រុកគេមានគ្រឿងប្លែក ៗ នាងភ្លេចដឹងខ្លួនថាអ៊ុំផែឡូតនឹងនាងឡើយ ។

## ៥

## មេការខ្លាងទៀតក្រែងក្លាយ

បីថ្ងៃក្រោយមក ៗ អ្នកសម្បត្តិបានទទួលសំបុត្រពីអ៊ុំផៃមួយច្បាប់ផ្ញើទៅប្រាប់ដំណឹងអាពាហ៍ពិពាហ៍ នាងវណ្ណា ៗ នៅពេលនោះនាងបុប្ផានឹកអរព្រេបដោយយល់ថាវណ្ណា មានសំណាងបានប្ដី ហើយនាងចង់ត្រឡប់ទៅមេ-សប្រប័ណ្ណវិញដើម្បីជួយធ្វើការរៀបចំផ្ទះសម្បែង តែអ្នកសម្បត្តិឃាត់ឲ្យចាំនៅជាមួយគាត់ ៗ

លុះដល់ថ្ងៃចូលរោងទើបអ្នកសម្បត្តិនាំនាងបុប្ផាទៅស៊ីការតែម្ដង ៗ

នៅថ្ងៃនោះអ៊ុំផៃមានមុខមាត់សម្បើមណាស់ អ្នក

www.elibraryofcambodia.org

ជិតខាងកោតញញើតគាត់គ្រប់ ៗ គ្នា ព្រោះគាត់មានកូនប្រុសនៅទីក្រុងភ្នំពេញហើយធ្វើធំដុំទៀតផង ។

ពិធីអាពាហ៍ពិពាហ៍ចាប់ផ្ដើមឡើង ភ្ញៀវប្រុសស្រីគគកុញត្រៀបត្រាពេញផ្ទះអ៊ុំផៃហៀរមកដល់ដីទៀត ។ មនុស្សសម្បើមណាស់ៗ ភ្ញៀវទាំងប៉ុន្មានព្រមទាំងសាច់ខ្ញនខាងស្រីរង់ចាំមើលផ្លូវកូនកម្លោះរហង់ៗ រង់ចាំតាំងពីព្រឹកទល់ថ្ងៃត្រង់នៅតែមិនឃើញមកសោះ ។ ដល់ពេលហែរកូនកម្លោះហើយ ក៏នៅតែមិនឃើញកូនកម្លោះមកទៀត ។ ពេលនោះអ៊ុំផៃមិនសូវស្រួលដូចពីពេលមុន ៗ ទេ គាត់ចេះតែស្ងុរស្ងារ ៗ មុខស្រងូតស្រងាត់ក្រៀមផ្ទះ ។

ឯផ្ទើម៉ាំងវិញ គាត់ដោះសាខ្លួនថាទៅតាមមើលផ្លូវកូនកម្លោះខ្លាចក្រែងមានគ្រោះថ្នាក់តាមផ្លូវ ។ តាមការពិតគាត់គេចទៅដេកនៅផ្ទះគាត់ឯណោះធ្វើព្រងើយ ។

ភ្ញៀវទាំងអស់គ្នាអស់សង្ឃឹមថាកូនកម្លោះ លែងមក

www.elibraryofcambodia.org

គារទៅហើយ ៗ អ៊ុំផៃសម្លឹងមួយមាត់ក៏មិនពួស្តីដែរ មុខគាត់ឡើងខ្មៅអែ ៗ ក្រៀវខ្លះក៏ត្រឡប់ទៅផ្ទះវិញទៅ ៗ លុះដល់ល្ងាចបន្តិចស្រាប់តែឃើញឡានមក ( ស៊ីត្រូអែន ) សម្បុរខ្មៅមួយបើកយ៉ាងសន្ធឹកមកឈប់ចតនៅមុខផ្ទះការ ៗ ពេលនោះចៅកែមាំងនឹងប្រពន្ធគាត់ក៏មកដល់ដែរ ៗ

នៅក្នុងឡានមានក្មេងប្រុសពីរនាក់ស្លៀកពាក់ស្អាតៗ ហើយមានបងក្រក់តក់ត្រប់ផ្លាផង ៗ អ្នកមករួមក្នុងពិធីការតាំងចុំគ្នាឃើញមនុស្សដល់ទៅពីរនាក់នោះ គេឆ្ងល់ណាស់តើប្រុសណាមួយជាប្តីនាងវណ្ណា ? ខ្លះនាំគ្នាស្រែកថា :

—« កូនកម្លោះមកដល់ហើយ មើលរៀបចំទៅ ឯណាឃ្មោះតាំតាំទៀត មេបក៏មិនក៏យទទួលគេទៅ » ៗ

ឯអ៊ុំផៃ សប្បាយចិត្តសឹងលោតកញ្ចោង ទឹកមុខរីកថ្លាលើសពីលើកមុន ១ ទៅទៀត ៗ ចញ្ញក្រុំ ១ ដែលមកពីនាងវណ្ណានោះម្នាក់ៗ សរសើរនាងវណ្ណាគ្នាជាប់

www.elibraryofcambodia.org

ពីមាត់ឡើយ ខ្លះថាវណ្ណការរូបមានខ្លួនជិះមានសំណាង ណាស់ ខ្លះទៀតសរសើរថាវណ្ណការរូបឡើងឋានៈជា លោកស្រី . . . ហើយកុំភ្លេចនាណា . . . ៗនាង វណ្ណបានគេសរសើរក៏ញញឹមរួចមិនបេះដាច់សោះ ៗ

បុរសពីរនាក់ចេញពីក្នុងឡានមកដើរតួរសមទឹងភៀវរូប ក៏មកនិយាយសាសព្វប្រាប់គ្នាថា :

– កូនកម្លោះមិនបានមកទេ លោកវរល់ញាំងណាស់ ឥឡូវនៅប្រទេសបារាំង ប្រទេសគេឡើមិនដឹងបាត់តាំងពីម្សិលម៉ិញម្ល៉េះ ៗ

គ្នីនៃកាលដំបូងគាត់ស្មានថា បុរសទាំងពីរនាក់នោះ ប្រើមិនមួយក៏មួយនៃវដែលត្រូវជាកូនប្រសាគាត់នោះ ៗកាល ឮថាកូនប្រសាពិតប្រាកដនៅស្រុកក្រៅនោះគាត់ក៏រកដងើម ជនខាន មុខឡើងស្ងាំងរកកលនៃគខ្សល់ចាប់ ៗ នៃអ្នក និយាយឃើញដូច្នោះក៏ចាប់ថែមសេចក្តីភ្ញាមទៀតថា :

www.elibraryofcambodia.org

– មិនអីទេអ្នកមីង ស្អែកនេះលោកត្រឡប់មកវិញហើយ កុំព្រួយ . . .

និយាយចប់បុរសម្នាក់ស្ទុះទៅយកប្រដាប់ប្រដាពីកូនឡានមកហើយនិយាយប្រាប់គេទៅទៀត :

– កូនកម្លោះមិនបានមកមែន តែលោកមិនឲ្យខូចដំណើរការនេះទេ លោកបានផ្ញើខោអាវ ស្បៀងដើងនេះមករៀបការបណ្តោះអាសន្នសិន លោកផ្តាំថាការរួចត្រូវឲ្យខ្ញុំជាក់ឡានលោកស្រី យកទៅការនៅភ្នំពេញម្តងទៀត ដើម្បីឲ្យហ៊ុំហាហ៊ុកហាក់ធំនៅស្រុកស្រែនេះ ឲ្យសមតាមឋានៈលោកជាអ្នកធំ . . . ម្យ៉ាងទៀតក្មេងៗរបស់លោកសុទ្ធតែអ្នកធំ ខ្លះជាជនបរទេសផង គេមិនមកស្រុកស្រែនេះទេ គេចាំស៊ីការឯភ្នំពេញ ។

គុំផែឮតែប៉ុណ្ណោះ ក៏ចាន់ទឹកមុខស្រស់ឡើងវិញ គាត់យល់ថាបើទៅការនៅភ្នំពេញម្តងទៀត ការឲ្យបានពីរ

លើចយកល្បើឈ្នោះ ម្យ៉ាងទៀតអ៊ុំផៃឃើញខោអាវរបស់ កូនប្រសារគាត់ស្អាត ៗ មានក្បាច់ចម្លាក់ ហើយមានមេ ដៃត្បូងធំខ្មៅសក្រហម បើថ្លឹងទៅសឹងបានកន្លះនាឡិ នោះ គាត់យល់ថាកូនប្រសាគាត់ធ្វើធំណាស់ ជាពិសេស គាត់ឮថាទៅស្រុកបារាំង គាត់ឡើងមីងជ័ទៀត គាត់នឹក ថាវណ្ណាកូនគាត់ការរួច គង់ថ្ងៃណាមួយបានជិះយន្ត ហោះទៅលេងស្រុកបារាំង, គាត់ឡើងមីងដែរ ម្ល៉ោះហើយ គាត់គិតតែញញឹមហើយញញឹមទៀត បិទមាត់មិនជិតទេ តែចង់ព្រះសំញើញ ។

ពេលគេកំពុងនិយាយគ្នា ជន្លៀម៉ោងបានដើរហួស ទៅក្រោយ បំណងទៅប្រាប់ចុងភៅឲ្យរៀបបាយទុកទទួល បុរសទាំងពីរនាក់នោះ ស្រាប់តែប្រទះឃើញនាងបុប្ផាកំពុង តែក្រាលកន្ទេលរៀបចំសម្រាប់ធ្វើពិធីផ្សេង ៗ គាត់ភ្ញាក់ ដោយនឹកឃើញថានាងរត់ទៅណាបាត់ទៅហើយនោះ ម្ដេច

ក៏ឃើញមកចំនេះល្ហុងវិញ ? គាត់បើកមាត់ក៏សួរទៅនាងបុប្ផាលេង  តែនាងបុប្ផាជាក្មេងត្រង់ហើយដោយមិនបានដឹងកិច្ចកលអ៊ុំផែនោះផង នាងក៏ប្រាប់ជន្លៀវម៉ាងតាមត្រង់ថា អ៊ុំផែបានប្រើឲ្យនាងទៅលេងស្រុកឆ្ងាយតល ៗ ពេលនោះចៅកែម៉ាងខឹងអ៊ុំផែណាស់  មិនគួរណាកុហកគាត់សោះ នេះមកតែពីចង់ឲ្យកូនស្រីខ្លួនបង្កើតបានប្តី ។ ចៅកែម៉ាងខឹងពេកក៏ដើរទៅជិតអ៊ុំផែ ហើយដកដៃគាត់ចេញឆ្ងាយពីគេ រួចគាត់និយាយខ្សឹបសួរថា :

- ផែ . . . ផែឯងម៉េចក៏កុហកខ្ញុំ ? មនុស្សបែបខ្ញុំមិនដែលអ្នកណាហ៊ានកុហកទេណា

- ឃើ . . . ខ្ញុំកុហកអី ? ខ្ញុំគ្មានកុហកលោកចៅកែទេ . . . ( អ៊ុំផែឆ្លើយ ) ។

ជន្លៀវម៉ាងយល់ថានេះជាឱកាសល្អហុចឲ្យគាត់ គាត់ក៏និយាយតាមត្រង់ប្រាប់ទៅអ៊ុំផែថា :

www.elibraryofcambodia.org

– ម៉ែ ! ម៉ែឯងមានបានទៅពិនិត្យមើលផ្ទះសម្បែង និងកូនប្រុសរបស់ម៉ែឯងឲ្យច្បាស់លាស់ទេ ?

– ទេ . . . ខ្ញុំមិនដែលទៅពិនិត្យទេ ខ្ញុំទុកចិត្តលើប៉ា ចែឯងហើយតើ មួយទៀតឲ្យខ្ញុំទៅពិនិត្យយ៉ាងម៉េចបើខ្ញុំមិនដែលធ្លាប់ស្គាល់ក្ដីពេញមុខផងនោះ . . . ?

– ម៉េចមិនទៅពិនិត្យមើលឲ្យស្រួលបួលផង មកទុកចិត្តលើខ្ញុំវិញ ខ្ញុំគ្រាន់តែជាអ្នកមកដណ្តឹងនាំផ្លូវទេតើម៉ែ . . . រឿងនេះមិនស្រួលទេម៉ែ កូនប្រុសម៉ែឯងធ្វើចាស់ ពពិចណាស់ទៅហើយ តែតាមខ្ញុំដឹងគាត់ចាស់អាយុជាង ៦០ ឆ្នាំទៅហើយណា៎ គិតទៅជាខុសពីខ្ញុំចុះ

– យី . . . កូនប្រុសខ្ញុំអាយុជាង ៦០ ឆ្នាំទៅហើយ ? អាយុប្រហែលជាងខ្ញុំទៅទៀតហ្ន៎ ! ទេ . . . បើអញ្ចឹងខ្ញុំមិនឲ្យណាកូនខ្ញុំរៀបការជាមួយទេ . . . ឲ្យរៀបការយ៉ាងម៉េចបើកូនខ្ញុំទើបតែនឹងបានអាយុ ១៨ ឆ្នាំនៅក្រមុំស្ដើងផង

www.elibraryofcambodia.org

ហើយប្ដីអាយុជាង ៦០ ឆ្នាំទៅហើយនោះ មិនសមគ្នាទេ ខ្ញុំសុំផ្ដាច់ហើយ ។

តែឯងផ្ដាច់មិនបានទេ បើផ្ដាច់ឈប់ការត្រូវសងបណ្ណាការនិងជម្ងឺចិត្តឲ្យគេច្រើនណាស់ មិនស្រួលទៀតនេះ គេធ្ងន់ណាស់ប្រយ័ត្ន រឿងនេះមានខុសពីគេឯណា ខុសពីយើងមិនទៅពិនិត្យឲ្យស្រួលបួលសិន គិតតែពីសប្បាយហ៊ុហាឥតបើគិត . . .

គ្រាន់តែដឹងថាកូនប្រសាចាស់អាយុជាង ៦០ ឆ្នាំនោះអ៊ុំតែហាក់ដួលចិត្តទៅហើយ គេផ្ដាច់ក៏ផ្ដាច់មិនកើតព្រោះគ្មានប្រាក់សងបណ្ណាការនិងជម្ងឺចិត្តគេវិញគាត់ទំរកខឹកដោះស្រាយបញ្ហានោះមិនរួចសោះ រំពេចនោះស្រាប់តែគាត់វិលមុខខ្យល់ចាប់ដួលទាំងជំហរ ។ មនុស្សផ្អើលឆោឡោរត់ទៅជួយ ហើយគេបាននាំយកទៅគោសខ្យល់ឲ្យ ៗ អ៊ុំតែនឹកសព្វគ្រប់ទៅខ្មាសគេណាស់ តែមិនបញ្ចេញស្ដីឲ្យ

អ្នកណាដឹងឮឡើយ ។ គាត់គិតថាមិនគួរណាលើកកូនក្រមុំ ឱ្យទៅមនុស្សចញ្ចាស់សោះ បើប្រសិនជាគេដឹងគាត់រឹត តែខ្មាស់គេថែមទៀត ម្ល៉ោះហើយគាត់ខំត្រិះរិះរកមធ្យោ- បាយដោះស្រាយយ៉ាងសម្ងំ ៗ លុះគេនឹកឃើញ មធ្យោបាយបោកប្រាសកូនកុហករួច ក៏ផៃស្លាងខ្យល់ក្លាម ហើយក៏ធ្វើជាខ្លាចប្ដូល ស្រែកឡូឡាព្រៀងកំពាស្រោមក ដឹកស្រោកឡើងដំពាលស្រែកថាខ្ញុំគាត់ ជាមេកន្លោងទៀត បង់បត់ព្រោះកន្សាលប្រាំបី ហាមឃាត់មិនឱ្យណ្ណាកូនគាត់ នោះរៀបការទេ គាត់ទំស្រែកដំពាលក្តួង ។ ថា ៖

— « អ្នកកល់នាពាប់មីបុប្ផាឱ្យជាប់ ហើយយកវា មករៀបការក្នុងពេលនេះជំនួសវណ្ណាវិញ ។ វណ្ណាមិន ទាន់ផល់ឲ្យព្រេងទេ មីបុប្ផាត្រូវតែរៀបការក្នុងពេលនេះជា ដាច់ខាត គូព្រេងរបស់វាផល់ហើយ បើវាមិនព្រមរៀប ការទេ អញ្ចេះមកន្លោងនេះទៀវបង់បត់ព្រោះកន្សាលប្រាំបី

រួមជាមួយគ្រាប់កាំផ្លោងជាច្រើន និងមីការផ្ទុះជាគ្រាប់ផ្លោង និងកាប់ចយករូបអ្នកតាំងអស់គ្នា ឲ្យស្លាប់មិនឲ្យសល់ ម្នាក់ឡើយ » ។

អ្នកនៅទីនោះតាំងពីមុនមក គេអាណិតនាងបុប្ផា ណាស់ ព្រោះនាងកំពុងតែធ្វើការបែកញើសឥតឈប់ ហើយ ចាប់យកនាងមករៀបការតាំងទទឹងទទែង ៗ គោះទាំងអស់ យ៉ាងណា នៅតែមេកន្ទ្រានទៀត (ដៃក្តិតកាយ) មិន ព្រមជាដាច់ខាត ដាច់តែឲ្យបុប្ផារៀបការក្នុងពេល នោះ ៗ ដោយអ្នកតាំងអស់គ្នាមិនដឹងកលល្បិចកុំដៃ ទឹកស្អានជាគ្រាប់បួលផែន ក៏ជឿតាមទាហមេកន្ទ្រានទៀត ទាំង ក៏សុខចិត្តបុះញាំមលែងអង្វរ ហើយយល់ព្រម ឲ្យនាងបុប្ផារៀបការជំនួសនាងវណ្ណាវិញ ។

មេកន្ទ្រានទៀតក្តិតកាយសប្បាយចិត្តណាស់ កាល គ្រាន់តែឮគេយល់ព្រមចាប់យកនាងបុប្ផា មករៀបការជំ

ជួសកូនបង្កើតរបស់គាត់នោះ គាត់នឹងសប្បាយចិត្តដោយ
កូនគាត់បានរៀនផុតពីថ្នាក់ រួចគាត់ក៏ធ្វើតាមវិធីការ
ឲ្យគេជឿថាក្មេងចេញទៅវិញក្ដាម ។

ពេលនោះជនស្មោះមិនសប្បាយចិត្តជាទីទេ កាលគេ
យកនាងបុប្ផាមករៀបការជំនួសវណ្ណានោះ ព្រោះបុប្ផានាង
មានរូបស្អាតជាងវណ្ណា ដើម្បីផ្គាប់ចិត្តទៅហ្វាយតញ្ញាស់
ដែលដេកចាំក្រៀមទាត់ឯកំពេញនោះ ម្ល៉ោះហើយជនស្មោះ
រិតតែធ្វើជាជឿក្មេងបាននេះទៅទៀត ។

ចំណែកនាងបុប្ផាក្មេងស្រីកំព្រា កាលគេចាប់បង្ខំ
ឲ្យរៀបការជំនួសវណ្ណានោះ នាងមិនព្រមទេ នាងកើតទុក្ខ
សោកសង្រេងទំនួញគេឡើងស្មុគបំពង់ក តែគ្មានអ្នកណា
ស្តាប់សោះ ព្រោះគេខ្លាចត្រូវបណ្តាសារមកនោងនេះទៀត
នឹងព្រាយក្បាលប្រាំបីកយំបាកគ ។

កន្លងក្រោនោះ បុប្ផាគេនិយមនលក់ទេ គំតតែពីទ្វារ

ឡូលេកាណិតខ្លួន ៗ នាងគិតចុះដើរទៅណាមិនបានព្រោះមានគេចាំឃាំឃាត់ឃាំងជាប់ ។ ដល់ពេលពាក់កណ្ដាលអាធ្រាត្រ គេហៅនាងឲ្យបុកលក្ខណ៍ ភ្លេងលេងកំប្រៀងអគ្រឹកគគ្រេងស្រាប់តែនាងទន់ជើងទន់ដៃសន្លប់បាត់ស្មារតីបន្តិចក្រោយមកទើបនាងមានកម្លាំងឡើងវិញ ។ ដល់ពេលភ្លៀបភ្លឺគេបង្ខំនាងឲ្យសំពះផ្ទឹមជាមួយខោអាវ និងស្បែកជើងប្ដីមិនដឹងជានៅឯណា? ពេលនាងកំពុងសំពះផ្ទឹមបាចផ្កាស្លានោះនាងគិតឃើញថានេះមកពីហេតុតែឯងកំព្រាអនាថាឥតឪពុកម្ដាយ គេបង្ខំឲ្យរៀបការទាំងទទឹងទាស់ក៏បាន គេឲ្យសំពះផ្ទឹមជាមួយខោអាវស្បែកជើងក៏គេធ្វើបានទាំងអស់នាងគិតឃើញសព្វគ្រប់ ក៏យំសោកអាណិតខ្លួនឯងណាស់ស្រោកស្រោន្តឡើយ ៗ

ក្រោយសំពះផ្ទឹមជាមួយស្បែកជើងរួច នាងបុប្ផាត្រូវគេនាំនាងយកទៅភ្នំពេញ ដោយគេកុហកថាយកទៅរៀប

ការឯភ្នំពេញម្ដងទៀត ។ តែតាមការពិតគេមានយកនាង ទៅរៀបការទៀតឯណា ? គេកុហកនាងដើម្បីយកទៅ ប្រគល់ឲ្យតាកញ្ចាស់តែម្ដង ព្រោះព្រះតេជគុណកញ្ចាស់ ដេករង់ចាំនៅភ្នំពេញឯណោះ ។

www.elibraryofcambodia.org

# ៦

## អាចារ្យយីសម្លាប់អ្នកក្លាហាន

ក្រោយឆ្លងបុណ្យភ្ជុំបានបន្តិច អាចារ្យយីលើកទ័ពចូលទៅដល់ពន្ធផ្ទះអ៊ុំផែដប់ បាញ់កាំភ្លើងទៅលើបី គ្រាប់ ប៉ុង ប៉ុង ប៉ុង ៗ ជាបន្ទាន់នោះ សេនាអាចារ្យយីម្នាក់ស្រែកប្រកាសឡើងថា :

- កូនក្រមុំដែលទើបនឹងការរួច ត្រូវយកទៅជូនព្រះតេជគុណ(អាចារ្យយី) ជាចៅហ្វាយយើង ឲ្យលោកផ្សំដំណេកបានបីបួនយប់សិន សឹមយកទៅប្រគល់ឲ្យប្ដីវា បើអ្នកណាមិនស្ដាប់បង្គាប់យើងទេ យើងនឹងវះពោះញាត់ស្មៅ

ត្រង់ពេលនោះ ពិតមែនតែចប់កម្មអាពាហ៍ពិពាហ៍

www.elibraryofcambodia.org

តែកៀវខ្វះមិនបានត្រឡប់ទៅផ្ទះខ្លួនវិញទេ ដោយអ៊ុំផៃពឹងឲ្យទៅជួយរៀបចំផ្ទះសម្បែង ឆាកខ្ទលបានឆ្នាំង ៗ ចំណែកឯស្រីក្រមុំ ១ ដែលមកកំដរនាងបុប្ផានោះ ខ្វះក៏មិនបានត្រឡប់ទៅផ្ទះវិញដែរ ។ កាលក្រុមអាចារ្យយើពួជាប់ ម្នាក់ ៗ ក៏យសឹងល្អស្រលីរតែទៅប្រកណាក៏តែមិនរួច ។ ពួកស្រីក្រមុំ ១ រត់ទៅពួនកងបន្ទប់ ពាស់ ១ ចុះទៅសំពះគន្ធ័ក្រុមអាចារ្យយើ :

— សូមបានមេត្តាប្រោស . . . កូនក្រមុំដែលតាររួច ខាន់ប្រុសគេមកនាំយកទៅក្នុងពេញគម្លាញម៉ាញទៅហើយ . . . បានប្រោស . . .

— យី ! . . ម៉េចក៏ប្រញាប់យកកូនក្រមុំទៅឲ្យប្តីរាម្ចះ ម៉េចក៏មិនយកទៅជូនទៅហ្វាយយើងផ្សំដំណេកប៉-ប្អូនយប់សិន . . . អ្នកកល់គ្នាធ្វើគញ្ចឹងខុសច្បាប់យើងមិនសុខចិត្តទេ ។ សេន្នាក់នេះនិយាយចប់ ភា

www.elibraryofcambodia.org

តាវ្យយ៍ក្រញែងខ្លួន ហួតដាវចេញពីស្រោមហើយបញ្ឈ
រដាវកូនចៅគាត់ថា :

— យើងមិនត្រូវអត់ឱនទោសឲ្យអ្នកទាំងនេះទេ គា
កូនទាំងអស់គ្នាត្រូវចាប់អ្នកស្រុកទាំងអស់នេះ យកទៅធ្វើ
ទោស ថ្ងៃក្រោយកុំឲ្យវាក្បត់អញអញ្ចឹងទៀត , . .

តាវ្យយ៍និយាយចប់ កូនចៅគាត់ចូលត្រូវចាប់
អ្នកស្រុកដែលមកអង្វរនោះ ខ្លះទៀតឡើងទៅរើកឆាយ
លើផ្ទះ ស្រាប់តែឃើញស្រីក្រមុំ ១ កំពុងតែភ័យពួនគេ
គ្នានៅក្នុងបន្ទប់កំព្រោន ១ ក៏ចាប់នាងក្រមុំទាំងនោះ
ទៀត ។

លុះរៀបចំចេញដំណើរចូលទៅក្នុងព្រៃវិញ តាវ្យ
យ៍ឈរជ្រែង ដៃច្រត់ចង្កេះភ្នែកឡើងក្រហមដូចភ្នែកអែ
អួតសំឡឹងថៃចុះឡើងៗមើលសព្វមើលគ្រប់ ស្រាប់តែមើល
ទៅឃើញនាងវណ្ណា បែបគាត់ចាប់ចិត្តស្រឡាញ់យ៉ាងខ្លាំង

www.elibraryofcambodia.org

ព្រោះស្រីក្រមុំទាំងប៉ុន្មាននោះ មានតែវណ្ណាម្នាក់ទេដែល ស្អាតជាងគេហើយគួរឲ្យបេតី គាត់សើចឡើងខ្លាំងៗ និយាយៈ

– ហាស . . . ហាស . - - ចូរតាកួន ដោះលែងអ្នកស្រុកទាំងអស់គ្នានេះទៅវិញចុះមិន ចាប់ខាំ យកទៅធ្វើអ្វីទេច្រើនណាស់ ចូរឯងចាប់យកតែនាងក្រមុំរូបស្អាតម្នាក់នេះ(តាតាវ្យើចង្អុលទៅនាងវណ្ណា) យកទៅឲ្យអញបានហើយ

កូនចោរឮមេកនិយាយដូច្នោះ ក៏ដោះលែងអ្នកស្រុកវិញអស់ទុកតែនាងវណ្ណាម្នាក់ប៉ុណ្ណោះ ហើយនាំគ្នាលើកទ័ពចូលទៅព្រៃវិញដោយយកនាងវណ្ណាទៅជាមួយផងៗ

នាងវណ្ណាកាលតាតាវ្យើចាប់យកទៅព្រៃនោះ នាងខំស្រែកទ្រហោយំក្រាញ់ចឹងគន្លងគេដូចជានាងបុប្ផា កាលគុំ ដៃចាប់បន្ទំទ្រការនឹងបន្ទំយកទៅក្នុងពញ្ញាវិរោះដែរៗ

តែគ្មានអ្នកស្រុកណាម្នាក់ហ៊ានចូលទៅជួយផងឡើយ គេគិតតែយកព្រះអាយុគេរៀរ ។

អ៊ុំខ្លួនគាត់ឆ្ងល់មែន កាលចោរព្រៃចាប់យកកូនក្រុមគាត់នោះគាត់ក៏ប្រថុយស្លាប់ ចេញប្រាណតួយ៉ាងគុះគុស មួយលើកតែតាមបំណងទៅកាប់សម្លាប់ ក្រុមចោរព្រៃយកកូនក្រុមគាត់មកវិញ ។ តែផលអំពើសោះក្រុមចោរព្រៃគ្រាន់តែឃើញអ៊ុំខ្លួនលើតួយ៉ាងពេញតាមក្លាម ក៏ព្រួតគ្នាចាប់ចាប់យកអ៊ុំខ្លួនទៅចងផ្ដួបនឹងដើមឈើ ហើយទះកំភ្លៀងគាត់ពីរបីដងមុខឡើងហើមពោរ រួចទើបក៏នាំគ្នាទៅមុខទៀត ។ អ៊ុំខ្លួនចង់ស្ទុះទៅតាមកូនគាត់ទៀតណាស់ តែគេចងផ្ទប់នឹងគល់ឈើជាប់មិនអាចទៅរួច ម្លោះហើយនៅតែកើតទុក្ខក្ដៅក្រហាយឥតអ្វីប្រៀបសម្រក់ទឹកភ្នែករហូតសឹងក្លាយជាឈាម ។

ថ្ងៃត្រង់ជិតពេលបាយចោរព្រៃលើកទ័ពទៅជិតដល់

ភូមិមួយឈ្មោះភូមិព្រៃក្រឡាញ់ ។ អាចារ្យបើរៀបចំនាំ
ចំពូលភូមិនេះស្រាប់តែលេចបុរសម្នាក់ឈ្មោះដោត មាឌធំ
ខ្ពស់សម្បុរខ្មៅឃ្មឹកចេញពីក្នុងភូមិមក ។ កាលក្រឡេត
ឃើញក្រុមអាចារ្យភ្លាម នាយដោតមិនបានជាប់ក្តី
និតឃើញថាក្រុមអាចារ្យនេះ នាយនឹកស្មានថាគេហែរ
បុណ្យផ្កាសៅវិញ ។ ដោយនាយដោតជាអ្នកក្លាហាន
មួយរូបដែរ ហើយធ្លាប់ធ្វើជាមេចោរល្បីៗខ្លាំងជាយូរមកហើយ
ដែរនោះ កាលនឹកស្មានថាគេហែរបុណ្យផ្កាជូនទៅមុខជា
បានប្រាក់ច្រើន ក៏មានបំណងជូនភ្លាម រួចទៅឈរយក
ដៃកាំងផ្លូវមិនឲ្យក្រុមអាចារ្យទៅមុខថែមទាំងស្រែកថា :

— អ្នកទាំងអស់គ្នាទៅណា ត្រូវប្រមូលប្រាក់យក
មកឲ្យអញភ្លាម . . .

ក្រុមអាចារ្យធ្លាប់តែក្លាហាន ពេលឃើញនាយ
ដោតតែម្នាក់ឯងមកឈរកាំងផ្លូវ និយាយបង្អាប់យកប្រាក់

www.elibraryofcambodia.org

នោះ ក្រុមនេះគ្មានញញើតប៉ុនសរសៃសក់ឡើយ ស្រែក គប់ទៅវិញ

— បៀស . . . បៀស . . . ប្រយ័ត្ន អញវះពោះញាត់ស្មៅហើយ . . .

ទ័ពគណាចារ្យនិយាយ ព្រមតាំងជើងរុញទៅមុខឥតបង្អង់ នាយជោកក៏មិនព្រមថយចេញហើយក្រោសខ្លួនដេកលើផ្ទៃឱ្យទ័ពគណាចារ្យដើរជាន់តាមចិត្ត ហាក់ដូចជាគ្មានតក់ស្លុតអ្វីបន្តិចសោះ ។ ទ័ពគណាចារ្យដើរជាន់លើខ្លួននាយជោកគ្រប់ ៗ គ្នានឹកស្មានថានាយជោកស្លាប់បាត់ទៅហើយ ស្រាប់តែនាយជោកក្រោកឡើងវិញសើចសប្បាយបែបក្លាហានថា :

— ហាស . . . ហាស . . . ពួកអ្នកឯងតាំង ៣-៤ រយនាក់នេះមិនគាបជាន់សម្លាប់អញបានទេ ឥឡូវប្រមូលប្រុកមកឱ្យអញក្លាម . . .

ក្រុមអាចារ្យឃើញចំណាស់ កាលធ្វើជាន់សម្លាប់យ៉ាងនេះហើយ នៅតែនាយជោគក្រោកឡើងនិយាយកេងកាងទៀត ។ ពេលនោះ អាចារ្យក្រញែងខ្លួនសង្កៀតធ្មេញដាក់នាយជោគ ហើយស្រែកបញ្ជាទៅកូនចៅគាត់ថា :

— ចាប់តាចាស់នេះយកទៅសម្លាប់ភ្លាម កុំទុកឲ្យវាតែធ្វើសម្មុខនាត់ទេ . . សម្លាប់ភ្លាមទៅតាកូន . . .

— កូនចៅអាចារ្យស្ទុះរឹងពេចពោចចាប់នាយជោគចងជើងចងដៃជាប់ រួចចាប់សម្លាប់ចោលតាមបញ្ជារបស់ចៅហ្វាយ តែសម្លាប់នាយជោគមិនស្លាប់សោះចាក់កាប់ទៅឮសូរតែកុស - កុស ដូចគេវាយស៊ុស មិនត្រូវមុតទោះទំយកដាវលំពែងពូថៅមកតាប់ចាក់យ៉ាងណាក៏មិនមុតដែរ ហើយមើលទៅនាយជោគហាក់ដូចជាគ្មានឈឺអ្វីបន្តិចឡើយ មុខនៅតែសើចញញឹម ៗ ជាប់ខ្ទាប់មកអាចារ្យស្រែកថា :

- យកកាំភ្លើងបាញ់វាសម្លាប់ចោលទៅ

លុះយកកាំភ្លើងមកបាញ់ក៏បាញ់មិនចេញទៀត បើតម្រង់បុងកាំភ្លើងឡើងលើ ឮសូរគងរំពងក្លួម បើតម្រង់ចំនាយដោតវិញក៏ជាឡើយដល់ឮសូរ សូម្បីតែឲ្យខ្សៀតគ្រាប់ចេញពីកងកាំភ្លើងក៏មិនចេញដែរ ។

កាលកាប់សម្លាប់នាយដោកមិនមុត បាញ់ក៏មិនចេញនោះ អាចារ្យយ៉ីខឹងខ្លាំងណាស់ ស្ទុះទៅខ្លួនឯងកាន់ដាវមួយខ្នូរ ចូលសំដៅទៅកនាយដោក ។ ដាវមួយខ្នូរដែលអាចារ្យយ៉ីកាន់នោះពូកែណាស់ មនុស្សណាកាប់មិនមុតបាញ់មិនចេញ យកដាវនោះទៅសម្លាប់មុខជាស្លាប់ប្រាកដ ។ ដូច្នេះហើយ បានជាអាចារ្យយ៉ីស្រឡាញ់ណាស់ ថែមទាំងឲ្យឈ្មោះដាវនោះថា "កាសីស្រៀវ" ឈាមមនុស្សដក់ជាប់ខនិមុខដាវកាសីស្រៀវមិនដែលដាច់ ហើយអាចារ្យយ៉ីដាក់លើជើងស្រាប់ ល្វាបឡើងតែងសូត្រមន្តអាគមថ្វាយបន្តឹងដាវរាល់ៗថ្ងៃមិនដែលខាន ។

www.elibraryofcambodia.org

អាចារ្យយីទៅដល់ក្បាលដាក់ឆាយដោកមួយដើមចំ កណ្តាលមុខបុាច់ រួចហូតដាវចេញមកចាក់សម្លាប់ ឆាយដោកតែម្តង តែចាក់មិនមុតទៀត ធ្វើឲ្យអាចារ្យយី ក្តៅក្រហាយលើសដើម ។ អាចារ្យយីអស់ចំណេះ ក៏បញ្ជាទៅកូនចៅតាថា :

— អើ! អានេះពូកែផង បើអញ្ចឹងកូនចៅទាំងអស់ គ្នាជីកអណ្តូងឲ្យជ្រៅរួចយកវាទៅកប់ទាំងរស់ . . .

ពេលនោះ ក៏ជីកអណ្តូងជម្រៅ ៤ ម៉ែត្រ ហើយ ដាក់ឆាយដោកទម្លាក់ទៅក្នុងអណ្តូង លប់ដីនាំគ្នាជាន់ឲ្យ ហាប់ណែនទៅវិញទើបនាំគ្នាចូលទៅបន្ទាយ បញ្ជាអ្នកស្រុក ឲ្យកាប់សម្លាប់គោក្របី ធ្វើបាយទឹកឲ្យក្រុមវាស៊ីជប់មុន ៗ ទៀត ។

អ្នកស្រុកខ្លាចអំណាចបុណ្យអាចារ្យយី ទោះតែខំ ធ្វើតាមបង្គាប់នាំបាយទឹកនំចំណីយកទៅជូនលោកដល់ស៊ុំគ្នា

www.elibraryofcambodia.org

អ្នកណាម្នាក់ព្រងើយកន្តើយឡើយ ។

ពេលនោះនាងវណ្ណាធ្វើមុខក្រៀមស្ពះ ប្រៀបបាននឹងមុខខ្មោច មិនព្រមស៊ីផឹកទឹកនោះទេ ។ អាចារ្យយើក្រឡេកទៅឃើញនិយាយថា :

- នែអូនក្រមុំកុំព្រួយចិត្តអី ញ៉ាំបាយទៅបងមិនសម្លាប់នាងក្រមុំឯងទេ បងយកនាងក្រមុំឯងមកធ្វើជាប្រពន្ធ . . . ញ៉ាំបាយទៅ . . .

នាងវណ្ណាមិនហ៊ានរឹងទទឹងទេ នាងទទួលទានបាយតាំងតែបន្តិច ៗ

នៅពេលអាចារ្យយើកំពង់តែផឹកស៊ី ស្រាប់តែឃើញឆាយដោកជើងពីក្នុងរណ្តៅដែលកប់នោះ ដើរទាំងក្លាហានញញឹមតព្រោយ ចូលទៅស៊ីផឹកក្នុងវង់ជាមួយអាចារ្យយើដែរ ធ្វើឲ្យអាចារ្យយើក្តៅក្រហាយទឹងតែខ្លាំងឡើង ៗ ហើយស្រែកឡូឡាឲ្យកូនចៅគាត់ថា :

www.elibraryofcambodia.org

– នែ.. អ៊ី.. ចាប់ការនេះឲ្យជាប់ នាមដាក់ក្បាលវា ហើយដុតដែកឲ្យឆ្អិនយកមកសិកប្រហោងគូថវាទើបវាស្លាប់

កូនចៅគាហ្វាយ៉ស្ទុះឡើងដាប់ជួយដាប់ទឹក រត់ចាប់នាយដោកជាប់ទាំងនាម នាមដាក់ក្បាល ហើយយកដែកក្តៅនេះប៉ុនកដៃ មកដុតភ្លើងឡើងឆ្អិនក្រហមឆ្អៅដូចរងើកភ្លើង រួចចាប់ឲ្យនាយដោកបំពង ហើយវាយកដែកនោះទៅចុកសិកតាមប្រហោងគូថ ៗ ស្រោចនៃដែកចូលកន្លែងពោះភ្លាម មានផ្សែងហុយតាមស្ទឹកត្រចៀក រន្ធប្រមុះ តាមមាត់ទ្រគោម នាយដោកក៏ប្រកាច់ស្លាប់ក្នុងពេលនោះទៅៗក្រុមគាហ្វាយ៉សប្បាយចិត្តណាស់ ដោយបានសម្លាប់អក្កាបានស្លាប់ ។

www.elibraryofcambodia.org

៧

# គោចាស់ប្រចះស្មៅខ្ចី

រថយន្តដែលនាំបុប្ផាមកនោះ លុះមកដល់ក្រុងភ្នំពេញ ក៏បែរមុខឆ្ពោះទៅផ្សារកាប់គោហើយបត់ចូលទៅឈប់នៅមុខផ្ទះព្រះតេជគុណ ដែលថៅកែម៉ាន់ធ្លាប់ទៅពឹងពាក់សំណាក់អាស្រ័យនោះ ។

ឡានស៊ីប្លេ ទីន . . . ទីន . . . ទីន ភ្លាមឆាយប្រុកតែមកបើកទ្វាររបង ឲ្យឡានបរចូលទៅចតនៅក្បែរមាត់ជណ្តើរផ្ទះ ។ មនុស្សគក្នជះចេញពីក្នុងឡានទាំងអស់គ្នា នៅសល់តែនាងបុប្ផាម្នាក់ឯងមិនព្រមចុះ ។ ទាល់តែគុំដៃទាញដៃទើបនាងចេញមក

ជនឈ្មោះម៉ាំង អ៊ុំផែនាងបុប្ផា នាំគ្នាឡើងទៅលើផ្ទះដោយមាននាយប្រុកជូនឡើងទៅផង ។

អ៊ុំផែសប្បាយចិត្តណាស់ដោយឃើញផ្ទះក្មួយប្រសារគាត់ស្តុកស្តម្ភ ហើយមានគ្រឿងប្រដាប់តុបតែងពាសពេញល្វែង មើលទៅគួរឲ្យចាប់អារម្មណ៍ ហើយគួរឲ្យសំគាល់បានជាជាផ្ទះអ្នកធំមែន ។

នាយប្រុកនាំភ្ញៀវទៅដល់លើផ្ទះនិយាយថា :

– ផ្ទះនេះលោកស្រី ៗ អញ្ជើញទៅលេងផ្ការួសទៅហើយ នៅសល់តែព្រះតេជគុណម្នាក់ឯងទេ ផ្ទួរគាត់នៅក្នុងបន្ទប់នេះសូមអញ្ជើញចូលទៅជួបលោកចុះ ។

នាយប្រុកនិយាយប្រាប់រួចក៏ចុះមកដីវិញ ដើម្បីចាំយាមផ្ទះមើលថែទាំសួនច្បារ ស្រោចទឹកផ្កា ទីងជីកន្ត្រៃឲ្យផ្ទុះតាមបម៌ជាដើម ៗ ឯអ្នកទាំងពីរដែលបើកទ្វាគេទៅយកបុប្ផាមកនោះ ក៏ចុះទៅដីវិញដែរ គេផ្លាស់ខោអាវស្អាតៗ

www.elibraryofcambodia.org

រួច អ្នកទាំងជួយធ្វើការនាយប្រែក ទាំងជួនខ្មាន អ្នកទាំង ម្ដាសម្ពុះ ព្រោះអ្នកទាំងពីរនោះសុទ្ធតែដឹងឈ្មោះព្រះតេជគុណទាំងពីរអស់គ្នា ។

បំណែកចៅកែមោងបើកទ្វារបន្ទប់នាំអ៊ុំផែនដីបុប្ផាចូលទៅ ឃើញព្រះតេជគុណកញ្ចាស់កំពុងអង្គុយប្រទុក ១ លើគ្រែតូចនោះនាំគ្នាសំពះនោរតក្បាល ។ នាងបុប្ផាស្មានថា ព្រះតេជគុណកញ្ចាស់នោះជាផុតកក្អកនាង ១ ទំសម្រម កាយទាយាងទន់ក្បនជួតទឹកកែកស្អាត មិនហានយំសោក ទៀតទេ ។ បំណែកអ៊ុំផែវិញ គ្រាន់តែឃើញព្រះតេជគុណកញ្ចាស់នោះភ្លាម គាត់យល់ដាក់ថាផិកយប្រសារ របស់គាត់ពិត្តនៈ បុប្ផារូបស្រេបទៅហើយ ។

ទាំងបីនាក់អង្គុយលើកៅអីដែលដាក់នៅជិតគ្រែនោះ ស្រួលបួលហើយ មោងក៏ជម្រាបព្រះតេជគុណថា អ៊ុំផែនេះ ត្រូវជាម្ដាយធំរបស់នាងបុប្ផា ។ ព្រះតេជគុណដឹង

www.elibraryofcambodia.org

ផ្ទះនោះ ក្រោកឡើងដើរទៅបើកទូដែកចាក់សោយកប្រាក់ចំនួន ៣០០០៛ (បីពាន់រៀល) មកហុចឲ្យអ៊ុំផៃក្តាម ។

អ៊ុំផៃទទួលប្រាក់យ៉ាងរហ័ស ដាក់ក្នុងហោប៉ៅផុត ហើយញញឹមខ្ជឹប ៗ ដង្ហើរឃើញអ៊ុំផៃបានលុយ ក៏គេរានាំចេញមកខាងក្រៅយ៉ាងលឿនរួចបិទទ្វារទៅវិញផង ។ លុះចែកប្រាក់គ្នារួចក៏នាំគ្នាត្រឡប់មក មេសប្រព័ណ្ណវិញក្នុងពេលនោះក្តាម ដោយទុកនាងបុប្ផាឲ្យនៅម្នាក់ឯងជាមួយតាកញ្ចាស់ . . ។

ចំណែកនាងបុប្ផាអង្គុយនៅក្នុងបន្ទប់ ជាមួយព្រះតេជគុណនោះ នាងនឹកស្មានថាអ៊ុំផៃនិងដង្ហើរមានចូលទៅវិញ នាងមិនដឹងថាគេយកមកឲ្យតាកញ្ចាស់នោះសោះឡើយ ។ នៅគ្រានោះ ដោយនាងចង់ដឹងពីដំណើរប្តីនាងក៏សួរព្រះតេជគុណថា :

— សូមអភ័យទោសលោក . . . ប៉ា . . .

ប្តី . . . ខ្ញុំគាត់ទៅស្រុកបាក់ង តើថ្ងៃណាបានគាត់អញ្ជើញត្រឡប់មកវិញ ?

— យី . . . អូនម្តេចក៏សួរគេញ៉ង បងមានទៅស្រុកផ្ទាក់ងឯណា បងហ៊ានហើយជាប្តីរបស់អូន អូនសួររកប្តីឯណាទៀត បងនឹងចាំមើលតែផ្លូវអូនឯងទេ . . . ( ព្រះតេជគុណកញ្ញាសឆ្លើយ )

នាងបុប្ផាសួរប្តីនោះ ក្រោយតែតាកញ្ញាសឆ្លើយមករកនាងសុខចិត្តពាក្យអូនបង ។ . . . ហើយនិយាយជាមួយគាត់ជាប្តីនាងថែមទៀត ៗ ខណៈនោះបុប្ផាភ្ញាក់ខ្លួនព្រឺត នាងស្ទុះក្រោកឈរឡើង ប្រឹងតែបញ្ចេញក្រៅ តែព្រះតេជគុណកញ្ញាសមានប្រសាសន៍ឃាត់ភ្លាម :

— អូនក្រោកទៅណា ? អង្គុយនៅអូន បើអូនដោយខ្ញុំកោយបង្កើរមកនេះលើគ្រៀក ឃើញម្តេចបងមកអូនត្រង់សំលៀកអ៊ី បងស្ងប់របស់អូនហើយទេ . . . អូន

គេនឹងយកកម្លាំងទៅ ដល់ល្ងាចជិះឡានដើរលេងជាមួយបង រួចយើងទៅមើលកុនកំសាន្តលេងទៀតណាអូន . ..

ព្រះតេជគុណកញ្ចាស់និយាយរកបុប្ផាអូន បងជាញឹកញាប់ពេកនោះ រិតតែធ្វើឲ្យនាងវិកវក់ងប់ចិត្តខ្លាំងឡើង ៗ បុប្ផានឹកឆ្ងល់ណាស់ ព្រោះនាងយល់ថាជាឪពុកក្មេកសោះ ម្តេចក៏ហៅនាងអូន ៗ អញ្ចឹង តែនាងគិតថាមនុស្សប្រុសប្រហែលជាគាត់ស្រវឹងហើយមើលទៅ ? ទើបនាងសួរម្តងទៀត :

– លោកប៉ា ! ម្តេចក៏លោកប៉ាហៅខ្ញុំជាកូនថាអូនៗអញ្ចឹង ក្រែងលោកប៉ាជាឪពុកក្មេករបស់ខ្ញុំ ?

– ទេ . . . ទេ . . . . . បងមិនមែនជាឪពុកក្មេកទេ បងនេះហើយជាប្តីរបស់អូន បងស្រឡាញ់អូនណាស់ ឲ្យបងសុំថើបបន្តិចមក បងមានការជាប់រវល់ជាច្រើនពេក បានជាមិនបានទៅរៀបការជាមួយអូននោះ

បងគ្រាន់តែប្រើកាមវិធីការបោកជាឈ្នួល ឱ្យយកទោការ ស្បែកជើង ទៅការជាមួយគូន... អគ្គិយជិតបងមកពៅមាស ព្រលឹងបង . . .

ព្រះតេជគុណកញ្ញាស់ មិនគ្រាន់តែនិយាយត្រឹម មាត់ទេ តែក្រោកដើរចេញ ។ ទៅរកស្រាក់ទុបរិតនាង បុប្ផាទៀត ។ ពេលនោះនាងបុប្ផាស្រែកហៅរកគុំដៃ... ស្រែកហៅរកថៅកែមើងឱ្យជួយតែមិនឮឆ្លើយសោះ នាង រត់ទៅបើកទ្វារបំណងរត់ចេញមកក្រៅតែមិនរួច នាងក៏ ស្រែកទ្រហោយំឡើង និងឃើញថាបាញ់ឡាកគេយក មកលក់ឱ្យតាកញ្ញាស់ . . . ។ ស្ដាយណាស់នាងបុប្ផា ទំរុញប្រានយ៉ាងណាក៏ទ្វារមិនបើកដែរ ព្រោះតាមការបៅថ្ងៃ បាក់សោពីខាងក្រៅជាប់ ។ ពេលនោះនាងបុប្ផាប្រៀប បាកនឹងកូនទន្សាយនៅក្នុងក្រញាំដៃខ្លា ឬដូចជាត្រីជាប់សំ ណាញ់តែម្ដង ។ តាចាស់សើចហាស . . . ហាស..

www.elibraryofcambodia.org

ដើរទ្រេច ៗ ទៅរកស្រក់កៀនកើយ នាងបុប្ផាទាំងតែពេញ ផែនបន្ទប់ភ័ក្រមិនឲ្យតាហាស់ពាល់ខ្លួនប្រាណនាងបានទេ គេចុះគេឡើងជិះពាប់ជើងទឹងជើងស្រែផ្លូលព្រស បានទុកតាហាស ឲ្យតាហាស់សង្គ្រប់ខុបនាងពីលើជាប់យ៉ាងស្អិត មួយទៀតដោយនាងខ្សោយកម្លាំងពេក ព្រោះមិនបានដេកមួយយប់មកហើយថែមទាំងអត់បាយអត់ទឹក ហើយត្រូវធ្វើដំណើរពីស្រែមកភ្នំពេញទៀត ម្ល៉ោះហើយមិនអាចរើបំរះឲ្យរួចពីក្រញាំតាហាស់បានឡើយ ។ កាលសង្គ្រប់ពីលើនាងជាប់ក្លាម តាហាស់ក្តួលទំពែក ថ្លុកក្រង ដេញគ្រហុបបាននុកាសយ៉ាងល្អប្រៀបបានទឹងគោហាស់ប្រទះស្មៅខ្ចី ទំគ្រាក់កកេរស៊ីរបរលដល់គល់ស្មន ។

នៅក្នុងបន្ទប់ឮស្នូរតែព្រួសប្រាស ៗ ទឹងសម្លេងនាងបុប្ផាយំស្រែកខ្សាវ ៗ លាយទឹងស្នូរដង្ហក់ដងដង្ហើមយូរ ៗ របស់ព្រះតេជគុណប្រៀបបានទឹងក្របីហាស់ស្តួសខន្តិល ។

www.elibraryofcambodia.org

យូរ ៗ ពុំតាចាស់និយាយថា ៖

— ម៉េចក៏យំអូន ! ពៅមាសត្រលឹងបង អូនមិនស្រឡាញ់បងទេឬ ? បងស្រឡាញ់អូនណាស់ បងជាប្តីរបស់អូន ឈប់យំទៅអាណិតបងផង អូនកុំគិតច្រើន ស្រឡាញ់តែបងមក បងថ្នាក់ថ្នមអូន . . .

នាងបុប្ផាយំអន្លឹមអន្លក់ហើយឆ្លើយតបទៅវិញទាំងការក្តៅក្រហាយថា :

— ខ្ញុំស្រឡាញ់យ៉ាងម៉េច បើលោកតាឯងចាស់ជិតចូលរណ្តៅហើយនោះ អាយុតាឯងយ៉ាងតិចណាស់ក៏ជាង ៦០ ឆ្នាំដែរ មកធ្វើបាបខ្ញុំអញ្ចឹង លោកតាឯងគំនិតអាក្រក់ អាងមានប្រាក់ទិញគេយកមកធ្វើបាប...

— យី . . . , បងមានធ្វើបាបអូនឯណា បងស្រឡាញ់អូនទេតើ បងរកមាសស្នេហ៍មកធ្វើជាប្រពន្ធ ឲ្យបានមានផ្ទះ ប្រាក់មានចាយ ផ្ទះថ្មមានគេនៅ ឈ្នួលប្រុសស្រីមានច្រើន ម្តេចក៏អូនមាសស្នេហ៍ពោលថាបងធ្វើ

www.elibraryofcambodia.org

ហុចកូនអញ្ចឹង ។ កុំតែស្រដីយ៉ាងនេះ បងស្អប់ណាស់ បន្តិចទៀតបងនាំកូនទៅទិញមាស ពេជ្រ សំពត់អាវល្អ ៗ ស្បែកជើងកែងចោទឲ្យកូន កូនកុំព្រួយ . . ,

លុះដល់ពេលល្ងាចពួកប្រពន្ធដើមរបស់ព្រះតេជគុណកញ្ចាស់ត្រឡប់មកពីដើរលេងវិញ គេនាំគ្នាសើចក្អាកក្អាយសប្បាយទ្រហឹងអឹងកងពេញពាំងផ្ទះ ។ ពេលនោះព្រះតេជគុណកញ្ចាស់មិនព្រមចេញពីក្នុងបន្ទប់មកទេ គាត់គិតតែប្រកៀកប្រកុបនាងបុប្ផាមិនឃ្លាតឃ្លា ។ ដល់ពេលល្ងាចប្រពន្ធដើមទាំងពីរទាំងបីគោះទ្វារ អញ្ជើញឲ្យមកកាស្រ័យបាយក៏គាត់មិនព្រមចេញមកដែរ ។ គាត់ស់បែរជាស្រែកប្រាប់ឲ្យគេលើកបាយទៅជូនគាត់ក្នុងបន្ទប់នោះវិញ ។ ពួកប្រពន្ធដើមឮប្តីនិយាយដូច្នោះក៏ប្រើឲ្យស្ត្រីអ្នកបំរើលើកបាយមួយថាសយកទៅជូនភ្លាម ។

នាងស្ត្រីបំរើក៏លើកបាយសម្លរនិងចំណីមួយថាសយកទៅ

ជូនព្រះតេជគុណក្នុងបន្ទប់យ៉ាងស្រួកន់ ។ ពេលនាងចូល ទៅដល់ក្នុងបន្ទប់ បែបនាកញ្ញាសុមិនឃើញនាងស្រីបំរើ នោះចូលទេមើលទៅ បានជាគាត់នៅតែចុះឡើង ៗ បិតមាត់នាងបុប្ផាដែលនាងកំពង់ដេកសន្លប់ បណ្ដាលឱ្យស្ត្រី គួបំរើនោះភ្ញាក់ស្រឡាំងកាំងស្រែកភ្ញាក់សំឡេងញាក់ថាស ប្តាយសម្លុតើដៃពែកពានខ្លួនស៊ . . . រួចនាងក៏ប្រាស កាយចេញមកក្រៅវិញ ។ គាត់ស៊ីងណាស់ក៏ស្ទុះចេញ តាមមកខាងក្រៅ ស្ទើរភ្លេចវង្វេងនាងស្រីបំរើនោះថា :

– ហង៎ . . . ឯង . . . មើលឃើញអញហ្ន ? មុន ខឹងចូលទៅក្នុងបន្ទប់អញមើលក៏មិនដោះព្រាសើន . . ប្រយ័ត្ន អញដេញឲ្យចេញពេលរ៉ុ . . . ។ និយាយចប់គាត់ ដើរចូលទៅក្នុងបន្ទប់វិញភ្លាម ហាក់ដូចជាមិនចង់ឱ្យឃាតពី នាងបុប្ផាប្រពន្ធថ្មីពេលនោះឡើយ ។

ពួកប្រពន្ធដើមៗទាំងអស់គ្នា មានការងឿងឆ្ងល់ពេក

www.elibraryofcambodia.org

កំនិតស្មូរស្រើគួបពេះនោះ ៗ នាងស្រើបរំភើបប្រាថ្នាតាម ហេតុការណ៍ដែលនាងបានឃើញ ទើបពួកប្រពន្ធ ដើមទាំងពីរទាំងបីដងជាប្តីមានប្រពន្ធចុងមកទៀត ៗ កាល ដែលជាប្តីមានប្រពន្ធចុងមួយទៀត ពួកដើម ៗ ទាំងនោះ មានសេចក្តីព្រួយបារម្ភជាខ្លាំង ខ្លាចក្រែងព្រះគេផុតគុណ បោះបង់គេចោល ដែលនាងទឹកដែកក្នុងចិត្ត មិនហាន បញ ស្តី ៗ

មួយយប់មួយថ្ងៃកន្ទងផុតទៅ ៗ សុជន់ដំណេក ក្តិនជួបកន្ទំ ផ្តាល់ដំណេកផ្លូវផង់ ទឹកភ្នែកសំខាន់ឯទៀត ៗ ដែលធម្មជាតិបែកមកឲ្យ ហើយដែលនាងបុប្ផាតែងតែទំនៃ រាត្រាមិនឲ្យគេណាប៉ះពាល់ផល់ម្តងណាសោះនោះផង ឡើងនេះ ត្រូវតែពាសបំពាញញាក់ញ័រខ្លួនខ្ញុំសស់ ៗ នាងគិតឃើញថា គ្មានមធ្យោបាយអ្វីទីនដោះស្រាយរួចនោះទេ ព្រោះតែស្រុក ញាតិមិត្តដែលព្រួយប៉ះគ្នាថានាងមានប្តីទៅហើយ ម្យ៉ាងទៀត ក្តី ៗ ដែលមានតម្លៃឃាត់ថ្លៃមិនបានគឺ.. របស់គាត់ . . . .

នោះ ម្ល៉ោះហើយនាងបុប្ផាក៏សម្រេចចិត្តទាំងក្តៅក្រហាយ ព្រមយកព្រះគេហ៍គុណកញ្ញាសំនោះធ្វើជាប្តីទៅចុះ ។

បុប្ផានៅលើផ្ទះនោះយូរបន្តិចមក សេចក្តីអៀនខ្មាស់ក៏រលត់បាត់ខ្លះទៅដែរ ។ នាងលែងគិតពីប្តីចាស់-ក្មេងហើយ ។ នាងហ៊ានចេញមុខមកជួយធ្វើការសព្វគប់ក្នុងផ្ទះ ត្រូវបោសក៏បោស ត្រូវជូតក៏ជូត ត្រូវលាងក៏លាង លែងគួរផ្ចូបពេលមុនដូចនឹងឡើយ ។ នាងគិតតែម្យ៉ាងគឺទំផ្គាប់ចិត្តគ្រប់ពេលវេលា តែនាងមិនបានដឹងថាពួកស្រី ១ នៅលើផ្ទះនោះត្រូវជាប្រពន្ធដើមរបស់ប្តីនាងទេ ។ នាងនឹកស្មានថាជាកូនជាចៅប្តីទៅវិញ ព្រោះពួកស្រី ១ ទាំងនោះសុទ្ធតែក្មេង ១ ដូចនាងដែរ ។ ដោយស្មានថាគេជាកូនជាចៅរបស់ប្តីនោះបុប្ផាបានហៅគេសុទ្ធតែនាង ១ស្រាប់តែលោកស្រី១ទាំងនោះបោះកេមស្តីជេរជ្រេះឆ្អេះឡើងវិញយ៉ាងសម្បើមថា ៖

— មេសារដៃ . . . ហ៊ានរួមប្តីអញ ហើយហ៊ានហៅអញនាង១ទៀត ? មុននឹងហៅអញនាងសូមមើលមុខ

អញឡូវជាក់ស៊ិន អញប្រពន្ធទីពីរណា៎ មិនមែនចុងប្ដីបទេ ដូចមីសាវៃផងទេ . . . ហ៊ឹស . . . ។

ប្រពន្ធទីពីរជេរស្ដីឡើងបុណ្យរួច ប្រពន្ធទីបីក៏ជួយជេរបន្ថែមទៀត

– អញបង់តែបោចសក់ហានឹងឯងឥឡូវហ្នឹង ហ៊ានហៅអញអាន៑ ១ ផងមីស្មាគ្រេះ អញប្រពន្ធបីណា៎ . . . អញដើមហានឯងវ៉ី កុំមកក្អើវហៅអញអាន៑ ១ នោះប្រយ័ត្នបែកក្បាលណា៎ . . .

គ្រាន់តែផែនឹងបញ្ចេញមាត់ថាគេជាប្រពន្ធទីពីរទីបីភ្លាម បុប្ផាភ្ញាក់ខ្លួនព្រើតជើងថាស្រៃ ១ ក្រោកតាំងនោះជាប្រពន្ធដើមរបស់ប្ដីខ្លួន ។ នាងកៀនខ្ទាស់ណាស់ទឹកថាឯងបុរីគេមិនគួរណាទៅហៅគេដើមថាអាន៑ ១ សោះ . . . ដោយខ្ទាស់គេ បុប្ផាស្រីអកីក្ដៅគត់ចូលទៅដេកក្នុងសំរក់ទឹកភ្នែកកន្ទបខ្នប់ លែងចេញមកក្រៅ ។

# ៨

## ព្យាយាមគង់បានសម្រេច

ពួកលោកស្រីដើមៗទាំងប៉ុន្មាន គិតតែនាំគ្នាប្រណាំងនឹងគ្នាឈ្នានីសនាងបុប្ផា រហូតដល់គិតព្យាបាទនាងឲ្យវិនាស ។ ពេលណាព្រះតេជគុណកញ្ចាស់មិននៅ ពួកប្រពន្ធដើមទាំងនោះ ចោមរោមធ្វើបាបនាងបុប្ផាយ៉ាងខ្លាំង ចោទប្រកាន់ថាបុប្ផាល្បួងប្ដីខ្លួន ហើយបណ្ដេញមិនឲ្យនាងនៅលើផ្ទះទេ ។ មិនតែប៉ុណ្ណោះ ក៏ព្រមគ្នាពិតខ្វល់ចាក់រុកឲ្យតាចាស់ស្អប់ខ្ពើមនាងទៀតផង ។ តែតាចាស់គាត់មិនស្ដាប់យកជាការទេ ព្រោះគាត់កំពុងឈ្លក់វង្វេងនឹងនាងបុប្ផា ។ ចំណែកនាងបុប្ផាវិញនាងជាស្រីស្លូតត្រឹមត្រូវ

នាងមិនដែលឈ្នះប្រកែកតបតរករឿងហេតុនឹងប្រពន្ធដើមទាំងនោះទេ ទោះគេជេរ គេបញ្ចោរ ធ្វើបាបយ៉ាងណាក៏ដោយ នាងនៅស្ងៀមព្រាញ្ញយកតែសុខ . . . ។

កាលខំនាំគ្នាធ្វើបាបទាក់ទុតបំបែកបំបាក់រាល់ៗថ្ងៃយ៉ាងនេះហើយ តាចាស់នៅតែកៀកកើយថ្នាក់ថ្នមបុប្ផាទៀតនោះ ពួកលោកស្រីដើមនៅតែនាំគ្នាក្តៅក្រហាយនឹងបុប្ផាខ្លាំងឡើង ៗ ដល់កាលថ្ងៃលោកស្រីជំនុំគ្នារកមធ្យោបាយបំបែកបំបាក់គេទៅទៀតតែមិនបានសម្រេចដូចបំណងសោះ ។

នាងបុប្ផា បានរួមរស់ជាមួយតាកញ្ចាស់អស់រយៈពេល ៥ ខែប៉ុណ្ណោះក៏មានផ្ទៃពោះ ប្រពន្ធដើមនៅតែកើតទុក្ខលើសមុនៗទៅទៀត ដោយយល់ថាបើនាងបុប្ផាមានកូនមិនងាយនឹងបំបែកបានទេ ម្ល៉ោះហើយម្នាក់ៗគិតតែពីខំដើររកមធ្យោបាយយ៉ាងណាកំចាត់បុប្ផាចេញពីផ្ទះឲ្យទាល់តែបានទើបសុខចិត្ត មានថ្ងៃមួយពួកប្រពន្ធដើមយកថ្នាំខ្មែរទៅរោយលើគ្រែដែល

www.elibraryofcambodia.org

នាងបុប្ផាដេក ៗ នាងបុប្ផាមិនដឹងកំប្រាសដេកនៅ ក៏រមាស់រកលរកលពេញទាំងខ្លួន នាងអេះខ្លាំងស្រែកប្រទៀត នៅតែគួនឲ្យគេជួយ ស្រាប់តែពួកប្រពន្ធដើមទាំងនោះមិនជួយគ្នា ទៅបែរជាឈរសើចឡោសនឹងបណ្ដេញនាងថែមទៀត ៖

– នែ៎ . . . កុំស្រែកឲ្យខ្លាំងលើផ្ទះគេ បើប្រឈប់ចង់ឆាប់នៅឆាប់ឯណា ឲ្យផុតពីផ្ទះគេទៅ ៗ

កាស្ទូរនាងបុប្ផាណាស់ នាងរមាស់ចង់ស្លាប់ទៅហើយ ពួកប្រពន្ធដើមមិនគិតជួយនាងទេ គិតតែសើចឡកថែមទៀត ៗ លុះដល់ពេលនាងបែកញើសឡើងក៏រិតតែរមាស់លើសដើម សង្ស័យឲ្យគេជួយ គ្មានអ្នកណាជួយនោះ ម្លោះហើយនាងទំអេះខ្លាំងតែខ្លួនឯងដាច់សាច់ទាំងដុំៗតាំងជាពេញទាំងខ្លួនប្រាណដូចមនុស្សកើតឃ្លង់ ៗ

ពីរបីម៉ោងក្រោយមកព្រះតេជគុណចេញពីធ្វើការមកវិញ ដោយគាត់អស់កម្លាំងពេកក៏ប្រាស់ដេកទៅលើគ្រែ

នោះទៅ មួយសន្ទុះស្រាប់តែគាត់ស្ទុះក្រោកឡើងអេះខ្លាំង ខ្លួនប្រាណគាត់ដៃឡើងញាប់ស្លេក រួចស្រែកឲ្យឡាឲ្យគេជួយលោកតាផងទឹងខ្លាំងណាស់ គាត់ប្រឡោកគោកតួងទំអេះឡើងមួលខ្លួន ពេលនោះនាងបុប្ផាចេញពីបន្ទប់ទឹកត្រឡប់មកវិញ លោកតាសួរផងមួយថា :

- អ្នកណាយកតឹមដាក់លើគ្រែ បានជាបងរមាស់ខ្លាំងម្ល៉េះ ?

- ចាស . . . បង អូនក៏រមាស់ដែរ មិនដឹងជានរណាគេយកតឹមមកដាក់ទេ តែបមានគេស្អប់ខ្ញុំហើយបង ( បុប្ផាឆ្លើយ ) ។

លោកតាឮបុប្ផានិយាយដូច្នោះ គាត់រឹតតែខឹងខ្លាំងឡើង ខណៈពេលនោះគាត់ចេញភ្លើសមកទៀតរឹតតែរមាស់គាត់ក៏ប្រឡោកគោកតួងឡូឡា . . . ។ ពួកប្រពន្ធដើមឮដូច្នោះ ក៏នាំគ្នាទៅជួយថ្លៃ ខ្ទះជួតខ្លួនប្រាណ

ខ្ទះគេដាំមកបន្ទាប ហើយគេស្តីបន្ទោសនាងបុប្ផាដើម្បី ផ្គាប់ចិត្តតាចាស់ជាប្ដី :

— ហាងឯងធ្វើបាបប្ដីអញ ហាងឯងអម្រែកណាស់ កន្លែងដេកមិនចេះបោសប្រាសអក់ហោកទេ ហាងឯងជាស្រីចង្រៃ . . . មិនគួរណាឲ្យប្ដីអញរមាស់កេលកល យ៉ាងនេះនោះ ( ប្រពន្ធចុងស្តីឲ្យនាងបុប្ផា ) ។

សំដីនេះគួរឲ្យលោកតាចង់ខឹងនាងបុប្ផាដែរ តែលោកតាមិនចង់ទេ គាត់យល់ថាបុប្ផាជាស្រីត្រឹមត្រូវ នាងមិនមែនមានគំនិតសព្រក់យកអម្បែងដាក់លើកន្លែងដេកយ៉ាងនេះឡើយ ក៏ប៉ុន្តែរកចាប់កស្ដុតនាងមិនបាន ព្រោះគេជគុណសៅស្បៀមចាំលបមើលពុតប្រពន្ធចាំងតែចាំងបំនោះតើនាងណាមួយខូចៗ

ពេលនោះជាគ្រោះល្អដែរ បើសិនជាកូនប្រពន្ធដើមដាក់ថ្មៃខ្មៅឲ្យប្រើនោះ មុខជាមានគ្រោះថ្នាក់ជាមិនខាន តែដាច់ដិតពេក ព្រោះល្អជាក់យ៉ាងប្រញាប់ខ្លាចគេចាន់

នោះហើយដាក់បានបន្តិចបន្តួចប៉ុណ្ណោះ ។

ពួកប្រពន្ធដើមមានការព្រួយបារម្ភណាស់ ខ្លាចក្រែងប្ដីដឹងគំនិតអាក្រក់របស់ខ្លួន ៗ តាំងពីពេលនោះមកពួកដើម ១ លែងដាក់ថ្នាំបំបែកបំបាក់នាងបុប្ផាហើយ គេនាំគ្នាកប់រក ស្រឡាញ់នាងបុប្ផាណាស់ ឯកចិត្តស្មបុប្ផាលើសដើម ទៅទៀត ក៏ប៉ុន្តែធ្វើជាកប់ឥឡូវដើម្បីកុំឲ្យប្ដីសំគាល់ថាខ្លួន មានគំនិតអាក្រក់ ។

ព្រះតេជគុណសប្បាយចិត្តណាស់ កាលឃើញប្រពន្ធទាំងបួនទាំងដើមស្រឡាញ់រាប់អានគ្នានោះ ៗ គាត់មិនដឹងកលល្បិចរបស់ប្រពន្ធទាំងបីទេ ។

យូរថ្ងៃបន្តិចមក មានពេលមួយ ព្រះតេជគុណត្រូវគេអញ្ជើញទៅស៊ីរៀងនៅផ្ទះលោកសង្ឃបាក់ង នៅក្បែរវត្ត ៗ គាត់មិនហ៊ានយកប្រពន្ធណាមួយទៅតាមទេ ខ្លាចក្រែងគាំប្រណែនគ្នា ម្ដោះហើយគាត់ទៅតែម្នាក់ឯងដោយ

ខាននាយហោងបើកទ្វារជូនទៅ ៗ ឱកាសនោះត្រូវប្រពន្ធម៉ែមានពេលល្អ ក៏នាំគ្នាកប់សពនាងបុប្ផាលើសពេលណា ៗ ទាំងអស់ ធ្វើហាក់ដូចជាគេឈប់ប្រទូសរ៉ាយនាងបុប្ផាហើយ ៗ

បុប្ផាឃើញគេកប់សពដូច្នោះ នាងសប្បាយចិត្តណាស់ ៗ គេនាំនាងជំនុំគ្នានិយាយលេងពីអ្នកនេះពីអ្នកនោះសើចក្អាកក្អាយ ៗ មេប្រពន្ធទាំងពីរព្រោងប្រាជ្ញឲ្យនាងបុប្ផាស្ដាប់ ឯប្រពន្ធទាំងបីដើរដងទឹកម៉ាណាក់ (ជំនាន់នោះមានតែទឹកម៉ាណាក់) មកបែកគ្នាស្រើយជីកលេងកំសាន្តសប្បាយ លុះជីករួចទាំងអស់គ្នាដើរចេញទៅតាមដំណើររៀង ៗ ខ្លួន ៗ

ឥឡូវឲ្យកាណាត់នាងបុប្ផាណាស់ នាងគ្មានជំងឺជាគេក្បត់នាងទេ ៗ កន្លងទឹកម៉ាណាក់ដែលគេហុចទៅឲ្យនាងជីកនោះ គេបានដាក់ថ្នាំបំពុលបណ្ដាំនឹង

www.elibraryofcambodia.org

សម្លាប់នាងឯតែម្តង ។ គ្រាន់តែផឹករួចហើយក្លាយ បុប្ផា ដែលត្រូវថ្នាំពុលនោះបើកភ្នែកមិនរួច ក៏ចូលទៅក្នុងបន្ទប់ ដេកលង់លក់មិនដឹងខ្លួន ប្រៀបបាននឹងមនុស្សស្លាប់ តែម្តង ។

ពួកប្រពន្ធដើមដឹងថានាងបុប្ផាពុលថ្នាំដេកលក់ ក៏ នាំគ្នាទៅសែងនាង យកទៅដាក់ឲ្យដេកក្នុងបន្ទប់ក្រោមផ្ទះ ជាមួយនាយប្រុស ហើយសំរាតសំពត់អាវនាងអស់រលីង ពីខ្លួន ថែមទាំងដាក់ឲ្យនាយប្រុសគេងឱបថែមទៀត ។ នាយប្រុសដោយគ្នាធ្វើការពីពេលថ្ងៃ អស់កម្លាំងគេងដេក ឥតដឹងខ្លួន ពេលគេដាក់ឲ្យគេងឱបនាងបុប្ផានោះ នាយឱបឲ្យខ្វៃទាំងមិនដឹងខ្លួន ។

យប់ជ្រៅណាស់ទៅហើយ ទើបព្រះតេជគុណ ត្រឡប់មកពីដប់លៀនវិញ ។ ដំណើរបែបទ្រេតទ្រោត ។ ស្រវឹងស្រា ។ លុះចូលទៅក្នុងបន្ទប់ដេកមិនឃើញបុប្ផា

www.elibraryofcambodia.org

ប្រពន្ធបណ្ដូលចិត្ត គាត់ក៏ស្ទុះស្ទារដើរសួរប្រពន្ធដើម ៗ ពួកប្រពន្ធដើមទាំងនោះឆ្លើយតែថាមិនដឹង ៗ ពេលនោះព្រះតេជគុណប្រាស់ប្រាណ ទាំងគេខានបុប្ផាឡើងបែកញើស ម្ដងទៅមើលក្នុងបន្ទប់ទឹក ម្ដងទៅមើលក្នុងបន្ទប់គាបម៉ក៏នៅតែមិនឃើញ ៗ គាត់ក្ដៅក្នុងចិត្តយ៉ាងខ្លាំង ទាំងគេបុះរកឡើងតែផលខឹងទ្វារបន្ទប់ពាក់ថ្លាសប៉ុនតដៃ ៗ បន្តិចក្រោយមកទើបពួកប្រពន្ធដើម ១ និយាយប្រាប់ថា :

— បង ! បងរកមេបុប្ផានោះធ្វើអី ? ហ្នឹងហើយ បងមិនជឿខ្ញុំតាំងពីដើមមកបងអញ្ជើញទៅណាផុតភ្លាម ក៏តែងតែដើរបាត់ ១ អញ្ចឹង ប្រពន្ធរបៀបហ្នឹងទើបសមមុខបងឯង បើប្រពន្ធក្រមត្រូវបែរជាផ្កាខូច ពីព្រលប់មិញពេលដែលបងអញ្ជើញចុះទៅក្រោម ខ្ញុំឃើញមេបុប្ផាក៏ចុះទៅក្រៅខ្សែងលេងឧបរិតបើចគាត់កាំ ជាមួយតាប្រុសនៅ

ក្រោមផ្ទះ ឥឡូវតែអញ្ជើញចុះទៅមើលក្រោមផ្ទះមើល ។

ឮប្រពន្ធទីពីរទីបីនិយាយដូច្នោះ ព្រះតេជគុណក៏ចុះទៅមើលក្រោមផ្ទះ លុះដើរទៅក្នុងបន្ទប់នាយប្រុក ស្រាប់តែឃើញនាងបុប្ផាដេកស្រាតខ្លួនលត ហើយឃើញឧបរតិសន្ថវជាមួយនាយប្រុកយ៉ាងស៊ិតមែន ។ តាចាស់ឃើញប្រពន្ធបណ្តូលចិត្តដេកឧបរតិជាមួយបាវព្រៅរបស់គាត់នោះ ក៏កើតសេចក្តីប្រច័ណ្ឌ ហើយខឹងក្តៅក្រហាយយ៉ាងខ្លាំង ។

ក្នុងពេលនោះប្រពន្ធទីពីរទីបី ធ្វើជាចុះទៅជួយគេមើលដែរ ហើយធ្វើជាភ្ញាក់កាលដែលឃើញបុប្ផាដូចនោះ ប្រុកចាំងការក្រោធ ។ ម្នាក់ៗធ្វើកល់ផាដៃស្រែកជំពាលស្តីបន្ទោសឱ្យតាចាស់ជាប្តីថា :

— បងឯងមើចក៏យកស្រីចង្រៃខូចត្រកូលមកនៅលើផ្ទះ អញ្ចឹង ឥឡូវសមមុខណាស់ហើយ យកគ្នាទៀតទៅ

ប្រពន្ធត្រឹមត្រូវមិនដេកជិតទេ បើប្រពន្ធផ្ដេសផ្ដាសអញ្ចឹង បានដេកជិត ចង់ឯងយកកាំភ្លើងបាញ់ប្រពន្ធទៀតទៅល្អណាស់ ហើយព្រះអើយ ប្រពន្ធមកសាហាយជាមួយឈ្មោលឯងអញ្ចឹង ។

តាចាស់ត្រូវប្រពន្ធចាំងតែចាំងបំស្ដីបន្ទោសឡើងបោះតាបប្រៀបបាននឹងប្រេងសាំងដែលគេជះទៅក្នុងភ្លើងដែរ ។ តាក៏ស្ទុះចាំងតរេះទៅកាយមនុស្ស ដែលតាក់តែងតែដេកលក់គ្មានដឹងខ្លួនសូម្បីបន្តិចសោះនោះប៉ុន . . . ប៉ុន . . . ។

គុះគ្នាអើយ ! បុប្ផានឹងនាយប្រកកាល ត្រូវនឹងដំបងឈើប្រតរបស់តាចាស់ ក៏ស្ទុះក្រោកឡើងចាំងស្រឡាំងកាំងមមាំងមមើង ។ នាយប្រកស្ទុះទៅដោយនាយប្រកឯ នាងបុប្ផាទៅដោយនាងបុប្ផា ។ ចាំងតែនាក់សំគះតាចាស់ឡើងញ័រដៃ ។ នាយប្រកឆ្ងល់ក្នុងចិត្តថាដេកម្នាក់ឯងសោះម្ដេចក៏លោកស្រីបុប្ផាមកដេកជាមួយដែរ ? ឯនាង

បុប្ផាក៏ឆ្ងល់ខ្លាំងណាស់ដែរ ខ្លួននាងដេកលើផ្ទះសោះម្ដេចក៏មកដេកស្រាតក្រោមផ្ទះជាមួយនាយប្រុសទៅវិញ ។ នាងឃើញខ្លួនស្រាតទទេលនោះ នាងខ្មាស់គេណាស់ ទំរាំយកសំពត់អាវមកបិទបាំងកេរ្តិ៍ខ្មាស់ ដោយគ្មានពាក្យអ្វីនិយាយទៅកប្ដីបន្តិចសោះឡើយ ។ នាងគិតតែយំសោកដោយហួសចិត្តខ្លាំងពេក ។

ព្រះតេជៈគុណគញ្ចាស់ណាលឃើញជាក់ស្ដែងនឹងភ្នែកពេកយ៉ាងនេះ ក៏ជឿតាមសំដីប្រពន្ធដើម ហើយសំគាល់ថានាងបុប្ផាជាស្រីខូចស្រីបង្រៀមែន ។ ដោយគាត់ខឹងខ្លាំងពេកទប់មិនបាន ក៏ស្ទុះទៅសំពងនាងបុប្ផានឹងឈើប្រតនោះប៉ុន ប៉ុនបក្បាលថែមទៀត ។ ក្បាលនាងធ្លាយឈាមក៏ហូរមកប្រឡាក់ពេញមុខនិងខ្លួនប្រាណដោយឈឺខ្លាំងពេក នាងស្រែកគួរឱ្យអាណិតថា :

– "អូយ..., បង... ខ្ញុំមានផ្ទៃពោះផង អូយ

ព្រះអើយជួយខ្ញុំផង,, ស្រែកបានតែប៉ុណ្ណោះម៉ាក់ក៏ដួលសន្លប់បាត់ទៅ ។ បុប្ផាមិនគ្រាន់តែត្រូវប្ដីធ្វើបាបវាយដំប៉ុណ្ណោះទេ នាងត្រូវប្រពន្ធដើមគេតាំងពីរតាំងបីធ្វើបាបលើសប្ដីនាងទៅទៀត ។ គេអូសគេទាញគេរុញច្រានច្បាបសក់វាយធប់ត្រឡប់ត្រឡិន ហើយបណ្ដេញនាងឲ្យចេញពីផ្ទះនោះទាំងអាក្រាត ។ បុប្ផាមិនដឹងជាធ្វើអ្វីគេបាន ក៏អង្គុយគិតថា ៖

-ប្ដីសំឡាញ់របស់អូន អូនមិនក្បត់ប្ដីទេ អូននៅតែប្ដីណាស់ នោះតែហើយស្រឡាញ់ប្ដីលើសជីវិតខ្ញុំទៅទៀត លោកប្ដីអើយអូនដេកលើផ្ទះសោះមិនដឹងជានរណាគេយកខ្ញុំមកឡើងដេកនៅទីនេះទេ សូមលោកប្ដីអាណិតប្រពន្ធផង ខ្ញុំមិនដឹងជាទៅប្រែតាមខ្លួនណាទេ ខ្ញុំនៅម្នាក់ឯងកំព្រាឥតឪពុកម្ដាយ មកនៅទីក្រុងភ្នំពេញនេះគ្មានស្គាល់នរណាម្នាក់សោះ មួយទៀតខ្ញុំមានផ្ទៃពោះផង បើ

លោកប្ដីលែងខ្ញុំក៏លែងចុះ តែសូមលោកប្ដីករុណាមេត្តាឲ្យខ្ញុំសុំជ្រកកោនធ្វើជាខ្ញុំបំរើផងក៏បានដែរ ទំរាំឲ្យខ្ញុំសម្រាលកូនហើយសិន ។

បុប្ផាអង្វរយ៉ាងណា ក៏តាចាស់មិនព្រមស្ដាប់ដែរ រិតតែក់យោផុះបណ្ដេញឲ្យនាងចេញពីផ្ទះគាត់ ក្នុងពេលយប់នោះជាដាច់ខាត ៖

— ចេញពីផ្ទះអញភ្លាមទៅ អញមិនត្រូវការយកស្រីថូបមេតិរប្វានឯងមកធ្វើជាប្រពន្ធទេ បើមិនព្រមចេញពីផ្ទះអញឥឡូវនេះទេ ប្រយ័ត្នស្លាប់ខ្លួនណា៎ . . . ឯងផើមនេះក៏មិនមែនផើមដោយសារអញដែរ ឯងដើរទៅផើមព្រៃជាមួយគាណាផ្សេងទៀតឯណោះទេ ចុះចេញពីផ្ទះអញភ្លាមទៅមេកំពូជតា អញលែងត្រូវការឯងទៀតហើយ ។

និយាយរួចព្រះតេជគុណកញ្ចោស់ប្រាខនាងបុប្ផា

www.elibraryofcambodia.org

ផ្លូវត្រឡប់ត្រឡិនព្រមទាំងក៏យកគប់ ហើយបង្គាប់ទៅប្រពន្ធដើម ១ ទាំងនោះថា :

—កូនទាំងអស់គ្នា ចាំអីទៀត ឆ្កួសក៏យកទៅបោះចោលខាងក្រោយបង្គន់ទៅ កុំទុកក៏ទាំងតែចង្រៃផ្ទះយើងទៀតទេ..,

ប្រពន្ធដើមទាំងនោះ គ្រាន់តែប្ដីនិយាយចប់ ក៏ឆ្កួសទាញបុប្ផាយកទៅចោលខាងក្រៅភ្លាម ៗ ពេលនោះនាងស្រីអភ័ព្វហាក់ដូចជាវង្វេងស្មារតី មិនដឹងជាគិតទៅខាងណា ? ខឹងគិតចូលទៅក្នុងផ្ទះសុំអង្ករគេម្ដងទៀត ក៏ចូលទៅមិនរួចព្រោះគេបិទទ្វារចាក់សោជាប់ បើទុកជាចូលទៅរួចក៏គ្មានបានប្រយោជន៍អីដែរ ទាំងតែឲ្យគេធ្វើបាបឈឺសាច់ឥតប្រយោជន៍ ម្ល៉ោះហើយនាងគិតតែពីអង្គុយយំសោកខ្សឹកខ្សួលម្នាក់ឯងក្រោយបង្គន់ផ្ទះនោះ ដោយក្ដីអស់សង្ឃឹម ។ នាងមិនទាន់ហ៊ានធ្វើដំណើរទាំងយប់នោះភ្លាមទេ ព្រោះខ្លួនជាស្រី ក៏អង្គុយសំកុកត្រង់មាត់ទ្វារផ្ទះនោះត្រម៉ង

ត្រាមោឃម្នាក់ឯងនឹងចាំព្រះគង់ចិន្ត្យរះឡើងពីមុនធ្វើដំណើរ... ។

ចំណែកនាយប្រកយុវជនកំសត់ ក៏ត្រូវព្រះតេជគុណកញ្ចាស់ដេញក្បាលហាលកណ្ដាលពេលយប់នោះដែរ តែបានគុណបុណ្យលោកស្រី ១ ជាប្រពន្ធដើមរបស់តាចាស់មួយធ្វើអន្តរាគមន៍ជួយសង្គ្រោះ... ក៏បានទៅធ្វើការឱ្យតាកញ្ចាស់ក្រោយពេលនោះតទៅទៀត ។

# ៥

## ពូអន្ទត់

ព្រឹកឡើងភ្លឺស្រាង ៗ នាងបុប្ផាដើរចេញពីមុខផ្ទះតាចញ្ចាស់ដោយដំណើរធេងធោង ៗ ព្រោះនាងខ្សោយកម្លាំងណាស់ទៅហើយ នាងមានផ្ទៃពោះផងថែមទាំងអត់ងងុយមួយយប់ទល់ភ្លឺទៀត ណាមួយនាងឈឺចុកចាប់ពេញខ្លួនប្រាណគ្រាំគ្រាពេលគេធ្វើបាបនោះ ៗ នាងមមាយដើរបណ្ដើរថ្ងូរបណ្ដើរ ចេះតែដើរទៅមុខទាំងញ័រញ៉ែ គ្មានគោលដៅជាក់លាក់ថាដើរទៅទិសតំបន់ណាទេ បំណងនាងគឺចង់ដើរគេចចេញឱ្យបានផុតពីមុខផ្ទះតាចញ្ចាស់តែប៉ុណ្ណោះ ៗ នាងគិតត្រឡប់ទៅស្រុកកំណើតវិញ មិនស្គាល់ផ្លូវមិនដឹង

ជាំទៅតាមណា ហើយសោហ៊ុយក៏ត្រូវមួយសេនដែរ ។ ណាមួយឆ្ងាយជិតទៅខ្ចាស់ញាតិកន្ទុម ព្រោះខ្លួនមានផ្ទៃពោះយ៉ាងនេះនាំឲ្យគេហៅថា ខ្លួនផើមមិនដឹងប្ដីនៅឯណា ហើយរាំងខ្ពត់ចិត្ត ក្ដៅក្រហាយខឹងអុំផែធ្វើបាបនាងយកមកលក់ . . . ។ បុប្ផាក៏ប្ដូរជាស្ទើព្រាំនៅឱ្យស្ដាប់កន្ទីទី ក្រងឹកពេញតែម្នាក់ឯងទៅចុះ ពោះត្រូវធ្វើជាអ្នកធ្វើជេរឲ្យតែមានជនៃវស់សិន សើមគិតតទៅទៀត ។ នាងគិតសព្វ ១ ទៅយល់ឃើញថា បើធ្វើជាស្រីពេស្យាក៏ស្រួលផែនោបបានសោហ៊ុយធ្វើដំណើរទៅមុខ ។

— « ខ្ញុំ / ស្រី ១ តាំងឡាយដែលធ្លាក់ខ្លួនទៅជាស្រីខូចប្រហែលជាមកពីមានហេតុដូចជារូបអញនេះមួយកាតផែរហើយមើលទៅ ? ក៏ប៉ុន្តែពោះជាយ៉ាងណាក៏ត្រូវតែតស៊ូសិនផែរ ព្រោះធ្វើស្រីពេស្យានាំឲ្យគាប់ទុខខ្ចូបតួផគម្ពុណាំខ្មែរខ្លាំងណាស់ » (នាងបុប្ផាពោលតែម្នាក់ឯង )។

នាងគិតឃើញដូច្នេះ ក៏តាំងចិត្តស៊ូមិនត្រូវទៅធ្វើជាស្រីពេស្យាទេ នាងតាំងចិត្តរក្សាកេរ្តិ៍ខ្មែរឲ្យល្អស៊ូស្លាប់ជាជាង ៗ ក៏គន់តែគិតដូច្នេះ ស្រាប់តែនាងងើបមើលឃើញខ្លួននាងដើរមកដល់ផ្សារកណ្ដាល ។ បុប្ផាដើរទៅឈរ នៅក្រោមដើមពោធិ៍ត្រង់កាច់ផ្លូវវត្តឧណ្ណាលោមជិតប៉ាំតា សម្លឹងមើលទៅផ្សារកណ្ដាល ដោយមានទឹកមុខស្រងូតស្រងាត់ កើតទុក្ខជាខ្លាំងមិនដឹងជាទៅប្រកណា ។ នាងក៏គន់តែឈរកើតទុក្ខនោះស្រាប់តែឃើញបុរសម្នាក់មានវ័យចាស់បន្តិចហើយ បុរសនោះក៏បុតដៃម្ខាងផង គាត់ស្លៀកខោប៉ាំងជើងវី ខ្លួនខេប្រឡាក់ដីស្រមក ពាក់ក្បាលមួយចំហៀង ខុតស៊ក់មួយចំហៀង មុខមាត់គាត់មានលាបឡេង លាបកំបោក្រហមក្រម៉ៅមើលជាមនុស្សគួរលីលាបាតផ្សារ ។ ពួកអ្នកនៅទីក្រុងភ្នំពេញតាំងពីចាស់ទាំងក្មេង ហៅបុរស

កិបុតដៃនោះថាតួ «អន្ទិត» ៗ គ្រប់ ៗ គ្នា ៗ តួអន្ទិតដើរ ទៅកន្លែងណា ក្មេង ៗ តែងតាមពោមពេមគ្នាជុំជិត ៗ គាត់សើចហើហាហោតកញ្ចែនចេញពីក្នុងផ្សារ តម្រង់មក ក្រោមដើមពោធិ៍ដែលនាងបុប្ផាកំពុងឈរនោះដែរ ៗ លុះ មកដល់ គាត់ចូលទៅដកទឹកក្នុងត្រួដែលគេកំពុងដកក្បែរ នៅក្បែរគល់ពោធិ៍នោះ ៗ ពេលត្រូវទឹកក្នុងតួមួយតយ ក្លាយ តួអន្ទិតក្រោកទៀងឈរឆ្កោងដៃផ្កាជើងនិយាយពោក ឆាក ៗ ថា :

– អាតាវ្រូយ៍ កាក្លើផស្សារៈខ្វាចបាក់ជើងឆ្កាបខ្វា ទៅទៀត កាត្លៃកបានតែជាមួយផងតែខ្មែរតាងឯងទេ មនុស្ស ដូចអាតាវ្រូយ៍ គឺមនុស្សកំសាកញ៉ាកាក្លើផស្សារៈប៉ុនប្រាំផ្នា គ្មានបានផលប្រយោជន៍អ្វីដល់ប្រទេសជាតិសោះ មានតែបំ ផ្លាញជាតិទៅវិញ កាផុនវត្តអារាម ដុតគម្ពីរដីកាព្រះពុទ្ធ សាសនា ផុតផ្ទះគួតស្រុក បង្ខាច់ខ្មែរជាតិឯង ល្បែង

ព្រាត់ប្រាសប្រគន្ធកូនចៅ បំផ្លាញទ្រព្យសម្បត្តិអ្នកស្រុក គោក្របី មាន់ទាជ្រូកទៀតវិនាសអន្តរាយតែប៉ុណ្ណោះ អាចារ្យយើងមិនមែនជាអ្នកសង្គ្រោះត្រឹមត្រូវទេ គឺជាមេចោរព្រៃ មើលចុះដៃកាប់គេរបស់ខ្លួនអាចារ្យយើងបាញ់ នេះហើយគាត់ស្មុយជាតិរបស់វា យើងគួរតែកុំហៅវាថាអាចារ្យយើងមិនសមទេ ត្រូវហៅវាថាមេចោរយើងវិញទើបសម ៗ

ពូអគ្គិតនិយាយមកដល់ត្រឹមនេះ គាត់ក្រឡេកទៅឃើញនាងបុប្ផាកំពុងឈរទ្រឹងជិតគាត់នោះ គាត់ក៏ស្ទុះវិ្ហតចូលទៅរកនាង ហើយញាក់ចិញ្ចើមត្រិត ១ ដែរជាំងប្រៀងកំពាក់ក្បាលជាតនាងទៀតផង ៗ

បុប្ផាកំពុងកើតទុក្ខផង កាលឃើញពូអគ្គិតលេងផ្តេសផ្តាសមករកនាងដូច្នោះនាងទំលើរគេបញ្ចេញ តែពូអគ្គិតបេះតែដើរតាម ៗ លុះទៅដល់មុខវត្តឧណ្ណាលោម បុប្ផាឃើញព្រះគិលានកំពុងអង្គុយចាំនៅលើបល្ល័ង្ក កង

សួនបុប្ផាមុខវត្តនោះ ដោយមានឈានជួបហុយក្រទោល ស្រាប់ផង នាងក៏ចូលទៅថ្វាយបង្គំបន់សុំឲ្យព្រះគំលង់ជួយស្រោចស្រង់ជីវិតនាងឲ្យបានសុខ ៗ កំពុងតែបន់ស្រន់ស្រាប់តែតួអង្គត់ដើរលេង ៗ ពីក្រោយខ្នងចូលទៅជិតហើយនិយាយទៅកាន់នាងបុប្ផាថា :

— អូន ! អូនបន់ព្រះគំលង់ធ្វើអី អូនបន់ប្រាថ្នាសុំឲ្យបានបងធ្វើជាប្ដីរបស់អូនឬ ? មិនបាច់បន់ទេអូនមាសព្រលឹងបង បងសុខចិត្តធ្វើជាប្ដីរបស់អូនហើយ ស្រឡាញ់បងមកមាសស្នេហ៍ព្រលឹង បងសុខចិត្តធ្វើជាប្ដីហើយ ៗ

តួអង្គត់និយាយចប់ តាគត់ស្ទុះរឹងចាប់នាងបុប្ផាឱបជាប់ ហើយថែមទាំងថើបញីញាក់ធ្វើឲ្យថ្ពាល់ដ៏ផូរផង់របស់នាងប្រឡាក់ល្បាងទឹកមាត់ហោរដូចមុខមាត់គាត់ដែរ ។ បុប្ផាខំរើបម្រះស្រែកឲ្យគេជួយដែរ តែគ្មាននរណាមកជួយនាង

នោះ ៗ មានស្រីចិនចាស់ ១ ពីរបីនាក់ដែលទៅបន់ព្រះតិលង់ដែរនោះ គាល់ឃើញផ្លូវហោះគេរត់យកតែប្រាណឈ្មុះ . . . ៗ ម្លោះហើយបុប្ផាចំរើនឈប់ចិត្តបាច់ណាមួយពួកអន្ធពាលដែលបានញញើញទើបរួចហើយ ក្រញៀវព្រុំខេះឆប់ពួកអន្ធពាលត្រូវពីរបីដៃដែរ ៗ

ពួកអន្ធពាលឃើញថានាងបុប្ផា មិនព្រមស្រឡាញ់គាត់នោះ គាត់បញ្ចេញស្បៀតមួយទៀត ដីកំហែងកំហល់និយាយសំឡុតថា ៖

— នាងស្រីរូបល្អពៅ កុំមើលងាយតាអន្ធពាលដៃធ្ងន់ណា៎ អញខ្ញុំណាស់ស្រើកដែបនាងឯងនេះ ថែមលុយឲ្យអញទៀតផងក៏អញមិនត្រូវការដែរ ស្ទ្រមៈនលុយប៉ុន្មានត្រូវឲ្យមកអញទាំងអស់ បើមិនឲ្យទេអញសម្រាតសំពត់អាវយកអស់ស្ទ្រើហឹង . . . ៗ

និយាយចប់ក៏ស្ទុះទៅកញ្ចញ្ជប់ណាងនិងសម្រាតយក

សុំតែការពិតនាងបុប្ផាមែន ៗ ពេលនោះនាងយំសំ-ពះអង្វរគ្រូអង្គថា៖

— លោកគ្រូកុំធ្វើបាបខ្ញុំ ខ្ញុំជាស្រីកំព្រាអនាថាជាប់សង្វៀន មួយជាតិនេះខ្ញុំមិនដែលបានស្គាល់សេចក្តីសុខសប្បាយម្តងណាទេ ស្គាល់តែទុក្ខលំបាកវេទនារាល់នាទី លុយកាក់គ្មានមួយសេនសោះ សូមលោកគ្រូកុំធ្វើបាបខ្ញុំ...ៗ

— មិនបាច់និយាយច្រើនទេ បើចង់សុខឲ្យលុយមកអញភ្លាម ឲ្យលឿនឡើង កុំបង្អង់យូរពេកអញនិយាយស្រួល ៗ

— ខ្ញុំគ្មានលុយទេលោកគ្រូ បើមិនជឿសូមលោកគ្រូឆែកមើលចុះតែមួយសេនក៏គ្មានផង បើមានខ្ញុំរំលោះស្រេចការណ៍ខ្ញុំវិញហើយ មិននៅឈររងទុក្ខអញ្ចឹងទេ . . .

គ្រូអង្គមិនព្រមជឿតាមពាក្យសំដីនាងបុប្ផាទេ គាត់តែកនៅល្អួតហៅបាវនាងរកឆាយមើលទៀត លុះរកមិន

www.elibraryofcambodia.org

ឃើញមួយសេនសោះនោះ ទើបគាត់សួរទៅនាងថា៖

— នាងឯងមកពីស្រុកណាមក បានជាគ្មានលុយមួយសេនសោះយ៉ាងនេះ?

— បាស... ខ្ញុំនៅស្រុកមេសប្រច័ណ្ឌ លោកតួ...

ពូអង្គត់គ្រាន់តែឮសូរនាងបុប្ផាឆ្លើយប្រាប់ថានាងនៅស្រុកមេសប្រច័ណ្ឌភ្លាម គាត់ហាក់ដូចជាភ្ញាក់រលឹកនឹកឃើញអ្វីមួយ មុខឡើងស្រងូតស្រងាត់ ៗ គាត់លើកដៃកំបុតនោះឡើងលើហើយសួរបញ្ជាក់ទៅនាងម្តងទៀត៖

— យី! នៅមេសប្រច័ណ្ឌ ចុះនាងត្រូវជាកូនចៅអ្នកណា? នាងឯងឈ្មោះអី? ប្រាប់ពូមកមើល ៗ

— បាស... ខ្ញុំ...ឈ្មោះ...បុប្ផា ...ម្តាយខ្ញុំឈ្មោះផន ស្លាប់បាត់ទៅហើយគាត់ស្លាប់តាំងពីខ្ញុំនៅអាយុ ១៣ ឆ្នាំម្ល៉េះ។ គាត់ស្លាប់ដោយសារពួកបារាំងបាញ់សម្លាប់ ព្រោះក់ទង ចោទថាម្តាយខ្ញុំឲ្យបាយពួកឥស្សរៈស៊ី ចំណែកឪពុកខ្ញុំ

ឈ្មោះផនិ ក៏គាត់ស្លាប់ដែរ មានពេលយប់មួយនោះ ពួកអាពតយៀមមកឡោមព័ទ្ធផ្ទះខ្ញុំ ហើយ ទាញសម្លាប់ឪពុកខ្ញុំយកទៅចោលក្នុងទឹកទន្លេមុខផ្ទះបាត់ ព្រោះវាខឹងនឹងឪពុកខ្ញុំឲ្យបាយបារាំងស៊ី . . . ស្រុកខ្មែរយើងសព្វថ្ងៃនេះ ដូចលោកពូដឹងស្រាប់ហើយ បើយើងត្រូវខឹងបារាំងពួកឥស្សរៈគេខឹង បើយើងត្រូវខឹងឥស្សរៈវិញក៏បារាំងខឹងដែរ បើយើងធ្វើមិនដឹងមិនឮទៅ មិនទទួលស្គាល់វាទៅ វាចេះតែបូលទៅបង្គាប់បញ្ជា យើងមិនធ្វើតាមវា វាចោទថាយើងបក្សពួកខាងណោះខាងណេះ ហើយវាសម្លាប់យើងចោលទទេ ១ ហ្នឹ . . . ពិបាកណាស់ . . . ព្រះអើយ . . . លុះឪពុកម្តាយខ្ញុំស្លាប់ចោលខ្ញុំទៅ ខ្ញុំទៅនៅជាមួយម្តាយធំខ្ញុំឈ្មោះផៃ ប្តីគាត់គេហើយប្អូនទៀតគាត់ឈ្មោះគុំទួន ដល់ខ្ញុំធំឡើងគុំផៃគាត់រៀបចំខ្ញុំឲ្យមានប្តីមកនៅភ្នំពេញនេះបានប្រាំខែហើយ ឥឡូវនេះខ្ញុំមានផ្ទៃ

ពោះជាងគឺវាំងទៀតផង ព្រោះតែគេបោះបង់លែងខ្ញុំ ចោល គេធ្វើបាបខ្ញុំ . , . ប្រពន្ធដើមគេតាំងពី តាំង បីព្រិត្តគ្នាគិតសម្លាប់ខ្ញុំ យប់មុញនេះគេធ្វើបាបខ្ញុំសាហាវ ណាស់ . . .

នាងបុប្ផានិយាយរៀបរាប់ប្រាប់ត្បូងអគ្គិតបានតែប៉ុណ្ណោះ កំពូលដើមគគីរទ្រងនិយាយយំលែងចេញ ៗ ចំណែកត្បូង អគ្គិតវិញព្រោះតែគាត់ទ្រហោយំឡើង ហើយស្ទុះទៅឱប នាងបុប្ផាដាច់យំរៀបរាប់ថា :

— បុប្ផាកូនស្រីមាសឪពុក កូនធំប៉ុណ្ណេះទៅហើយ បុប្ផាកូនគើយឪពុកមិនទាន់ស្លាប់ទេ យើងជួបគ្នាវិញហើយៗ

កាលត្បូងអគ្គិតយំរៀបរាប់ ឱបនាងបុប្ផាដាប់នោះ នាង មិនជឿតាល់តែសោះ នាងរើបំរះ ហើយស្តីឲ្យត្បូង អគ្គិតវិញ :

— យី ! ត្បូងឯងនេះខូចណាស់ មុនដំបូងមកស្នេហា

ខ្ញុំ រួបបួនគិតសំរេចយកសំពត់អាវ ឥឡូវមកបោកប្រាស ធ្វើជាឪពុកខ្ញុំទៀត ឪពុកខ្ញុំអាចារ្យយើសម្លាប់បាត់ទៅហើយ កុំមកភូតកុហក ។

– ប៉ុញ្ញាកូនស្រី ម្ដេចក៏កូននិយាយឲ្យឪពុកអញ្ចឹងទៅវិញ អញហ្នឹងហើយឈ្មោះផន់ជាឪពុកកូនឯង ឪពុកមិនទាន់ស្លាប់ទេ តែអ្នកផងគេមិនហៅឈ្មោះផន់ទេ គេហៅឪពុកថាតាអន្ទិត ៗ ទៅវិញព្រោះគេឃើញដៃឪពុកកំបុតអន្ទិតម្ខាងនេះ នៅពេលយប់នោះកូនស្រីឯងកំពុងដេកក្នុងផ្ទះ អាចារ្យយើមកតែងផ្ទះយើង ឪពុកទំរាំកំបុះទៅក្នុងទន្លេបួក គ្រមាំក្រោបតែបាញ់កាំភ្លើងមកត្រូវចំដៃម្ខាងនេះ ដូចកូនឃើញស្រាប់ ពេលនោះឪពុកទំភ្លង់ខ្លួនមកដល់ត្រើយនាយ អង្គុយសំកុកមាត់ព្រាំនឹកអាល័យតាណនិងកូនណាស់ តែមិនហ៊ានឆ្លងត្រឡប់ទៅវិញខ្លាចគេសម្លាប់ លុះឃើញភ្លើងឆេះផ្ទះយើង ឪពុកនឹកក្នុងចិត្តថាកូនឯងស្លាប់ក្នុងភ្លើងនោះបាត់

នៅហើយ   មួយទៀតយប់នោះឪពុកឈឺចាប់បួសដៃនេះពេកក៏ប្រថុយតែមកឲ្យគ្រូមើលនៅភ្នំពេញ   លោកគ្រូកាត់ដៃឪពុកកំបុតរួចព្យាបាលជាពាល់សព្វថ្ងៃ   ពលជាក្លាយឪពុកពិតត្រឡប់ទៅស្រុកវិញដែរ   តែដល់ខែសព្វ ១ ក៏មានទៅវិញព្រោះម្ដាយកូនឯងក៏ស្លាប់   កូនស្រីឯងឪពុកស្មានជាស្លាប់ដែរ   ផ្ទះក៏ឆេះអស់   ហើយស្រុកក៏មិនទាន់បានសុខស្រួល   ម្នោះហើយឪពុកក៏ស៊ូទ្រាំរស់ចាំងត្រដរនៅភ្នំពេញនេះរហូតមក ឥឡូវយើងបានជួបគ្នាវិញហើយ ដ៏វិតយើងចាំងតែនោកថ្ងៃណាស់   ចាប់តាំងពីថ្ងៃនេះទៅយើងលែងព្រាត់ប្រាសគ្នាហើយណាកូនស្រី . . .

ពូផន់   (ពូនអគ្គត់)   និយាយរៀបរាប់ដូចនេះរួចទើបនាងបុប្ផាដឹងថា   ពូអគ្គីពិតជាឪពុករបស់នាងមែន ៗ ចាំងពីនោកឪពុកនឹងកូនស្មានពាក្យសួររកគ្នាទៀតទៅផ្លូតចិត្តរៀងៗខ្លួនគិតតែយំស្រែងស្រោងដោយថ្លែងសេចក្ដីខេតលើក

គ្នាទៅវិញទៅមកនៅមុខព្រះគំលង់ ។ ពេលនោះបើសិនជាព្រះគំលង់ចេះនិយាយចេះដើរដូចមនុស្សវិញ ប្រហែលជាលោកចុះពីលើបល្ល័ង្កមកល្បួងលោមជនកំសត់ទាំងពីរនាក់នេះមិនខានឡើយ ។ តែផ្ទើម្ដងដុំថ្មនិយាយមិនកើតសើចពុំរួច នៅតែអង្គុយថែងថែងលើបល្ល័ង្កសំឡក់សំឡឹងមើលមកពូផង់និងបុប្ផា ហាក់ដូចជាជួយឈឺចាប់ពេកណាស់ ។

បន្តិចក្រោយមកពូផង់ (ពូគង់) បាត់យំទៅវិញ គាត់នឹកឡើងដូចជាខ្មាសបុប្ផាកូនរបស់គាត់ណាស់ ដូចគ្នាមុនដំបូងប្រៀនកញ្ញាក់មុខញាក់មាត់កំប្លុកកំប្លែងលេងល្បែងស្នេហាឧបរិត ក្រោយមកបន្ទន់កំហែង ធ្វើអំពើនេះជោកចាប់ជាទីបំផុត ហើយមិនធ្វើទៅលើនរណា ធ្វើតែលើកូនស្រីជាទីស្រឡាញ់របស់ឯងទៀត ។ ដោយខ្មាសពេកគាត់គិតក្នុងចិត្តថានឹងតែលែងឲ្យកូនឃើញមុខម្ដងទៀត ។ ប៉ុន្តែមុននឹងរត់ គាត់និយាយប្រាប់បុប្ផាឲ្យបានដឹងថា:

www.elibraryofcambodia.org

– កូនស្រី! ឪពុកសូមជួបកូនតែប៉ុណ្ណេះបានហើយ ព្រោះឪពុកនឹងរស់ជាមនុស្សតទៅទៀតមិនកើតទេ សព្វថ្ងៃឪពុកបុះបោក់ទៅជាមនុស្សធ្ងន់ទំលខ្លួនបល្មបង្អួនទេ គឺហោចជាងសត្វតិរច្ឆានទៅហើយ សូម្បីតែកូនឯងក៏បានគិតធ្វើបាបដែរឪពុករស់នៅទៀតមិនកើតទេ ក៏ខូចខាតអស់ហើយ ហើយកូន គាំងពីទ្រព្យសម្បត្តិផ្ទះសម្បែង ប្រពន្ធ... កូនឯងទៀតក៏បានព្រាត់ប្រាសពីឪពុក ខ្លួនឪពុកនេះក៏កំបុតដៃហើយធ្លាក់ខ្លួនទលក្រ ទាល់តែយកអំពើបាបគ្រប់យ៉ាងមកទប់ទល់គ្នា ពីម្សិលមិញនេះទេ យ៉ាងណាក៏ពុំបានប្រាក់សោះ ស្លួមតាមគេក៏គេពុំឱ្យ ដើរទៅរើសកាយរកចំណីអាហារស្អុយរលួយពីគំនរសម្រាម យកមកបណ្ដោះឃ្លាន ក៏គេដេញបញ្ចេញកក់យកគប់ មានថ្ងៃណាមួយនោះទាល់ប្រែសុខចិត្តដេកអត់បាយ កូនមើលឪពុកបុះស្គមនៅតែស្បែកនិងឆ្អឹង ចំណែកកូនស្រីឯងទៀត បើស្លាប់

www.elibraryofcambodia.org

ទៅក្រោយ នេះបែរជាមករងទុក្ខវេទនាឲ្យគេធ្វើបាប ខានថ្ងៃ ព្រោះគេបានបង់ពេលទៀតលេងគោលនៅកណ្តាលផ្សារយ៉ាង នេះទៅវិញ ហ៊ឹ. . .ព្រឹកមិញឪពុកលក់ត្រកួនផ្សារបាន ៣០រៀល ផែរឲ្យកូនឯងយកធ្វើជាសោហ៊ុយទៅស្រុកវិញទៅហើយ កូនទៅនៅជាមួយបងថ្លៃទៀតចុះ បំណងឪពុកជួបនឹងកូន តែប៉ុណ្ណោះបានហើយ ចូរកូនឯងចំប្រើនសុខសាន្តទៅទៀត ចុះ ខ្លួនឪពុកយល់ថាអស់សង្ឃឹមនឹងរស់តែម្តងហើយ...

ពួជ៏និយាយចប់ ក៏ស្ទុះរត់សំដៅចុះទៅក្នុងបំណងលោត ទឹកសម្លាប់ខ្លួន ។ ឆាន់ប្រញាប់ស្រែករត់ទៅតាម លុះដល់ មាត់ទឹកទៀបនឹងលោត ឆាន់ចាប់ជាប់ ហើយលុតជង្គង់យំ ឱបជើងឪពុកនិយាយតទៅ :

— លោកឪពុកជាទីគោរព ! យើងបានជួបគ្នាវិញ ហើយ ម្តេចក៏លោកឪពុកគិតយ៉ាងនេះទៅវិញ កូនបានជួប លោកឪពុកកូនសប្បាយចិត្តណាស់ ទុក្ខតាំងអំឡុងមាន

ក៏កូនឲ្យខ្ញុំស្បៀងអស់ទៅហើយ ឥឡូវយើងត្រឡប់ទៅស្រុកកំណើតយើងវិញ ។

— ទេ . . . ទេ . . . ទៅមិនកើតទេកូនស្រី កូនតាណិតផុតពុកផង ពុកចាស់ពេកណាស់ កើតមកជាមនុស្សមិនគេដែរទេខុសគេឯង ម៉្យាងទៀតស្រុកទេសយើងមិនទាន់ស្រួលបួលយើងទៅធ្វើអ្វីនាំតែពិបាកចិត្តកើតទុក្ខ កិតក៏យើងនឹងពួកអាចោរហោខ្មៅអស់នោះទៀតទេ ដូចកូនស្រីឯងដឹងស្រាប់បន្តិចបាក់នឹងចូលទៅលុកលុយបន្តិចផ្សាររះបន្តិចហោរប្ចន់បន្តិចយៀកមុញចាប់យកទៅធ្វើបាបមិនទាន់ទៅស្រុកវិញទេ សុខចិត្តស្លាប់នៅទីនេះប្រសើរជាង

បុប្ផាឮសំដីពុកនិយាយដូច្នេះ នាងក៏ស្រណោកចិត្តចាក់ចង់ទៅស្រុកវិញដែរ ព្រោះខ្លាចពួកអាចោរហោខ្មៅធ្វើបាប តែនាងគិតថាបើពុកនាងមិនព្រមទៅ ក៏ហ៊ាចុះកុំឲ្យតែរត់ចោលនាងទៀត នាងនិយាយអង្វរថា :

www.elibraryofcambodia.org

— លោកឪពុក បើលោកឪពុកមិនទៅស្រុកយើងវិញទេក៏ហើយចុះ តែសូមលោកឪពុកកុំទៅណាពេលកូនទៀត . . . បើទៅពេលកូនទៀត កូនមុខជាស្លាប់ពេលនេះហើយ . . .

ពូផង់គាណិតកូនណាស់ឈរសម្រក់ទឹកភ្នែក តែគាត់ខ្មាស់គេពេកមិនអួរណាមកបំពារបំពានលើកូនឯងសោះ ៗ មចផស់ពេលនេះតោះខ្មាស់អៀនយ៉ាងណាក៏ដោយ ពូផង់តែងមានគំនិតនិងរត់ពេលកូនទៅលោតទឹកសម្លាប់ខ្លួនហើយ គាត់តាំងចិត្តជាទីបំផុតថែរក្សាកូនទៅនៅក្រុងភ្នំពេញនេះសិនចាំពេលណាឱកាសល្អទើបនាំគ្នាត្រឡប់ទៅស្រុកកំណើតវិញ ។

# —១០—

## ពងមាន់កុំជល់នឹងថ្ម

ដើរឿយស្រុកកើតអសន្តិសុខ មិនហ៊ានវិលត្រឡប់ទៅស្រុកកំណើតវិញនោះ ពួកជនចិននាងបុប្ផានាំគ្នាសំនៅទីក្រុងភ្នំពេញយ៉ាងសែនវេទនា ខ្វះខាតខ្វះផ្ទាំងរំពឹង បាយកញ្ចប់ស្លឹកឈូកទិញពីផ្សារ ហើយយកសំយាបផ្ទះចិន-យួនមុខផ្សារកណ្ដាលផ្សារថ្មីធ្វើជាទីជម្រក ។

នាងបុប្ផាជាក្មេងស្រីស្អាតគ្រាន់ណាស់ ហើយមានគំនិតល្អ នាងខំបំពេញចិត្តឪពុកនាងមិនឲ្យដើរចក់ក្តោតជួផឹកស្រាទេ ឯកំពើឆក់ឡាក់វិលខួចក៏នាងអង្វរឪពុកនាងមិនឲ្យប្រព្រឹត្តទៅទៀតដែរ ។

ថ្ងៃដាំបាយឆ្អិនមិនដែលកំសត់តាំងពីរោគកង្វះទឹកកូនទេ សុំស្រូវទិញលក់ៗ របស់ស្រូវទិញនេះមិនអាចឲ្យដូនទុកនៅនេះបានច្រើនទេ ក៏គ្រាន់តែញ៉ាំងជីវិតឲ្យរស់បានមួយពេលៗ តាំងតែដាំបាយគ្រប់ស្ប៊ុណ្ណោះឯងៗ ក្ដួចដីទំស្រូវស្ទឹងនេះទៀត ណាងបុត្តាចំជួយរញ្ជួតក្រោយ មើលទៅគួរឲ្យកើតសេចក្ដីសង្វេគណាស់ក្ដួចដីដែកបុត្តមាន ពណ្ណ៌ណាគណាងបុប្ផាវិញគប់ផ្ទុំពោះ... ហើយទំស្រូវទិញលក់តាំងពីកណ្ដាលថ្ងៃក្ដៅតាំងយប់អាត្រាត្រូវគ្រប់ប្រាកល្ហកងីទំក្រែងៗ ជួនលក់ទឹកមិនដាច់ ត្នានប្រាក់ឲ្យថ្ងៃឈ្នួលនេះទេ...ៗ

របស់នេះយាប់ណាស់ហើយ ដោយបុប្ផាណាងមានផ្ទៃពោះការនៃតែចាស់ទៅផងទំនុំហាវផង ហើយដោយគ្រាំគ្រាកាលនៅក្នុងជំរំជាក់ស្រែចាញ្ញកាលពីមុននោះផង ណាងមានសុខភាពមិនសូវស្រួលទេ មួងណ៍...មួងជា ជារួបឈឺទៀត...មិនសូវឈប់ឈរសោះ...ៗ

ក្ដួចដីឃើញកូនទុនទុកវេទនាបែបនេះ គាត់មានចិត្ត

អាណិតកូនខ្លោចផ្សា ហើយម្ដាយនឹកគិតដល់ទៅប្ដីនាងបុប្ផាដែលរាយធ្វើបាបកូនគាត់ឲ្យត្រាំត្រានោះ គាត់ក៏សួរបុប្ផាទាំងការក្ដៅក្រហាយថា :

— អាណាមួយប្ដីកូនឯង ផ្ទះវានៅកន្លែងណា ? វាធ្វើបាបកូនឯងយ៉ាងនេះអញផេកមិនលក់ទេ កូនប្រាប់ឪពុកមកមើល ប្ដីកូនឯងនៅកន្លែងណា ? វាហ៊ានធ្វើបាបយើង យើងក៏ត្រូវតែហ៊ានធ្វើបាបវាវិញដែរ ,..

បុប្ផាឮឪពុកសួរដូច្នោះ នាងក៏ភ័យណាស់នាងមិនហ៊ានប្រាប់ឲ្យ ដឹងថាផ្ទះរបស់ប្ដីនាងនៅកន្លែងណាទេ ។ នាងបង់បំភ្លេចរឿងនោះចោល តែឪពុកមិនព្រមស្ដាប់សោះ នាងនិយាយថា :

— បើកូនឯងមិនប្រាប់ផ្ទះប្ដីកូនឯងឲ្យអញដឹងទេ អញនឹងលោតចងកសម្លាប់ខ្លួនចោល តែគួរកូនប្រាប់ដើម្បីអញបាននៅឃើញមុខវា តើវាយ៉ាងម៉េចបានជាថ្លើមទៀ

ម៉្លេះ ? ឲ្យតែអញបានឃើញមុខវាបន្តិចក៏អស់ចិត្តដែរ . . . បើកូនការពិតជាឪពុកស្រឡាញ់ឪពុកត្រូវកូនប្រាប់ភ្លាម ... ។

ប៊ុប្ផាគិតឃើញថាបើមិនប្រាប់ឲ្យឪពុកនាងបានដឹងផងទេ ឪពុកនាងមុខជាខូចចិត្តគំនិតផ្តួលការណ៍ដើម ឬក៏ដេរតែលះគោលគោលនាងទៀតជាមិនខាន នាងក៏ជាប់ចិត្តប្រាប់ តែនាងបានអង្វរថា :

– លោកឪពុក ! បានជាកូនមិនប្រាប់ផ្ទះប្តីខ្ញុំឲ្យលោកឪពុកស្គាល់នោះ ព្រោះគេលែងត្រូវការនឹងយើងទៅហើយ មួយទៀតខ្ញុំមិនចង់ឲ្យមានរឿង ដោយគេធំណាស់ គេមានអំណាចលើយើង តែបើកូនប្រាប់ទៅហើយ សូមលោកឪពុកកុំទៅធ្វើអ្វីគេឲ្យសោះ កុំឲ្យមានរឿងយើងច្រើនណាស់ បើល្អយើងទៅអង្វរគេវិញទាល់ប្រែសេចក្តីដែលគេការពិត គេបែកច្រើនសូម្បីខ្ញុំៈ ពុំមានគុណលើនិងថ . . .

— អើ . . .   នាំអញទៅឲ្យស្គាល់ផ្ទះកាំស៊ិន ហើយបង្ហាញមុខប្ដីកូនឯងឲ្យឪពុកស្គាល់ផង   បើត្រូវគ្នើរ គេគិតគ្នើរដែរ   ឪពុកមិនធ្វើអ្វីគេទេ . . .

បុប្ផាទឹកស្មានថាឪពុកនាងមិនហ៊ានធ្វើអ្វីគេទេ   នាងក៏ស្មុំមុខប្ដីជូនទៅឲ្យស្គាល់មែន ៗ   ដល់ផ្សារកាប់គោមុខផ្ទះព្រះតេជគុណកញ្ចាស់នោះនាងចង្អុលប្រាប់ភ្លាម ៖

ផ្ទះហ្នឹងហើយជាផ្ទះប្ដីខ្ញុំ គាត់ចាស់ណាស់ទៅហើយ អាយុគាត់ជាង៦០ឆ្នាំ នៅតែក្នុងផ្ទះ   មិនសូវដើរទៅណាទេ ៗ

ឪពុកស្គាល់ផ្ទះស្រួលបួល   គាត់ឲ្យនាងបុប្ផាឈប់ចាំរួច គាត់មិនទាន់ចូលទៅភ្លាមទេ គាត់លបទៅផឹកស្រាសពេសប បួនតយសិនព្រោះគាត់តែងថាឲ្យស្រាជួយគាត់ឲ្យមានស្មារតី មានកម្លាំងក្លាហាន ៗ លុះផឹករួចឪពុកចូលទៅក្នុងរបងផ្ទះ ព្រះតេជគុណ   ហើយឡើងទៅដល់លើផ្ទះនោះ   រួចចូល

www.elibraryofcambodia.org

ទៅដល់ចានក្នុងនៃម្ហូប ៗ បន្តិចស្រាប់តែព្រួសស្សួរមាត់គាត់ស្រែកថា :

– តាតាប៉ុនញ្ញាស់ណាមួយ ដែលហ៊ានយកកូនអញមកធ្វើបាប តាឯងសឿងចេញមុខមក អញនឹងតដល់លើផ្ទះតាឯងហើយ តាឯងមើលងាយអ្នកក្រ អញអស់ទ្រាំ ស្លាប់ហើយតា . . . ពេលនេះអញសុំដីតែតាឯងហើយ តាឯងធ្វើបាបកូនអញឲ្យមានផ្ទៃពោះហើយបោះបង់បណ្ដោយចេញ . . . ៗ តួសំដីនិយាយគង់គាត់ទាត់ធាក់ ក់យជញ្ជាំង ក់យតុ ក់យខ្ទុកផ្ទះតាតញ្ញាស់ព្រួស្សួរនៃមុំក្រោម ១ . . . លាយទៀតនឹងសម្រែកតាត់ស្រែកថា :

– តាឯងធ្វើបាបកូនអញឲ្យវេទនា តាឯងមិនរួបខ្លួនទេ អញចាំផុតក្នុងរបស់បុរុសអញក្ដៅណាស់ អញយកដីតែតាឯងឲ្យទាល់តែបាន ទើបអញសុខចិត្ត ៗ

នាងបុប្ផាដែលឈរចាំនៅមុខផ្ទះនោះ លុះឮ

www.elibraryofcambodia.org

ពុកនាងស្រែកឡូឡារាំយកុក់យេខ្លួនគេប៉ុនប៉ុន ៗ នាងភ័យណាស់ នាងនឹកថាគាសន្ធទៅតែហើយ ៗ នាងចង់ចូលទៅឃាត់ហៅឪពុកឲ្យចេញមកវិញ តែចិត្តមិនលុះមិនហ៊ានចូលទៅ ម្លោះហើយនាងប្រាសប្រាលអន្ទះអន្ទែងភ័យខ្លាចគេធ្វើបាបឪពុក ។

ចំណែកអ្នកនៅក្នុងផ្ទះនោះវិញភ័យភើយសែនភ័យ ។ តាចាស់ទឹងប្រពន្ធទាំងពីរទាំងបីនាក់ៗភ័យស្ទើរតែស្លាប់ទៅហើយ ឥតហ៊ានចេញមកខាងក្រៅទេ ម្នាក់ៗនៅតួនតែក្នុងបន្ទប់ ។ ឯនាយប្រុក នាយមឺនិងកាចេង ឈ្នួលបំរើតាកញ្ចាស់ទាំងប៉ុន្មានផាក់មេដាយយកតែរួចខ្លួនបាត់ ។ ពួកវង់នោះតែរាំយកុ រាំយខ្លួលើគពោះទ្រព្យសម្បត្តិតូងតាំងក្នុងកាំងពេញនៃផ្ទះតាកញ្ចាស់គ្មានញញើតអ្នកណាបន្តិចឡើយ ។

តាកញ្ចាស់ស្ដាយទ្រព្យសម្បត្តិគាត់ខ្លាំងណាស់ឮសូរពួកវង់ពោកប្រាស់បាក់បែកនោះ តែមិនហ៊ានចេញមកខាង

ស្លាប់ គាត់វិលវល់ក្នុងចិត្តយ៉ាងសម្បើម ណាមួយភ័យខ្លាចតួឯងទំខ្មោចផញ្ញាំងចូលទៅកសម្លាប់គាត់ ក្នុងបន្ទប់ទៀតផង ។ ម្លោះហើយគាត់ស្ទុះស្ទារប្រាសប្រាលចេញពីបន្ទប់ ចន្លិបក្រោយមកគាត់ស្ទុះទៅទាញយកទូរស័ព្ទនៅលើតុមកនិយាយហៅប៉ូលិស តែទូរស័ព្ទនោះខូចជាយូរមកហើយនិយាយមិនឮសោះ គាត់ស្ទុះទៅរកកាំភ្លើង កាំភ្លើងនៅឯក្នុងបន្ទប់ប្រពន្ធទីពីរឯណោះ ឃើញពិតយ៉ាងណាក៏ដោះ ទៅប្រតណាដោះ ស្លាប់ពេលនេះទេដឹង ?

វាគេចនោះ ស្រាប់តែឃើញឡានប៉ូលិសបើកមកចូលទៅក្នុងផ្ទះតាកញ្ចាស់ ដោយមាននាយប្រុក នាយមី នាយចេងជុំនាំមកជាមួយផង ។ ឡានឈប់ចតត្រង់មាត់ជណ្ដើរ រួចឈ្មួលបំរើតាកញ្ចាស់ទាំងបីនាក់នាំប៉ូលិសទាំង ៤ នាក់នោះឡើងទៅលើផ្ទះក្នាមហើយដេញ

តាប់គួផ្ស័រកំរិតពេញផ្ទះ ៗ ឮស្នូរខាត់ខាយប្រុកស្រែក ខ្លាំងៗ ៖

— តោរ . . . តោរ . . . តោរបួន . . . តាប់ . . . តាប់ . . . ផ្លូយតាប់ផ្ស៊ីតោរ , . . តោរ . . . ៗ

មួយសន្ទុះក្រោយមកគេតាប់គួផ្ស័បាន ក្រឡុបសក់ផាប់រើលែងរួច ៗ លុះគេតាប់គួផ្ស័បាន ទើបឃើញគាត់កញ្ចាស់ខិងប្រពន្ធគាត់ទាំងបុត្រទាំងដើមចេញមករួបរ៉ាយតប់គួផ្ស័យ៉ាងផ្ចិត ៗ ភ្ញាក់ផ្អើលប៉ូលិសក្របួចសក់បណ្តើរចុះមកដាក់ឡានតែគួផ្ស័មិនព្រមទៀងផ្ទះ ក៏ត្រូវគេតាប់ហោះផ្លូលប្រឆាំងប្រធិល គ្រាន់តែរើបំរះខ្លួនបន្តិចត្រូវគេវាយតប់តាត់គាត់ឥតប្រណី ៗ

ព្រោះគេឥតគុណកញ្ចាស់ ខិងលោកស្រីទាំងពីរទាំងបីឃើញផ្លូ-ហោះហើយគាត់បានរួចពីសេចក្តីស្លាប់ ក៏សប្បាយរីករាយ

ថ្ងៃនិទ្ធរសេចក្ដីអំណរគុណដល់ប្ដីលិស ទើបសរសើរនាយប្រុក នាយមី នាយពេជយ៉ាងសម្បើម ៗ ដោយគាត់សប្បាយចិត្តពេក បានឲ្យរង្វាន់ដល់អ្នកទាំងអស់នោះថែមទៀតផង ៗ នាយពេជបានទៅហាយខាយសរសើរទៀតស៊ីជំនោរ ក៏ទៀនទៅលើឡាន ហើយក្របួចសក់ពួផង់ខ: កំភៀង តាត់ដាក់គ្នានាណាតតាសួរដល់អ្នកក្រដួចគ្នាទេ គ្រាន់តែពួផង់កម្រើកខ្លួនបន្តិចវាទាត់ដាក់លោតប្រាំហាទប្រកាន់ជាពួផង់តន្ដែវនីក ៗ

នាងបុប្ផាឃើញនាវយុវម៉ាបផុតកម្លាំងពេក នាងគាណាតណាស់តែមិនហ៊ានចូលមកជួយនាងបក្រេង់គេចាប់ធ្វើបាបទាំងអស់គ្នា ម្លោះហើយនាងលាក់ខ្លួនយំសោកខ្សឹកខ្សួលអណ្ដោចអណ្ដោមកនឹងចំកូបទ់ ព្រះសំពះទេវតាឲ្យជួយផុតកបន្តិចក្រោយមកឡានប្ដីលិសក៏បើកនាំពួផង់យកចេញទៅ ៗ នាងបុប្ផាស្រែកហាត់ឲ្យឡានឈប់ បំណាននឹងសុំអង្គរ

ប៉ូលិស   តែឡានបើកលឿនពេកមិនបានជាឮនាងហៅ ឡើយ   ម្យ៉ាងទៀតបើទុកជាឮក៏ឥតប្រយោជន៍ដែរ ព្រោះ នាងគ្មានឥទ្ធិពលអ្វីនឹងឃាត់បានឡើយ ។

ឡានបើកផុតទៅនាងគិតថាឪពុកនាង   មុខជា គេយកទៅមន្ទីរស្នងការដ្ឋានប៉ូលិស   នាងខំដើរពេញផ្លូវ ទាំងទឹកភ្នែកហូរហាមទៅតាម ៗ   លុះទៅដល់ ស្នងការដ្ឋានរកមិនឃើញសោះ   នាងខំដើររកតទៅទៀតៗ រកប៉ុះរកទៀននឹកហាក់បង្គួត ដោយហេតុតែនាងមិនស្គាល់ ដំណាញនៅក្រុងភ្នំពេញនោះផង   ក៏បេះតែប្រឹងដើរទាំងថ្ងៃ ទាំងយប់   ល្ងិតល្ងង់ឥតបាយក្រហាយទឹកអស់ពេលយ៉ាង យូរ ទើបនាងទៅដល់គុកធំ ៗ   ដល់ភ្លាមនាងក៏ចូល ទៅស្រាប់តែក្រឡេកឃើញពូធំ   កំពុងដេកស្ងឹង ស្ងាប់ផ្ញើមុខក្រៀមក្រោះនៅក្នុងទ្រុងដែក ៗ គ្រាន់តែឃើញ ឪពុកនៅក្នុងគុកនោះភ្លាម   នាងស្រែកហៅយំបោកខ្លួន

ប្រាណជួបអកុសលកាណិតឪពុកខ្លាំងណាស់ ៗ ពូផន់ឃើញកូនយំសោកខ្លាំងពេក ក៏ព្រោកឡើងនិយាយពីកន្ទ្រុនមកទាំងរអាក់រអួលថា :

— បុប្ផា . . . ល្ងីល្ងើយកុំយំស្រែកអី កម្មរបស់យើងទេកូន ឈានោះកល្លួសទៅហើយ ចូរកូនឯងទៅរកស៊ីនៅកន្លែងណាសិនចុះ ចាំអញចេញពីគុកទៅវិញសឹមយើងជួបគ្នាណ៎ាកូនណ៎ា

បុប្ផាស្រីមេម៉ាយ ទោះឪពុកប្រាប់យ៉ាងនេះក៏នាងមិនព្រមទៅណា ហោលកូនមានគុណដែរនាងដើរអង្វរគេពេញតែគុកសុំយកឪពុកចេញ តែគ្មានអ្នកណាជួយសង្គ្រោះនាងឡើយ ទោះនាងខំនិយាយរឿងកំសត់របស់គ្រួសារនាង ប្រាប់គេយ៉ាងណា ក៏ឥតប្រយោជន៍ដែរ ប្រាក់គ្មានមួយរៀលសោះធ្វើឲ្យនាងអស់សង្ឃឹមយ៉ាងខ្លាំង ម្ល៉ោះហើយឪពុកនឹងកូន

ម្នាក់នៅក្នុងទ្រុង ម្នាក់នៅខាងក្រៅឈរសម្រក់ទឹកភ្នែកកើង មើលមុខគ្នាទ្បើនទ្បើងៗទៅវិញទៅមកគួរឲ្យអាណិត ។

ថ្ងៃក្រោយមកឃើញឆាងបុប្ផាដើរសុំទានគេគ្រប់ច្រកល្ហក តាមបំពៀមផល់ទឹកក្នុងចំប្ញុរ ដើម្បីបំពៀមជីវិតឆាងផង ហើយទឹងជួយផ្ដល់ឲ្យផុតពីការដែលដេកនៅក្នុងគុកផងៗ

## ១៧

# អាចារ្យយីអស់លក្ខណ៍

រឿងកុម្មុញជាចៅហ្វាយធំ កាលឃើញកូនចៅរបស់ខ្លួនកក់កាយគ្នា ខ្លះទៅកើត ខ្លះទៅលិចស្រេចតែចិត្តរៀងៗខ្លួន ក៏បញ្ជាពីក្រុងហើយមកឲ្យពួកអស្សុរៈណាដែលជាកូនចៅរបស់គេ ឲ្យមកជួបជុំគ្នានៅស្រុកកោះធំ ដើម្បីស្តាប់បញ្ជារបស់គេជាថ្មី មិនបាច់ធ្វើការកាត់ក្បាលគ្រប់ទិស ខ្ទេចគេទៅទៀត ។

កាលប្រជុំគ្នានៅស្រុកកោះធំនោះ សឹងនិងកុម្មុញជាមេបញ្ជាការភៀកម៉ាញ បានគម្រាមឲ្យអាចារ្យយីទៅឈរកាត់ក្បាលនៅខេត្តបាត់ដំបង-សៀមរាប-កំពង់ធំ ដោយគេ

www.elibraryofcambodia.org

ប្រាប់ថាបើផែនការប្ញូនទឹកដីខ្មែរបានសម្រេច គេនឹងតែងតាំងឲ្យអាចារ្យយី ធ្វើជាស្ដេចត្រួតប្រទេសខ្មែរ ។ ចំណែកមេក្រុមឯទៀត ៗ ដូចជាលោកស័ក្ដិមួយធញ លោកសាំប ជាដើមក៏យៀកមិញប្រាប់ថា បើបានសម្រេចគោលបំណង គេក៏តែងតាំងឲ្យធ្វើស្ដេចត្រួតប្រទេសខ្មែរដែរ ។

អាចារ្យយីឆ្លើយទទួលយល់ព្រមនៅចំពោះសិន៊ុក-មិញជាពៅហ្វាយរួច ក៏ដកខ្លួនខឹងនាំទ័ពចេញមក តែមិនបានទៅនៅកន្លែងដែលនាយពៅហ្វាយ គម្រោងឲ្យទៅនោះទេ ព្រោះគាត់កក់អន់ចិត្តនឹកប្រណែនដោយពៅហ្វាយគាត់លើកគេឲ្យធ្វើជាស្ដេចគ្រប់ ១ នា ៗ ម្ល៉ោះ ហើយគាត់បែរជាចូលទៅនៅស្រុកទន្លាប់កណ្ដាល មុំព្រះវិហារសួគ៌ បន្ទាប់មកទៀត គាត់ចូលទៅកងល្បាតនៅស្រុកល្វាឯម ហើយតាំងទីជម្រកស្នាក់ការនៅក្នុង

មិនគិតសំណាបដិតក្អមិបារុំន៍ជាការ ពាក់កណ្ដាលទៅល្ងាចមួយ ពាក់កណ្ដាលមកទៀតបក់កណ្ដាល ហើយតាចារ្យយ៉ែបានតាំងខ្លួនគាត់ជាមេទ័ពធំ ដែនតាំងបន្ទាយនឹងធ្លាយ ( នាយយក្ស ) ដែលជាប្អូនបង្កើតរបស់គាត់នៅឡើងធ្វើជាមេទ័ពរង ចំណែកឯតាំងប្អូនស្រីបង្កើតរបស់គាត់ម្នាក់ទៀតឈ្មោះនាងប៉ុនថនឲ្យធ្វើជានាយក ។

តាំងពីពេលនោះមក តោះតាចារ្យយ៉ែដើរធ្វើបាបអ្នកស្រុកបានទ្រព្យសម្បត្តិមាសប្រាក់លុយកាក់ ចំណែកឯយប៉ុស្ដិ៍យកកាំភ្លើងបានច្រើនយ៉ាងណា ក៏ឈប់លែងយកទៅឲ្យយៀកមិញដូចមុន ៗ ហើយ គាត់តាំងចិត្តឈប់ទាក់ទង ព្រោះគាត់ទឹងទាញបោកយៀកមិញ ។

ថ្ងៃជាបន្ទាប់ ៗ មកតាចារ្យយ៉ែបានលើកទ័ពទៅកាប់សម្លាប់យួននៅក្នុងការិយាល័យគ្រួចនិងផុតវិហារស៊ុនក្លូ នៅមាត់ព្រែសាស ដោយបង្អាំងចិត្តក្រោកតាសេកខ្ទេចខ្ទីអស់ . . ។

យៀកមុំញដឹងថាអាចារ្យយីមិនស្លាប់បង្គាប់ ហើយបែរជាទៅកាប់សម្លាប់ជាតិយួនម្នាក់ទៀតផងនោះ វាក្តៅក្រហាយសម្បើមណាស់ តែវាមិនធ្វើអ្វីដល់អាចារ្យយីទេ ព្រោះវាមានបំណងចង់ទុកប្រើសម្រាប់ឲ្យរកកូនខ្មែរយើងនោះទៀតនិងតទល់ដេញបារាំងចេញ វាដឹងត្រួតត្រាខ្មែរម្តង ៗ ពេលនោះយៀកមុំញគិតឃើញថាបើកំចាត់អាចារ្យយីដោយដៃវាទៅខ្លាចអាចារ្យយីចង នឹងវេរឃាតកាត់ទៅទៀត ទោះហើយយៀកមុំញចាត់ម្នាក់ឲ្យទៅត្រូវដើរនឹងបារាំង ញុសញង់ប្រាប់បារាំងឲ្យដឹងពីទីកន្លែងដែលអាចារ្យយីនៅ ៗ យៀកមុំញបះណាស់មិនប្រាប់បារាំងតាមត្រង់ទេ ប្តូរជាអាចារ្យយីនៅឯស្រុកស្រីសន្ធរនោះទៅវិញ ៗ យៀកមុំញធ្វើបែបនេះ មិនមែនមានបំណងចង់ឲ្យបារាំងទៅសម្លាប់អាចារ្យយីទេ វាធ្វើដើម្បីឲ្យបារាំងទៅបង្អើល ព្រោះស្រុកស្រីសន្ធរនៅជិតស្រុកខ្សាច់

កណ្តាលបំណាច់ឲ្យអាចារ្យយើកើយ រត់មកជ្រកកោនវិញ ស្រលាញ់ផប់រាប់ច្រើនគេទៅទៀតតែប៉ុណ្ណោះ ។ តែបំណាច់របស់យៀកម៉ុញ មិនតែសម្លាប់អាចារ្យពេលដដែលទៅ ពេលណាដែលផែនការបានសម្រេច ។

បាក់ក៏បានជីជនខ្មែរគំនិតអាចារ្យតាមយួនក្លួនរួចក៏បញ្ចេញទ័ពទៅតាមផ្លូវទឹកពីរកងពលធំ ។ កងពលមួយទៅតាមទន្លេមេគង្គ កងពលមួយទៀតទៅតាមទន្លេបាសាក់រួចចូលទៅតាមទន្លេតូចទៅជួបគ្នានៅស្រុកស្រីសន្ធរ (ព្រែកពោធិ៍) ។

មិនដឹងជាថ្ងៃខែឆ្នាំ នៅថ្ងៃនោះអាចារ្យជុតតម្កល់ព្រះពុទ្ធសាសនាផ្សាយព្រះសង្ឃវត្តសាការែវ និងវត្តព្រះវិហារសួគ៌ រួចក៏លើកទ័ពចេញពីជម្រុំទៅស្រុកស្រីសន្ធរដែរ បំណាច់ខ្លួនទៅរកកោននឹងពាមជីកង ។ ទើបតែទៅដល់ភូមិមួយឈ្មោះភូមិបឹងចិនធានីកើតភូមិព្រៃយាម ស្រាប់តែជួបនឹងកងទ័ពបាក់ង ចណ្តាលឲ្យបាញ់គ្នាទៅវិញទៅ

មកក្ដុងក្ដាំងយ៉ាំងសម្បើម ៗ

ចាប់បាញ់តយុទ្ធគ្នាតាំងពីព្រឹក រហូតដល់ថ្ងៃរសៀល នៅតែមិនឈប់ ទាំងទាហានឡុកកាំងទាំងទ័ពអាចារ្យយីស្លាប់រាប់មិនអស់ ឮសូរតែកាំភ្លើងធំគ្រាប់បែកផ្ទុះគ្រាំងគ្រឹប ៗ មិនព្រមចាញ់មិនព្រមឈ្នះ ៗ លុះដល់ពេលព្រលប់ព្រឹល ៗ បារាំងបាញ់បន្ទុយានឡាយត្រូវចំកណ្ដាលដើមទ្រូងស្លាប់បាត់ទៅ ៗ អាចារ្យយីហាក់ដូចជាខនដៃខនដៃព្រោះស្លាប់ប្អូនបង្កើតរបស់គាត់ ហើយដែលជាមេទ័ពដ៏ខ្លាំងជាដៃស្ដាំនោះ ម្យ៉ាងទៀតគ្រាប់រំសេវក៏អស់រលីងអស់ ៗ ចំណែកបារាំងវិញទាំងនៅលើកប៉ាល់ទាំងពួកនៅលើគោកបេះតែបាញ់សម្រុកខ្លាំងឡើងៗ ម្លោះហើយអាចារ្យយីបញ្ជាដកទ័ពថយក្រោយ :

តេសីនកាកូន...តេសីន ទៅជម្រំយើងវិញ

អាចារ្យយីស្រែក ហើយលើកដៃម្ខាងឡើងឲ្យកូន

www.elibraryofcambodia.org

ចៅគាត់តែស្រែសុលតាមប្រឡោះឈៀក តម្រង់ទៅជម្រុំឯ ខ្សាច់កណ្ដាលល្វាឯងវិញ ។ អ្នកណាបានស្រែសុលក្រោមឈៀកគាពារឲ្យត្រូវបានបៀសផុតពីគ្រាប់កាំភ្លើង និងគ្រាប់បែក ឯអ្នកក្រៅពីនោះរត់ខុសផ្លូវត្រូវពួកបារាំងបាញ់ស្លាប់អស់ ។ កូនចៅគេទៅមុខអស់ទើបគាពារឲ្យដើរតាមការពារពីខាងក្រោយនៃគ្រាប់បែកគ្រាប់កាំភ្លើង តែគ្រាប់បែកគ្រាប់កាំភ្លើងបារាំងបាញ់ផ្ទុះផ្ទួលលាប់នោះ មិនអាចត្រូវគាពារឲ្យឡើយ ហើយបើទុកជាត្រូវក៏មិនមុតដែរ តែពេលនោះមិនដឹងជាយ៉ាងម៉េច ស្រាប់តែបារាំងផ្ដក់គ្រាប់បែកមួយគ្រាប់ទៅធ្លាក់ពីក្រោយជំហានគាពារឲ្យកំពង់ដើរ ធ្វើឲ្យគាពារឲ្យភ្ញាក់ព្រើត ភ្លាត់មាត់បញ្ចេញពាក្យបំពេសចំគាស ភ្លេចនឹកដល់មន្តអាគមគាថា គ្រាប់បែកនោះផ្ទុះឡើងប៉ុងប៉ើងទៀតគាពារឲ្យតែម្នាក់ឯងទាំងជំហារទៅធ្លាក់ក្នុងទឹកត្នុកទើបមិនរួចក៏ដេកត្រាំទឹកត្នុកសំងំនុយនោះជាមួយនោបកូនចៅគាត់

www.elibraryofcambodia.org

ទៅ ដោយគ្មាននរណាដឹងឡើយ ។ ចំណែកកូនចៅរបស់គាត់វិញ គិតតែទំប្រឹងរត់ទៅមុខមិនដឹងស្គាល់ជាអាចារ្យយើង ជាចៅហ្វាយត្រូវគ្រាប់បែកទៀតធ្លាក់ក្នុងទីធ្លាខេត្ត គាំងអស់ស្នាក់យកគិតតែទំដាក់មេដាយតម្រង់ទៅជម្រៅ ។

ម៉ោង ៨ យប់ទើបស្ងាត់ឈប់ឮសូរកាំភ្លើង ។ ពួកខ្មាំងសល់ពីស្លាប់ប៉ុន្មានទៀតដេញតាមទៅរកក្រុមអាចារ្យយើងទៀតមិនព្រមថយក្រោយឡើយ ព្រោះគ្នាគេមានគ្រឿងសាស្ត្រគ្រប់គ្រាន់ឯកងទ័ពក៏នៅសល់ច្រើននាក់ ។

ទំហំនៃចម្បាំងគ្នាលើក អ្នកស្រុកអ្នកភូមិនោះមានស្លាប់មនុស្សរាប់មិនអស់ទាំងស្លាប់គោ ក្របី មាន់ ទា ជ្រូកជាច្រើនក្បាលទាំងខ្ទមផ្ទះសម្បែងអស់ជាច្រើនខ្នង ដោយសារគ្រាប់កាំភ្លើងដែលគេគាក់គ្នាផ្លោះទៀតទៅត្រូវ ។

មួយយប់មួយថ្ងៃក្រោយមក ។ នៅពេលព្រឹកព្រលឹមស្រាងៗមានអ្នកដំណើរ ៤ នាក់នៅក្នុងព្រៃប្រែសប់

ដើរទៅតាមគេគោ ដែលចោរលួចដោយមិនបានដឹងក៏ដើរ កាត់ទៅចំកន្លែងដែលបាំងគ្នានោះ អាចារ្យ៍ដើបពីត្តុក ក៏មិនរួចណាមួយ អស់កម្លាំងអត់បាយយូរថ្ងៃមកផង ហើយ ថែមទាំងដេកត្រាំទឹកក្ដុកថែមទៀត កាលគ្រឡេកឃើញ ពួកដំណើរភ្លាមគាត់សប្បាយចិត្តណាស់ ទំស្រែកពីកន្ទុក មកសំឡេងគេថា :

– អាឯងទាំង ៤ នាក់ហ្នឹងទៅណា? ឈប់សិន មក សែងអញចេញពីកន្ទុកនេះមួយភ្លេត . . .

ពួកដំណើរឮអាចារ្យ៍និយាយដូច្នោះ នឹកស្មានថា ខ្មោចលង ព្រោះឃើញខ្មោចហើមស្ដឹងៗ រពេរកូតនោះ ក៏ភ័យហើយរត់ដាក់មេដាយ តែអាចារ្យ៍និយាយបន្ថែម ភ្លាមទៀត :

– នែ . . , កុំរត់ . . . កុំរត់ បើចង់រស់កុំរត់ អញ មិនមែនខ្មោចទេ អាឯងរាល់គ្នាស្គាល់អញទេ? អញហ្នឹង

www.elibraryofcambodia.org

ហើយឈ្មោះអាចារ្យយើងសស្រះ: អាឯងនឹងឃើញទេខ្មោច ឆាប់រកនរកូតនេះអញសម្លាប់ពីម្សិលមិញ ឥឡូវបើចង់រស់មានជីវិតត្រូវមកសែនអញពីក្នុងគុកនេះចេញភ្លាម . . . អញដេកក្នុងគុកនេះ គឺអញដេកក្រោយតពិសណា ។

ពាក្យសំដីនេះ អាចារ្យនិយាយសំឡុតអ្នកដំណើរ តែតាមការពិតវិញ គាត់ងើបពីក្នុងគុកមិនរួចឡើយ ព្រោះខុសតំណមគ្រូកាលដែលភ្លាត់មាត់ផ្ដេសផ្ដាសនោះ ។

អ្នកដំណើរមិនយល់ការគ្រាន់តែឮឈ្មោះ អាចារ្យយើភ្លាម គិតភ័យយ៉ាងខ្លាំងខ្លាចអាចារ្យជាងខ្លាចខ្មោចទៅទៀត ក៏សុខចិត្តនាំគ្នាចូលទៅសែនអាចារ្យពីក្នុងគុកយកមកដាក់លើគោកក្បែរផ្លូវដើរ ។ គ្រាន់តែដាក់ផុតដី អាចារ្យសំឡុតទៀត :

– យើ . . . អាឯងយកអញមកដាក់កន្លែងផ្លូវដើរអញ្ចឹង ប្រយ័ត្នគេឃើញអញ អញសម្លាប់អាឯងចោល

ផ្លូវ ត្រូវយកអញទៅដាក់មាត់ព្រៃជិតក្បាលស្រែឯណោះ ទើបរួចខ្លួន . . .

បុរសទាំង៤នាក់ខ្លាចអំណាច ក៏បេះដៃខំប្រឹងសែងអាចារ្យយ៉បន្តទៅទៀត ៗ លុះដល់ជើងព្រៃជិតក្បាលស្រែ ទាំងលិបបឹងខ្លួនអាចារ្យយ៉និយាយថា :

— ដាក់អញត្រង់ហ្នឹងហើយ អាឯងនាំគ្នាទៅវិញចុះ តែកុំនិយាយប្រាប់អ្នកណា ឲ្យដឹងថាអញនៅកន្លែងនេះឲ្យសោះ ប្រយ័ត្នតែគេដឹង អញទៅតាមសម្លាប់អាឯងរាល់គ្នា ព្រោះអញស្គាល់មុខអាឯងអស់ហើយ ទៅចុះ . . . ៗ

អ្នកដំណើរសប្បាយចិត្តណាស់ ដោយបានរួចពីកណ្ដាប់ដៃអាចារ្យយ៉ទាំង៤នាក់ខំរត់ចេញពីទីនោះឥតហ៊ានងាកក្រោយឡើយ ៗ ចំណែកអាចារ្យយ៉វិញ អ្នកដំណើរចេញផុតទៅ គាត់ដេកស្ដិតនៅចាំតែពេលស្លាប់ ដោយអស់កម្លាំងរឹងជើងរឹងដៃអត់បាយស្រេកទឹក ៗ

មួយសន្ទុះក្រោយមកកសិករម្នាក់នៅភូមិជិតជុំ បានបរគោទឹមនង្គ័លទៅភ្ជួរស្រែនៅជិតជើងព្រៃនោះ អាចារ្យយ៉ីក្រឡេកឃើញ, គាត់ទំព្រងរក្រោកឡើងហើយសំឡុត :

– នែ ... អាឯងនឹងបរគោទៅណា ? មិនស្គាល់អញទេឬ ? អញឈ្មោះអាចារ្យយ៉ីមេឥស្សរៈ យកគោមកឲ្យអញ អញសម្លាប់យកសាច់ដុតស៊ី . . .។

កសិករភ័យណាស់កាលឮឈ្មោះថា អាចារ្យយ៉ីនោះ គាត់បញ្ឈប់គោហើយឈរវៀចវេរញ័រៗទើបតបទាំងញ័រអង្វរថា:

– បាទលោកម្ចាស់ ព្រះតេជគុណមេត្តាកុំសម្លាប់គោខ្ញុំ នោះនេះខ្ញុំជួលគេយកមកភ្ជួរទេ បើព្រះតេជគុណចង់ទទួលទាន ខ្ញុំបាទមានបាយមួយកញ្ចប់ដៃ

– បាយមួយបន្តិចអញស៊ីមិនឆ្អែតទេ គ្នាអញច្រើននាក់ណាស់នៅក្នុងព្រៃនេះ ប្រយ័ត្នអញស្រែកហៅ,

www.elibraryofcambodia.org

វាដេញមកសម្លាប់តាឯងឥឡូវហ្នឹងហើយ ។ អាចារ្យយីបំភ័យតែតាមពិតក្នុងព្រៃនោះ ឥតមានកូនទៅគាត់ទាក់ទេ ហើយឃើញថាមានបាយមួយកញ្ចប់ស្រាប់នោះ គាត់សប្បាយចិត្តណាស់ ក៏ប៉ុន្តែគាត់ឈប់ឫកធ្វើជាមិនចង់បានសិន ។

ពួកសិស្សដឹងថាអាចារ្យយីមិនព្រម ក៏បំផាយដោបំណងត្រឡប់មកក្នុងវិញ តែអាចារ្យយីស្រែកនិយាយបន្ទូបន្ទោយថា :

– កុំរត់ . . . កុំរត់ អញតាមទៅសម្លាប់ដល់ផ្ទះ អញសម្លាប់ឱ្យអស់មួយពូជ បើចង់រស់កុំរត់ ឱ្យបាយមួយបង្វិចនោះមកអញក៏បានដែរ អញទុកតោឱ្យតាឯងប្រើ . . . ឱ្យបាយមកអញភ្លាមកុំរត់...

ពួកសិស្សភ័យណាស់ ឈប់រត់ហើយក៏យកបង្វិចបាយទៅជូនអាចារ្យយីភ្លាម ។ អាចារ្យយីបានដល់ដៃគាត់សំឡុតម្ចាស់បាយ :

www.elibraryofcambodia.org

— ថយចេញពីមុខអញទៅ . . . អញសម្លាប់ចោលឥឡូវហ្នឹង . . .

ពួកសិស្សមានសេចក្ដីត្រេកអរជាទីបំផុត បានរួចពីសេចក្ដីស្លាប់ ខំបរគោចេញពីទីធ្លានោះយ៉ាងលឿន សំដៅផ្ទះវិញ ។

ចំណែកអាចារ្យបានបាយមួយកញ្ចប់ ក៏លាស៊ីភ្លាម ឥតបង្អង់ ស៊ីអស់គ្មានសល់មួយគ្រាប់ឡើយ រួចចុះទៅផឹកទឹកបឹង ។ ស៊ីផឹករួចមានកំឡាំង គាត់ខំដើរតម្រង់ទៅរកជម្រំដើម្បីជួបជុំកូនចៅគាត់ ។

ថ្ងៃនោះអាចារ្យជួបជាអស់លក្ខណ៍ ទៅដល់ជម្រំវិញបាត់កូនចៅគាត់អស់ ដោយកូនចៅរបស់គាត់នាំគ្នាចេញដើរទៅរកគាត់ជ្រួសផ្លូវគ្នា ឃើញតែពួកស្រីៗមួយហ្វូងនៅចាំជម្រំ ។ ពួកស្រីៗទាំងនោះគេសុទ្ធតែជាប្រពន្ធអាចារ្យទាំងអស់ បាត់អាចារ្យមួយយប់មួយថ្ងៃ

លុះឃើញក្ដាមកំតែទៅទទួលចុះជើងចុះដៃយកចិត្តថ្វី ៗ ឯអាចារ្យយើវិញក៏មិនអន់ដែរ ពេលជួបគ្នាគាត់ថៃមើល តៀកកើយចុះមិនស្រេចតែចិត្តនឹកឃើញ អស់ពីមួយទៅមួយទៀត ៗ

អាចារ្យយើកំពុងតែគៀកកើយចុះថើបប្រពន្ធតាំងមួយ ហ្វុនយ៉ាំងសែនសប្បាយ ពួកទាហានបាក់ងដើរ ៗ ទៅ ឃើញតែមិនឲ្យអាចារ្យយើដឹងខ្លួនទេ ៗ បាក់ងក៏យកទំពា ជាស្នែងក្របី ពន្លាអាចារ្យយើជាប់ រួចធ្វើជាក្អកក្រហែម អាចារ្យយើក្រឡេកឃើញទំពាបាក់ងប្រើនគាក់គេក ហើយ មកហ៊ុំពន្លាគាត់ជាប់ទៀតនោះ គាត់ក៏តែបោលប្រពន្ធចុះ ទៅតួនកន្ទីទីកបង ៗ

ទំពបាក់ងបាញ់កាំភ្លើងរះបម្រះពីក្រោយ ហើយដេញ តាមចុះទៅក្រកេកន្ទីទីកទៀត ៗ ចំពេកអស់ពេលយ៉ាំងយូរ នៅតែមិនឃើញ ៗ រកចុះកេចឡើង ស្រាប់តែទាហាន

ធ្លាក់ពីម្នាក់ដើរល្ហុយទឹកទៅជាន់ប៉ះលើខ្មោចនៃហោង ខ្មោចដែលក្រុមអាចារ្យយើសម្លាប់បោះចោលក្នុងទឹកនោះ ៗ តែដោយតាហាននោះយល់ថាប្រាកដជាមនុស្ស ជាពិសេសយល់ច្បាស់ជាអាចារ្យយើ ក៏ជាន់ក្រពឹតខ្មោចជាប់រូបស្រែកថា :

– ឃើញហើយរ៉ើយ ... ឃើញហើយ អញជាន់កក់ជាប់ហើយជួយ ... ជួយ ... លឿនឡើង ៗ ...

ក្រុមតាហានធ្លាក់ពីព្នានៅស្រែកជួយខ្លះ ក៏ខំហែលទាំងខ្លាយទឹកសំពោងទៅតាមក្រោមបំណាក់ខ្ញុំជួយចាប់ រូបនាំគ្នាចាប់លើងឡើងពីក្នុងទឹក ស្រាប់តែស្អុយនើងឃើញស្នាមរបេះពោះបញ្ចេញពោះវ៉ន ... លាងអណ្តាត .. ឈាមធ្លាក់តាមប្រមុះក្អក គេកំទម្លាក់ខ្មោចនោះចោលហោងប្រញាប់ភ័យជាសក្រញ៉ាំជាន់គ្នាសឹងឈ្លកទឹកស្លាប់ខ្លួន ព្រោះខ្តើមហើយខ្លាច ៗ ខ្វះទៀតភ័យស្រែកភ្ញាក់សំឡេង ៗ

www.elibraryofcambodia.org

នេះគឺរឹតតែធ្វើឲ្យទ័ពបារាំងកាន់តែក្តៅក្រហាយទាំងអាចារ្យយីរឹតតែទៅទៀត ។ ឈ្លៀតឱកាសនោះពួកប្រពន្ធរបស់អាចារ្យយីទាំងមួយហ្វូង ក៏នាំគ្នារត់បាត់អស់ទៅ ។ លុះរយៈយូរបន្តិចក្រោយមក ទើបឃើញអាចារ្យយីកំពុងអង្គុយក្នុងទឹកតូចកំប្រោនៗ ដោយយកមាន់កំប្រោចគ្របក្បាលផង ។ ពួកទាហានបារាំងចាប់អាចារ្យយីបាននាំទៀតយកមកលើគោកខ្លះស្រែកហៅរំពងបង់ ខ្លះទាត់ខ្លះដាក់វាយបណ្តើរយកទៅដាក់គប៉ាល នាំមកក្នុងពេញ ។

ពេលនោះទាហានបារាំង ធ្វើបាបអាចារ្យយីសម្បើមណាស់ នៅលើកប៉ាល គេយកអាចារ្យយីទៅចងផ្តួចនឹងបំពង់ភ្លើង តែអាចារ្យយីមិនក្តៅមិនលោកឡើយ វាយសំពងក៏មិនឈឺមិនបែកយកកាំភ្លើងមកបាញ់បញ្ចេញតែមិនផុតមិនឆ្លាយ ទាហានបារាំងទាំងអស់ចាប់ចងជើងចងដៃបោះទៅក្នុងទឹកយ៉ាងយូរ លុះលើកឡើងអាចារ្យយីនៅរស់

ដដែល ៗ បន្ទាប់មកទៀតធ្លាក់ភ្លៀងមកយ៉ាងយូរមិនឈប់ឈរ កងទ័ពបារាំងទាំងប៉ុន្មានរសាររញ៉ើរផ្ដាយ ចំណែកអាចារ្យវិញ កុំថាឡើយដល់រអាសូម្បីតែទឹកភ្លៀងមួយតំណក់ក៏មិនអាចស្រក់ឡើត្រូវគាត់បានឡើយ ៗ

ទៀតឃើញដូចជាទាហានបារាំងចាប់អាចារ្យ ជាខ្ញុំបំរើរាំងដែលគាប់ប្រើមិនអស់ចិត្តផងនោះ ក៏ស្ដាយសែនស្ដាយស៊ីងព្រោកក្រូល ម្យ៉ាងទៀតខ្លាចអាចារ្យអើយប្រាប់បារាំងពីអាថ៌កំបាំងរបស់គាត់ តែនេះមកពីបំណោះដេះចងន ៗ

# ១២

## ពូជច់នឹងអាចារ្យយីជួបគ្នាក្នុងគុក

មកដល់កំពេញ ប៉ាក់នីដោះខ្សែកជាមន្តអាគមចេញពីខ្លួនគាពារ្យយ៉ាអស់ ហើយរាយបញ្ចូលគុក ។

គុកជំនាន់នោះ ឲ្យតែមានអ្នកទោសចូលទៅថ្មី ពួកអ្នកជាប់មុន ៗ តែងមករោមរោមសួរសុខទុក្ខអ្នកដែលនៅខាងក្រៅពីអំពើដែលប៉ាក់នី - ផស្សៈ - យៀងមិញ - ពោរព្រៃធ្វើបាបយ៉ាងណា ១ ៗ ខ្លះទៀតសួរពីអំពើរបស់អ្នកទោសថ្មីបានប្រព្រឹត្ត បើសួរទៅ អ្នកណាបានធ្វើអំពើបដិបបន្តឲ្យជាប់គុកដែរនោះមុខជាអ្នកជាប់មុន ៗ រាយតាក់ឆាក់ធ្វើបាប តែបើពុំជាបានប្អូនកាប់សម្លាប់មនុស្សបាន

ច្រើននាក់វិញ ពួកនាក់ជាប់គុកមុនៗ សប្បាយចិត្តណាស់ គេមិនធ្វើអ្វីទេ គេលើកដំកើងថែមទៀត ។

ដូច្នោះហើយបានជាគេបញ្ចូលអាចារ្យយើងទៅកន្លែងគុកភ្នាម ពួកអ្នកជាប់មុនៗ មករោមគេមសួរគ្នា ។ អាចារ្យយើងជាអ្នកចេះដឹងដែរ ហើយគាត់មានបំណងចង់ធ្វើជាចៅហ្វាយគេនៅក្នុងគុកទៀតនោះ ដើម្បីឲ្យគេគោរពខ្លាចផងក៏និយាយប្រាប់គេថា ៖

— អ្នកកាល់គ្នាមិនដឹងខ្ញុំទេ . . . ខ្ញុំឈ្មោះអាចារ្យ អ្នកកាល់គ្នាដែលឮឈ្មោះខ្ញុំទេ ? បានជាគេហៅខ្ញុំអាចារ្យព្រោះខ្ញុំបានបួសរៀនធម៌ សំណាក់ព្រះកម្មដ្ឋានចេះដឹងច្រើនថែមទាំងបង្ហាត់បង្រៀនគេទៀតផង ខ្ញុំចេះរហូតដល់បែកមេកាំបិតចេះដឹងគាថមន្តដុតមិនឆេះ បាញ់មិនចេញ បានជាពួកយៀកមិញចាប់ខ្ញុំស្រឡាញ់ខ្ញុំណាស់ គ្រាន់តែប្រពន្ធខ្ញុំទាំងអស់មាន២៣នាក់ហើយសុទ្ធតែក្មេងៗ

ស្អាត ៗ ស្រុកខ្សាច់កណ្ដាលជាស្រុកកំណើតរបស់ខ្ញុំ(ត្រឹម ម្ដុំផ្ទះអាចារ្យយើសព្វថ្ងៃបែកបួលខាងស្រុកស្រែសន្ធរខេត្តកំពង់ចាមវិញ) ទៅសួរមើលអ្នកណាមិនស្គាល់ខ្ញុំជាអ្នកខ្វាក់ភ្នែក ខ្ញុំធ្លាប់កាត់កគេហូតឈាម ធ្លាប់វះពោះគេយកថ្លើមស្ងោស៊ីប ធ្លាប់វះពោះគេញាត់ស្មៅ ខ្ញុំធ្លាប់សម្លាប់សព្វបែបសព្វយ៉ាង ៗ

ពួងដឹងថា អាចារ្យយើក្លាយ គាត់មានកំហឹងកើតឡើងមួយរំពេចសំឡុក អាចារ្យយើយ៉ាងមុតសឹងស្ទុះទៅស៊ុំសាប ព្រោះអាចារ្យយើនេះឯង ជាអ្នកធ្វើបាបឲ្យគាត់ព្រាត់ប្រាសប្រពន្ធកូន រោលស្រុករោលទេស រួចក៏ស្ទុះទៅចល់មុខអាចារ្យយើហើយសួរទាំងក្ដៅក្រហាយថា :

– គាត់ឯងឈ្មោះអាចារ្យយើមែន ?

– បាទ ខ្ញុំឈ្មោះអាចារ្យយើមែន

– អាចារ្យយើធ្វើមេចោរហ្នឹងឬ ?

– បាទ, ខ្ញុំមិនមែនមេចោរទេ ខ្ញុំជាមេឥស្សរៈ

www.elibraryofcambodia.org

• គាត់ឯងមិនមែនមេឥស្សរៈទេ គាត់ឯងជាមេចោរ គាត់ឯងធ្វើបាបតែខ្មែរគ្នាឯងឲ្យរងទុក្ខវេទនា ហ៊ានជិះជាន់ខ្មែរសឹងស្លាប់អស់ពូជ យៀកមិញកាន់ត្រួតខ្មែរប្លន់យកទឹកដី តាគាត់ឯងមិនគិតធ្វើបាបបារាំង ធ្វើបាបយៀកមិញទេ បែរជាមកធ្វើបាបជាតិឯងទៅវិញ គាត់ឯងមើលដៃអញកំបុតនេះបុះតើដោយសារតាគាត់ឯងបាញ់អញនៅភ្នំ មេ·សប្រប័ណ្ឌ ធ្វើឲ្យអញវេទនា ព្រាត់ប្រាសប្រពន្ធកូនទៅ រហូតដល់អញជាប់គុកដល់សព្វថ្ងៃ ឥឡូវអញបានជួបតាឯងអញសុំសងសឹកវិញហើយតាកៀន . . ,

ពួកនិយាយបប់ ក៏ស្ទុះទៅដាល់តាចារ្យយ៉ើបមុខមួយដៃធ្ងន់ , . . , រូបគាត់កន្ត្រាក់មួយខ្ទង់ជើងចំពោះហ្វាយទៀត ។ តាចារ្យយ៉េក្រោកឡើងតដៃ ដាល់ទៅដាល់មក ទាត់ចុះទាត់ឡើង ជួលព្រួស ហោកចំបាប់ផ្លាវក់ពេញកន្លែងទឹកស្អុក ។ ពួកនឹងដៃគាត់អស្ចារ្យខ្លាំងមែន តែមិន

www.elibraryofcambodia.org

ព្រមបាញ់អាចារ្យយើងទេ គាត់ខឹងខ្លាំងណាស់ គាត់ខំបោកបំបាក់ជាមួយសត្រូវមិនសំចៃកម្លាំងឡើយ ។

ខណៈពេលនោះនាងឃ្មុំបាត្រឡប់មកពីស៊ីឈ្នួលទៅវិញ នាងអរណាស់បានចំណីអាហារយកមកជូនឪពុក លុះឃើញឪពុកកំពង់បោកបំបាក់ទាត់ធាក់ជាមួយអាចារ្យបែកញើសតឃារ ហាក់ដូច្នោះនាងភ័យណាស់ទួញយំដើរចង់ចូលទៅជួយតែចូលទៅមិនរួចរបងដែកទ្វារចាក់សោរ ម្លោះហើយនាងឈរទន្ទ្រាំមើលស្ទុះស្ទោរ ភ័យខ្លាចឪពុកនាងស្លាប់ ពេលណាឃើញឪពុកនាងមានប្រៀបជាងអាចារ្យ នាងសប្បាយចិត្តណាស់ បើឃើញចុះប្រៀបដោយឃើញអាចារ្យជិះពីលើឪពុកនាងវិញ នាងភ័យស្លឹងហោះព្រលឹងអាណិតឪពុក ។

ក្នុងពេលនោះពួកអ្នកជាប់គុកឈរមើលសើចសប្បាយ ដោយឃើញអាចារ្យយើងនឹងពូឯងប្រកាច់បំបាក់គ្នា តែដោយ

អ្នកទាំងនោះស្អប់អាចារ្យយើងដែរ ហើយមើលទៅ ទៅទីបំផុត គេចូលទៅជួយកូនជំ ព្រមទាំងយកសំពត់ឈាមដាក់អាចារ្យយើង ទៀតព្រមខ្លួនសឹងពេញក្អួត . . . ។

មានថ្ងៃមួយ(៧ - ១៤ - ៧៣) ប៉ាក់ងឹមមិនដឹងជាយល់ឃើញយ៉ាងណាទេ ស្រាប់តែដោះលែងអាចារ្យយើងឲ្យមានសេរីភាពតែចេញមិនទាន់ផុតពីគុកផង ត្រូវខ្មែរក្រហមជាតិនិយមចាប់ចាប់បញ្ចូលទៅក្នុងគុកវិញមិនឲ្យចេញរួចព្រោះគេយល់ថាអាចារ្យយើងមុខជាចេញទៅបំរើផលប្រយោជន៍ឲ្យប៉ាក់ងឹមបើពុំនោះទេ មុខជាទៅបំរើចៅហ្វាយនាយ ( យៀកមិញ ) ទៀត ។

◦◦◦

# ១៣

## ដកបន្លាចេញពីទ្រូង

អ្នកជាប់គុកចុកឡើងជាប់សឹងចុះ យើងបែរមើលទៅគុំផៃវិញម្ដង ៗ កាលគាត់នាំនាងបុប្ផាយកមកឱ្យគាត់ញ៉ាស់ផ្លែបំរើបារាំងបក្រពត្តិ ដោកកំពេញ រូបគាត់ត្រឡប់ទៅផលផុះវិញ បាត់កូនបាត់ប្ដីអស់ធ្វើឱ្យគាត់ស្រពាំងកាំងធ្លល់យ៉ាំងទាំង ៗ បន្តិចក្រោយមកញាតិជនខាងនិយាយរឿងរ៉ាវប្រាប់សព្វគ្រប់ គុំផៃហាក់ក្រឡុកខួរក្បាលយ៉ាំស្រែកសស្រាក់ទំដើរតាមទៅរកកូនរកប្ដី ៗ ដើរៗទៅស្រាប់តែឃើញគុំខ្លួនប្ដីគាត់ជាប់បំណង ដែលក្រមសាបារ្យយ៉េបងផុបខឹងគលលឈើកណ្ដាលផ្លូវ ធ្វើមុខក្រៀមផ្ទះទឹកភ្នែកហូរ

www.elibraryofcambodia.org

ហាម ៗ កុំឲ្យឃើញប្ដីក្លាយឈើចិត្តនឹងក្រុមអាចារ្យយើងសឹង ហោតក្បាល ហើយស្ទុះទៅស្រាយប្ដីពីចំណងនាំមកផ្ទះវិញ។

តាំងពីគោះកប្ដីប្រពន្ធ នោះដឹងច្បាស់ថានាងវណ្ណកូន គាត់ គឺអាចារ្យយើងចាប់យកទៅក៏ដោយ គាត់មិនហ៊ាន ទៅតាមយកមកវិញទេ ខ្លាចអាចារ្យយើងចាប់ធ្វើបាបទាំងអស់ គ្នា ព្រោះនៅពេលនោះអាចារ្យយើងបញ្ចេញឥទ្ធិពលខ្លាំង ណាស់ គាត់ទៅសុំចតម្ដុំស្រុកកំពង់ត្របែកផ្លូវព្រៃវែង ស្វាយរៀង ដោយមានគាយខុនពីរនាក់ (ខ្ញុំសូមអភ័យ ទោស មិនបានបញ្ចេញឈ្មោះគាយខុននេះទេ ព្រោះសព្វ ថ្ងៃនេះគេជាសេដ្ឋី ) ជួយតម្កល់ជននឹងស័ក្កទៅបំពាក់តែង តាំងឲ្យអាចារ្យយើងធ្វើជាស្ដេចអាចារ្យបានចិត្តតែតែធ្វើបាប អ្នកស្រុក ដុតសាលារៀន ដុតគម្ពីរព្រះពុទ្ធសាសនាធ្វើ បាបព្រះសង្ឃនឹងកំចាត់គ្រូបង្រៀនធ្វើបាបជាតិខ្មែរឯង ខ្លាំង ឡើង ៗ ម្យ៉ាងទៀតនៅពេលនោះ រវល់តែភ័យខ្លាចនឹង គួនហោរល្ហបហោរប្អូន ជួនភ័យខ្លាចនិងពបាក់ឆ្អឹងចូលទៅស្រុក

ឲ្យគេធ្វើបាប ជួនក៏យកទឹកពុះហៀកម៉ិញទៅកាប់សម្លាប់ចោល តែក៏យកគេបរិវារក់ទឹកអាពួកអស់ទាំងនេះ ម្ល៉ោះហើយអ៊ុំផៃក៏ខ្លួនខ្វល់ខ្វាយពេក តែកើតទុក្ខអាណិតកូនសង្ឃបិតទាំងពីរនាក់ប្តីប្រពន្ធ ។

យូរថ្ងៃក្រោយមក គឺនៅមុនពេលអាចារ្យយើងនឹងចាក់ចំបាំងគ្នា នៅស្រុកស្រីសន្ធរក្បែរភូមិបឹងចន់នោះ អាចារ្យយើងបែបនាត់អស់ចិត្តអស់ចង់ លែងត្រូវការសេជាតិនាងវណ្ណា ម្យ៉ាងទៀតដោយគាត់បានស្រីក្រមុំថ្មី ១ ជាច្រើននាក់មកទៀតនោះ អាចារ្យយើងមកសន្ធេក ក៏ដេញបំបរបង់នាងវណ្ណាមកវិញ ដោយនាងពហ៍ផ្ទៃពោះមកជាមួយផង ទឹកការយំសោករលឹកទុក្ខម្តាយ ។

អ៊ុំផៃគាត់ឃើញកូនមានផ្ទៃពោះ គេហោះបង់ចោលឲ្យមកវិញត្រមង់ត្រមោចនោះ គាត់ហួសចិត្តពេកណាស់តែមិនហ៊ានហាមាត់បកស្នាក់ ខ្លាចនៅខាងបក់ស្ទើង សុខចិត្តនៅស្ងៀមទាំងមួយហ្ន រហូតដល់កើតផ្ទាំការក្អកក្តាក់ឈាម ។

ថ្ងៃតាក្រក់ ថ្ងៃអព្វមង្គលកន្ទុំផុតទៅ ថ្ងៃជោគជ័យក៏ចូលមកដល់ ។ ថ្ងៃនោះជាថ្ងៃឧក្កតបុណ្យជាថ្ងៃដ៏មហាសប្បាយមានសិរីសួស្តី គឺថ្ងៃទី ៩ វិច្ឆិកា ១៩៥៣ មេឃកំពង់កាំងស្ងួតបិតថ្ងៃក្តៅថែសរសោះ ស្រាប់តែមានហេតុចំឡែក ធ្លាក់ភ្លៀងមកមួយមេយ៉ាងធំស្រោចស្រពផែនដីកម្ពុជាហាក់ដូចជាភ្លៀងមាស ដើម្បីលាងជម្រះគ្រឿងសៅហ្មងគ្រោកអព្វមង្គលទាំងពីត្រៃវស្ស ហើយស្រាប់តែកាំងស្ងួតទៅវិញ បើកថ្ងៃស្រឡះថែស តែមិនក្តៅដូចមុនទេ វែរតែត្រជាក់ល្ហឹមគួរឱ្យធ្លុល់ ។

បន្តិចក្រោយមកបានទទួលដំណឹង ១ នាហ្លួរវៃហារ ពីក្រុងពេញផ្សាយមមដល់ គ្រប់ប្រកល្ហកបុនការក់មាត់ញែតគ្រប់ស្រុកគ្រប់ភូមិទូទៅពេញ ក្នុងព្រះរាជាណាចក្រកម្ពុជា (កាលនោះមិនទាន់មានវិទ្យុផ្សាយដល់ស្រុកស្រែទេ ពួដំណឹង ១ នាតាមមាត់ ) ជា៖

www.elibraryofcambodia.org

- (( ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុវរ្ម័ន ជាព្រះមហាប្រិយក្សត្រ ព្រះអង្គទ្រង់ទាមទារឯករាជ្យ ទឹកដីសិទ្ធិអំណាចសេរីភាព ពីក្រចកបារាំងបានមកឲ្យខ្មែរ ហើយឲ្យជាតិដ៏វៃឆ្លាក្លាហាន ក្រោមព្រះបញ្ញាញាណ របស់ព្រះអង្គ បានកាន់កាំភ្លើងឈើគ្រប់ដៃដេញបារាំង ធ្វើឲ្យបារាំងដាក់មេដាយវាសក្រញាំរត់ ទៅស្រុកវិញទាំងអាមាស់មុខក្រៃលែង ឲ្យជាព្រះអង្គកំពុងប្រដិបប្រដិមពួកឥស្សរៈឲ្យចូលជាតិមួយត្រកូលគ្នាកសាងមាតុប្រទេស ទាំងឲ្យជាពួកមហាកែត្រ ទាំងពួកឥស្សរៈទិលខូច ដែលធ្លាប់តែមានចិត្តឃោរឃៅយុទ្ធឃ្នងតែនឹងជាតិឯងនោះ ត្រូវបាញ់បារមីតេជៈព្រះបាទសម្ដេចព្រះនរោត្ដមសីហនុ ហើយពួកអាចង្រៃទាំងនោះ វិនាសរលាយខ្លួនហិនហោចអស់ពីទឹកដីខ្មែរទៅហើយ )) ។

នៅថ្ងៃនោះពលរដ្ឋខ្មែរខ្ញុំទៅពេញទាំងប្រទេស ជំពន់

www.elibraryofcambodia.org

ណាក៏ដូចជាជិះទូកណាដែរ កាលបានពូជិះណាំងនេះភ្លាមក៏លោតតោញោងតែកាយសប្បាយយ៉ាងមហិមា ប្រៀបបានដូចជាដកបន្លាចេញពីទ្រូងឬសប្បាយចិត្តដូចមនុស្សចាស់អាយុ-៧០ឆ្នាំបានកើតជាក្មេងម្តងទៀត ឬសប្បាយជាងនេះទៅទៀត . . . ។

ដល់ពេលថ្ងៃរសៀលបន្តិច ស្រាប់តែឃើញពូផង់ ខឹងឆាងប៉ុញ្ញាទៅដល់ភូមិមេ.សប្រប៉ណ្ណស្រុកកំណើតគាត់ដែរ ហើយដោយពូផង់គាត់សប្បាយចិត្តពេកដើរស្រែកប្រាប់គេតាំងពីដើមភូមិរហូតដល់ចុងភូមិថា ៖

— ប្រទេសខ្មែរបានឯករាជ្យហើយ អ្នកជាប់គុកជាប់ច្រវាក់ឃុំឃាំងដែលបារាំងធ្វើបាបនោះ ក៏ព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះមហាក្សត្របស់យើង ទ្រង់ដោះលែងឱ្យរួចទុក្ខទោសអស់ដែរ ចំណែកបារាំងចក្រពត្តិវិញមុខវាខ្មៅកែរ គេដាស់ត្រញាំទៅស្រុកវាវិញ ជយោព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ជយោព្រះមហាក្សត្រខ្មែរ !

ជះយោព្រះកជាំណាបក្រុមត្តជាបានឯកជ្យ ។

អ្នកស្រុកពួកផ្សំនឹងនាងបុប្ផា ទើបនឹងត្រឡប់មកពីក្នុង ពេញ ហើយស្រែកក្រោកប៉ែបនេះរីតតែធ្វើឲ្យអ្នកស្រុកបាន ព្រួសពីដំណើរនេះមួយគ្រប់មិនបៃមទៀត ។ បរិណាកផ្ទុះខប្ញុំ ថៃវិញ គ្រាន់តែក្រឡេកឃើញនាងបុប្ផានឹងពួកផ្សំក្លាយ គាត់ទម្លាក់ការងារហោលទៅស្រែកចក្រោលឡើង គេ ឆ្កួ.គេ ឆ្កួ តាមភាសារបស់គាត់សបតសោទរបំពោះបងប្អូន ។ ឯក្នុងស្នងនឹង នាងវណ្ណាវិញក៏តែទៅទទួលដៃរ ។ ពេលនោះគ្នាដៃយំទបពួ ផង់នាងវណ្ណានឹងនាងបុប្ផាដែលសុទ្ធតែជាស្រីមេម៉ាយហើយ មានផ្ទៃពោះដូចគ្នានោះ នាងយំទុបគ្នាទៅវិញទៅមកថ្ងូនខ្សួរ សេចក្តីនឹកលើកគ្នាតូចនឹងគេឡោច ។ ក្នុងគពិតមែនតែគាត់គ ហើយបួងនិយាយមិនកើតស្ដាប់មិនឮ តែគាត់ឈរសម្រក ទឹកភ្នែកតក់ៗ ស្រនេះស្រទោបយ៉ាងខ្លោចផ្សាម្នាក់គាត់ដែរៗ

អ្នកស្រុកញាតិមិត្តបានទៅហោមកេមសួរសុខទុក្ខ

ផ្ទឹងខ្ទឹង នាងបុប្ផា ពេញណែនបណ្តៀតផ្ទុះអុំផៃ ហៀរមកនៅ
ឈរនឹងដីគ្រៀបគ្រោមដើរដោសទៀតផង ហើយព្នមាត់ពូផង់
និយាយកោកកាកៗ ខ្លាំងៗ នៅកណ្តាលចំណោមភ្ញៀវថា ៖

– បើកុំតែតាពាក្យយើងផង ចាក់ងផង ពោរផងយៀក
មិញផងនោះ យើងទាំងអស់គ្នា គ្មានអ្នកណាព្រាត់ប្រាស់គ្នា
ទេ ហើយប្រពន្ធខ្ញុំក៏មិនស្លាប់ ដៃខ្ញុំក៏មិនកំបុតអគ្គិតម្ខាង
យ៉ាងនេះដែរ តែឥឡូវពួកគេពោរពោន្ទយ៉ាំងទាំងអស់នោះក៏
រលាយអស់ហើយ ខ្ញុំសប្បាយចិត្តណាស់ដែលបានមក
ជួបជុំគ្នាវិញនេះ ហើយយើងជាជាតិខ្មែរសូមកុំភ្លេចជាប្រ-
ទេសខ្មែរ ពលរដ្ឋខ្មែរដែលបានសុខសប្បាយជៀសផុតពី
ភ្លក់សង្គ្រាម ហៅលង្វិនផុតពីសមុទ្រទុក្ខ សមុទ្រស្លាប់
គឺដោយសារបារមីតេជគុណព្រះបាទ សម្តេចព្រះនរោត្តម -
សីហនុវរ្ម័នជាព្រះមហាក្សត្ររបស់យើង ព្រះអង្គទ្រង់ពុះពារ
យ៉ាងកាត់ឱបបត្តិយ៉ាងក្លាហានឥតខ្លាចនឿយព្រះកាយពល

www.elibraryofcambodia.org

ទំប្រើនប្រែន ដើម្បីឲ្យយើងកល់គ្នាបានសុខឲ្យប្រទេសជាតិ យើងបានរួបតិភាពទុំកញ្ចះគេ ដូច្នេះយើងត្រូវកត់ត្រាទុកនូវ ព្រះមហាករុណាទិគុណដ៏ធំធេងរបស់ព្រះអង្គ ក្នុងដួងចិត្ត របស់យើងកល់ ១ គ្នា កុំភ្លេចព្រះអង្គឲ្យសោះ ព្រោះជាបើកុំ បានព្រះអង្គប្រទេសខ្មែរ ពលរដ្ឋខ្មែរយើងទាំងអស់គ្នាមិន ដឹងជាក្សឯណាទេ . . . យើងទាំងអស់គ្នាត្រូវគោរពបូជាដរៃ ថ្វាយចំពោះ ព្រះអង្គទឹងផ្ទើតាមព្រះអង្គរហូតរៀងទៅ .

ត្រូវនិយាយមិនទាន់ចប់ផង មានលោកយាយ ម្នាក់ស្រែកឈរឡើង ៗ លោកយាយនេះស្គមបាប មាត់បន្តិច ប្រហែលកាលដែលគាតារ្យយំហោលត្រូវចិន បានតើមុខនោះកំមិនដឹង គាត់ប៉ោះហោលប្រណុកប្លាដែរ គាត់បៀមនៅក្នុងមាត់ស្ងួយប៉ុនមេដើងនោះ ហោលពេញរួច និយាយកាត់ថា :

— យ៉ ! ឲ្យយើងភ្លេចព្រះមហាក្សត្រដ៏ជាទំគោរពស្នេ

ជីវិតរបស់យើងម្ដេចបាន ? ព្រះអង្គមានព្រះគុណធំលើ យើងរាល់គ្នាសម្បើមណាស់ ? បើកុំតែបានព្រះអង្គ យើងមុខជានៅតែរងទុក្ខវេទនាដកដាំតែថ្ងៃស្លាប់តែហោង ដោយសារប្រព្រឹត្តិបាកាំង ដោយសារអាចារ្យយ៉ឥស្សរៈ ដោយសារការយៀចិញ្ចធ្វើបាបសក្តិសក្តិនមិនដឹងជាថ្ងៃណា បានជួរស្បើយទុក្ខទេ តាមយោបល់របស់ខ្ញុំ ដែលជាមនុស្សចាស់ជាងអ្នករាល់គ្នា ខ្ញុំយល់ថាព្រះបាទសម្ដេចព្រះនរោត្តមសីហនុជាព្រះមហាក្សត្រមានឫទ្ធានុភាពដ៏ឥស្សារ្យ ព្រះអង្គមិនមែនពួតង្ស្រជាមនុស្សជួបយើងរាល់គ្នាទេ ព្រះអង្គប្រាកដជាទេវតាឬព្រះឥន្ទព្រះព្រហ្មនៅស្ថានទេវលោកច្បុតិមកបដិសន្ធិនៅនគរខ្មែរយើង ដើម្បីជួយយើងយោងប្រោសប្រណីស្រោចស្រង់ខ្មែរយើងនេះតែម្ដង ព្រះអង្គមានតេជបារមីបញ្ញាចិត្ត ព្រះកំហាក៏សប្តុះ ព្រះអង្គឃើញយើងជាកូនចៅកើតទុក្ខវេទនា ទ្រង់សព្វាជាប័ន្តាំខិងធ្វើឲ្យយើងបានសុខឥឡូវទើបតែ ៣ ខែ សោះព្រះអង្គតាមតាវបានឯករាជ្យជូនព្រះ

www.elibraryofcambodia.org

កដបំណង យើងកល់គ្នាបានសុខមែន ទឹកព្រះទ័យរបស់ព្រះអង្គទ្រង់ទសពិធរាជធម៌គ្រប់លក្ខណៈទាំងអស់ ។ លោកយាយនេះមានប្រសាសន៍ចប់ភ្លាម អ្នកស្តាប់ទាំងប៉ុន្មានទះដៃឡើងឮស្នូរគ្រាវ ៗ អបអរសាទរហើយសប្បាយស្រែកហ៊ោកញ្ជ្រៀវ ខ្លះស្រែកថា ៖

— ជយោព្រះមហាក្សត្រខ្មែរ ជយោព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ជយោប្រទេសខ្មែរ ជាឯករាជ្យដោយសារព្រះបញ្ញាញាណដ៏ភ្លឺថ្លា របស់ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន បរាជ័យទៅពួកអាចក្រពត្តិ ពួកអាមេរិចរទិលខ្ទេច ។

នៅថ្ងៃដ៏សប្បាយនោះ គ្រប់ផ្ទះទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលទូទៅទាំងប្រទេស ឮតែស្នូរសព្ទមានមនុស្ស ក្មេង ចាស់ ប្រុស ស្រី និយាយគ្នាសើចលេង សប្បាយគឹកកង មានសំរែកភាពគ្រាប់គ្រាន់លេងខ្លះផងដែរ នៅតាមមុខផ្ទះនិមួយ ៗ ដែលពីដើមធ្លាប់ឃើញដោតទង់ជ័យ

ពីរ តិចុងជ័យខ្មែរមួយ,ផ្កាកំផ្លឹមួយ នៅពេលនោះឃើញមាន ដោតតែទង់ជ័យខ្មែរ យើងតែមួយគត់យ៉ាងហ៊ានឯកច្ឆន្ទ មកវិញ ។ ញញឹមស្រស់ពព្រាយរំលេចដោយប្រាសាទអង្គរ វត្ត មានសភាពសេរីរីក ហាក់ដូចជាស្រែកប្រាប់បញ្ជាក់ ឲ្យពលរដ្ឋខ្មែរទាំងប្រទេសបានដឹងថា «ប្រទេសខ្មែរពលរដ្ឋ ខ្មែរបានរួចពីខ្ញុំកញ្ជះគេ បានសុខបានសប្បាយ គឺកើត ឡើងដោយស្នាព្រះហស្តព្រះបាទសម្តេចព្រះនរោត្តមសីហនុ ដែលព្រះអង្គយកព្រះជន្មទៅប្តូរ... ទៅថ្ងៃមុខប្រទេសកម្ពុជា នឹងបានរីកចំរើនរុងរឿងដូចយុគៈអង្គរវិញមិនខានឡើយ» ។

ផ្លូវគំនិតប្រទេសយួនឃើញប្រទេសខ្មែរបានសុខ ក៏មិន សប្បាយចិត្តសោះ ហើយដោយពូជតម្សណ៍ក៏ជាពោរបន់តែ ប្លន់ប្រទេសគេយកទៅធ្វើជារបស់ពួកនោះ ក៏បញ្ចេញគំនិត ចំពក់ឲ្យមករំលោភទាំងបំពាន លើទឹកដីកម្ពុជាបន្ថែម ទៀត ។ កាលនោះមានខ្មែរយើងខ្លះលក់ខ្លួនឲ្យយួនយៀក មិញនេះ មិនព្រមចុះចូលក្នុងសង្គមជាតិវិញទេ ក៏បែរ

ជាទៅធ្វើការបំរើយៀកមិញ ( សព្វថ្ងៃក៏មានដែរគឺពួកខ្មែរក្រហម-វៀត-ខ្មែរសេរី ពួកអស់នេះជាខ្ញុំកញ្ជះយួនដូចគ្នា-ជាមួយដែរ ) ធ្វើបាបខ្មែរជាតិឯង បំណងយកប្រទេសខ្មែរលក់ឲ្យយួន ក៏កាត់ត្បូងគេនៅខេត្តបាត់ដំបង នៅខេត្តក្រចេះ ស្ទឹងត្រែង និងតំបន់ឯទៀត ៗ យ៉ាងសម្បើម ។

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះអង្គទ្រង់មេត្តាករុណាពិតកូនចៅព្រះអង្គពេក កាលយៀកមិញជិះជាន់ធ្វើបាបនោះ ម៉្យាងទៀតដោយព្រះអង្គជាក្សត្រមានព្រះទ័យស្នេហាជាតិ មិនចង់ឲ្យប្រទេសណាមកបៀតបៀនព្រះនគរធ្វើបាបកូនចៅព្រះអង្គបាន មិនឲ្យពួកយៀកមិញប្លន់លោកប្រទេសខ្មែរបាននោះ ព្រះអង្គបង្កើតអង្គការមួយឈ្មោះ សហប្រតិបត្តិការសាមគ្គីដោយព្រះអង្គទ្រង់ជាអគ្គមេបញ្ជាការនាំកងទ័ព យាងចេញទៅធ្វើសហប្រតិបត្តិការវាយយៀកមិញនៅក្រវ៉ាយចាប បានជោគជ័យធ្វើឲ្យសត្រូវស្លាប់និងបាក់បែកខ្ទេចខ្ទីរត់ខ្ចាត់ខ្ចាយ ៗ បន្ទាប់មក

www.elibraryofcambodia.org

ទៀតកងទ័ពជាតិ ដែលក្នុងនោះមានព្រះអង្គជាព្រះមគ្គុទេសក៍ទៅបំផ្លាញសម្បុកយៀកមិញនៅស្រែបេស ក៏បានជោគជ័យយ៉ាងមហិមា ធ្វើឲ្យយៀកមិញស្លាប់និងបាក់ស្បាតរត់ទៅស្រុកយួនវិញអស់ទៅ ។

យកជ័យជំនះពីពួកយៀកមិញបានហើយ អាសីលនុ៊កជានខ្ញុំបំរើយួនក៏ចង់ធ្វើប្រធានាធិបតីចង់ដឹកនាំប្រទេសខ្មែរ ក៏គិតបំបែកនគរខ្មែរជាពីរយកទៅលក់ឲ្យចៅហ្វាយរបស់វា

ព្រះបាទសម្ដេចព្រះនរោត្តមសីហនុ ខ្លាចពលរដ្ឋឈាមខ្មែរវេទនាហើយព្រះអង្គមិនចង់ឲ្យខ្មែរបែកបាក់គ្នានិងធ្លាក់ខ្លួនទៅជាកញ្ជះបរទេសទៀតនោះ ព្រះអង្គបង្កើតអង្គការមួយទៀត ឈ្មោះសង្គមរាស្ត្រនិយមមានព្រះអង្គជាព្រះប្រធាន ឲ្យបោះឆ្នោតជាសកល ។ លុះបោះឆ្នោតទៅគណបក្សប្រជាធិបតេយ្យក្បាលជ័ររបស់អាសីលនុ៊កជានបរាជ័យចាញ់ឆ្នោតគណបក្សសង្គមរាស្ត្រនិយម (គណៈបក្ស

តែសុខឲ្យក្សត្រ រកយុត្តិធម៌ឲ្យក្សត្រ ចំពោះក្សត្រតារពារទេក ដីកប់រយគីឡូ ។

ក្នុងរាត្រីដ៏អស្ចារ្យនោះ ព្រះចន្ទរះភ្លឺថ្លាដូចពន្លឺព្រះអាទិត្យ ដែរឡល់ចក់កើយ ។ ពលរដ្ឋខ្មែរគ្រប់ភូមិគ្រប់ស្រុកតក់ពង់ ជំនុំគ្នានិយាយលេងពីនេះពីនោះ ស្រាប់តែក្រឡេកមើលទៅលើ ឃើញរង្សីព្រះភ័ក្រ្តសម្ដេចឪនៅក្នុងរង្សីព្រះចន្ទ ដែលរះភ្លឺថ្លាថែងថាំងស្នើភ្លឺចិញ្ចាចផ្ទះ ប្រោះព្រំមកលើប្រទេសខ្មែរ ព្រះភ័ក្រព្រះអង្គទ្រង់ញញឹម ទតមករកពលរដ្ឋខ្មែរពេញទាំងប្រទេសឲ្យសញ្ញាថា ប្រទេសខ្មែរបានសុខសប្បាយនិរទុក្ខនិរភ័យ ហើយ-សម្បូណ៌សក្ខុយហើយ ។

កាលដែលព្រះភ័ក្រ្តសម្ដេចឪ គេឃើញនៅក្នុងរង្សីព្រះចន្ទដ៏ភ្លឺថ្លានោះមិនមែនតែអ្នកភូមិមេសប្រចាំណាមួយប៉ុណ្ណោះទេ គេឃើញគ្រប់ៗភូមិទូទៅក្នុងព្រះរាជាណាចក្រតាំងមូលៗ

ពេលស្រុកបានសុខសប្បាយ ឃើញកាចារ្យយ៉ែត្រ

ឡប់ទៅស្រុកកំណើតវិញ តែរាជីនីខ្លួនទាំងជាអ្នកស្រុកគិតសំឡេះវានោះ វាចឹងជាក់មេជាយតាំងពីពេលនោះបាត់ទៅ ។

តាំងពីពេលនោះមក ប្រទេសកម្ពុជាដែលមានសម្តេចឪ ព្រះបិតាឯករាជ្យជាតិ ជាព្រះអគ្គមគ្គុទ្ទេសទ្រង់ដឹកនាំមក ពោះប្រទេសជិតខាងមានភ្លើងសង្គ្រាមឆេះរោលរាល កាប់ចាក់គ្នាយ៉ាងណា ក៏ប្រទេសខ្មែរបានសុខសម្បូណ៌សប្បាយរុងរឿង ស្ទើរតែរកប្រទេសណាមួយមកប្រៀបផ្ទឹមពុំបានឡើយ ។ ប្រជារាស្ត្រមានសេរីភាពសមិទ្ធិកើតស្គុះស្គាយ...

សរសេរចប់នៅមេសប្រចណ្ឌា ស្រុកពារាំង ខេត្តព្រៃវែង

ថ្ងៃទី ២៣ ខែកញ្ញា ១៩៨៧

អ្នកនិពន្ធ

**អែម ម៉ុច**

**ចប់**

យើងខ្ញុំជាកូន ខ្ចៅ ឃុនសំរ៉ង ខ្ចៅ យ៉ាតណៃ ខ្ចៅសុខផល ខ្ចៅ វិសាល ខ្ចៅ វ៉ាមុន ខ្ចៅ ភាភាដា ខ្ចៅ ចំរើន ខ្ចៅ ភារី

បាននបត្ថម្ភការផ្សាយសៀវភៅនេះជាeBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក **ខ្ចៅ ពាញ** និង ឧបាសិកា **ឈរ យឿន**

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

## មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **ប៊ូរ សេងទីន**

កញ្ញា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ចៅ ឃុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

មានលក់ដុំនិងរាយនៅ
បណ្ណាគារ បន្ទាយស្រី
ផ្ទះលេខ 75Eo ផ្លូវប៉ាស្ទ័រ ភ្នំពេញ
តូបលេខ 23,24 ផ្សារអូឬស្សី

www.elibraryofcambodia.org